**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៥០)

ភាគីដាក់ឯកសារ: ក្រុមការពារក្ដីរបស់អ្នកស្រី អ៊ឹម ចែម

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៧

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 02-July-2018, 09:25
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.សចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ប្រភេទចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ)**

---

**ដាក់ដោយ៖**

**សហមេធាវី**

ប៊ិត ស៊ាងលឹម

Wayne JORDASH, QC

**ផ្ញើជូន៖**

**ចៅក្រមអង្គបុរេជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម BAIK Kang Jin

ចៅក្រម ន៍យ ថុល

ចៅក្រម Oivier BEAUVALLET

ចៅក្រម ហួត វុទ្ធី

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**ទាំងអស់ក្នុងសំណុំរឿង ០០៤/១**

## I. សេចក្តីផ្តើម និងការសង្ខេប

១. អ្នកស្រី អ៊ឹម ចែម តាមរយៈសហមេធាវីរបស់អ្នកស្រី ("ក្រុមការពារក្តី") តទៅនេះ សូមដាក់ជូនចម្លើយតបទៅនឹង *បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ)*[1] ដោយបដិសេធចោលនូវរាល់បទចោទប្រកាន់ទាំងអស់ប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម ក្រោមហេតុផលខ្វះយុត្តាធិការបុគ្គល[2] ។

<u>បណ្តឹងឧទ្ធរណ៍សង្ខេប</u>

២. សហព្រះរាជអាជ្ញាអន្តរជាតិ ("សពអ") បានលើកឡើងថា សហចៅក្រមស៊ើបអង្កេត ("សចស") មានកំហុសអង្គច្បាប់ និង/ឬ កំហុសអង្គហេតុ លើការវិភាគរបស់ពួកគាត់ដែលមាននៅក្នុងដីកាដំណោះស្រាយ[3] ។ ជាពិសេស បណ្តឹងឧទ្ធរណ៍បានតវ៉ាដោយលើកឡើងថា សចស i) បានខកខានមិនបានពិចារណាលំរាល់អង្គហេតុទាំងអស់ដែលខ្លួនបានប្តឹងទៅ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបឋម និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម និងរបៀបដែលអង្គហេតុទាំងអស់នេះអាចជះឥទ្ធិពលលើបញ្ហាថាតើអ្នកស្រី អ៊ឹម ចែម ស្ថិតនៅក្នុងដែនយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែរឬយ៉ាងណា[4] ii) សចស មានកំហុសនៅក្នុងការវិភាគ និងអនុវត្តធាតុផ្សំមួយចំនួននៃឧក្រិដ្ឋកម្មសម្លាប់រង្គាល និងការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ[5] និង iii) សចស មានកំហុសក្នុងការរកឃើញថា អ្នកស្រី អ៊ឹម ចែម មិនមែនជាលេខាស្រុកកោះអណ្តែត ហើយក៏មិនមែនជា

---

[1] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ធ្វើនៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៧, ឯកសារ **D308/3/1/1** ("បណ្តឹងឧទ្ធរណ៍") ។

[2] ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះនៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧, ឯកសារ **D308/3** ("ដីកាដំណោះស្រាយ, ឯកសារ **D308/3**") ។

[3] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ១ ។

[4] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ១១-៣៧ (ទទ្បីករណ៍ទី១ និងទទ្បីករណ៍ទី២) ។ *សូមមើលផងដែរ*, បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ២ ។

[5] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣៨-៥៧ (ទទ្បីករណ៍ទីទី៣ និងទទ្បីករណ៍ទី៤) ។ *សូមមើលផងដែរ*, បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ២ ។

សមាជិកគណៈតំបន់ ១៣ ដែរ[6] ។ ដោយផ្អែកលើមូលដ្ឋានដែលត្រូវបានចោទថាមានកំហុសអង្គច្បាប់ និងអង្គហេតុទាំងនេះហើយទើប សពអ ស្នើអង្គបុរេជំនុំជម្រះ (“អបជ”) សុំឱ្យ៖ i) បញ្ជូនសំណុំរឿងត្រឡប់ទៅសហចៅក្រមស៊ើបអង្កេតវិញ ដើម្បីឱ្យពួកគាត់ធ្វើការវាយតម្លៃសារជាថ្មីថាតើអ្នកស្រី អ៊ឹម ចែម ស្ថិតក្នុងដែនយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឬយ៉ាងណា ឬមានជម្រើសម៉្យាងទៀត គឺសុំឱ្យ ii) អបជ ធ្វើការវាយតម្លៃឡើងវិញរឿងក្តីនេះឡើងវិញដោយខ្លួនឯង[7] ។

<u>សេចក្តីសង្ខេបនៃចម្លើយតប</u>

៣. នៅក្នុងចម្លើយតបនេះ ក្រុមការពារក្តីសូមស្នើទៅ អបជ សុំឱ្យធ្វើការច្រានចោលបណ្តឹងឧទ្ធរណ៍នេះ ។ បណ្តឹងឧទ្ធរណ៍បានផ្អែកលើការយល់ខុសជាមូលដ្ឋាន ដែលថា ឱ្យតែរាល់កំហុសអង្គច្បាប់ ឬកំហុសអង្គហេតុគឺអាចនាំអោយមានការបដិសេធចោលសេចក្តីសម្រេច និងការស្នើសុំឱ្យមានការវាយតម្លៃឡើងវិញនៃច្បាប់គ្រប់គ្រង និងអង្គហេតុពាក់ព័ន្ធជាធរមាន ។ នៅក្នុងបណ្តឹងឧទ្ធរណ៍ទាំងមូល សពអ មិនបានពិគ្រោះវែកញែកអំពីបទដ្ឋានត្រឹមត្រូវនៃការពិនិត្យបណ្តឹងឧទ្ធរណ៍ឡើងវិញ និងធ្វើការចង្អុលបង្ហាញនូវកំហុសអង្គហេតុដែលត្រូវបានចោទប្រកាន់នៅក្នុងការប្តឹងឧទ្ធរណ៍ថាវាកើតឡើងយ៉ាងដូចម្តេច ដែលបានបង្កឱ្យមានការរំលោភបំពានឆន្ទានុសិទ្ធិរបស់ សចស ក្នុងការសន្និដ្ឋានថា អ.វ.ត.ក ខ្វះយុត្តាធិការបុគ្គលលើអ្នកស្រី អ៊ឹម ចែម ។ សរុបសេចក្តីមក ក្រុមការពារក្តីយល់ឃើញថា សចស i) មិនមានកំហុសអង្គច្បាប់ ក្នុងការវាយតម្លៃលើអង្គហេតុពាក់ព័ន្ធនានាដែលពួកគាត់ត្រូវបានប្តឹងក្នុងគោលបំណងកំណត់យុត្តាធិការបុគ្គលនៅក្នុងសំណុំរឿង០០៤/១ ii) សចស មិនមានកំហុសក្នុងការវិភាគ និងអនុវត្តលើធាតុផ្សំនានាសម្រាប់ការចោទប្រកាន់លើបទឧក្រិដ្ឋនៃការសម្លាប់រង្គាល ព្រមទាំងការបាត់ខ្លួនដោយបង្ខំ និង iii) សចស មិនមានកំហុសក្នុងការសន្និដ្ឋានថាអ្នកស្រី អ៊ឹម ចែម មិនមែនជាលេខាស្រុកកោះអណ្តែត និងក៏មិនមែនជាសមាជិកគណៈតំបន់១៣ ដែរ ។

---

[6] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៥៨-៨១ (ទទ្បីករណ៍ទី៥ និងទទ្បីករណ៍ទី៦) ។ *សូមមើលផងដែរ*, បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ២ ។

[7] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣ និង ៨២ ។

## II. សាវតារ

៤. ក្រុមការពារក្តីសូមដាក់រួមបញ្ចូលគ្នាដោយយោងតាមប្រវត្តិនីតិវិធី ដែលមាននៅក្នុងចម្លើយតបរបស់ក្រុមការពារក្តីទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់ សពអ[8] ។ បន្ថែមពីនោះ នៅថ្ងៃទី២២ ខែ កុម្ភៈ ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតបានដាក់ចេញផ្នែកសេចក្តីសម្រេចនៃដីកាដំណោះស្រាយនៅក្នុងសំណុំរឿង០០៤/១ ចំណែកសេចក្តីសំអាងហេតុពេញលេញនឹងត្រូវដាក់ចេញតាមក្រោយ[9] ។ នៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ២០១៧ សចស បានចេញដីកាដំណោះស្រាយនៃសំណុំរឿង០០៤/១ ដែលមានសំអាងហេតុពេញលេញ ដោយធ្វើការបញ្ជាក់ថាអ្នកស្រី អ៊ឹម ចែម ស្ថិតក្រៅដែនយុត្តាធិការបុគ្គលនៅ អ.វ.ត.ក និងសម្រេចច្រានចោលនូវរាល់បទចោទប្រកាន់ទាំងអស់[10] ។ នៅថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១៧ សពអ បានដាក់បណ្តឹងឧទ្ធរណ៍ ។ នៅថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៧ ក្រុមការពារក្តីបានដាក់សំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម ដើម្បីសុំពន្យារពេល និងបង្កើនចំនួនសន្លឹករបស់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍[11] និងត្រូវបានទទួលការអនុញ្ញាតជាផ្នែកកាលពីថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៧[12] ។

## III. ការសង្ខេបបឋម

[8] ចម្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងអ្នកស្រី តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ធ្វើនៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦, ឯកសារ **D304/6** ("ចម្លើយតបទៅនឹងសារណាស្ថាពររបស់ សពអ, **D304/6** "), ត្រង់កថាខណ្ឌ ៧-១៤ ។

[9] ដីកាដំណោះស្រាយ (ផ្នែកសេចក្តីសម្រេច) ចុះនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧, ឯកសារ **D308** ។

[10] ដីកាដំណោះស្រាយ, ឯកសារ **D308/3** នៅកថាខណ្ឌ ៣១២-៣១៣ និង កថាខណ្ឌ ៣២៥ ។

[11] សំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម ដើម្បីសុំពន្យារពេល និងបង្កើនចំនួនសន្លឹករបស់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) (D308/3/1/1) ធ្វើនៅថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៧, ឯកសារ **D308/3/1/2** ។

[12] សេចក្តីសម្រេចលើសំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម ដើម្បីសុំពន្យារពេល និងបង្កើនចំនួនសន្លឹករបស់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) (D308/3/1/1) ធ្វើនៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៧, ឯកសារ **D308/3/1/3** [ដោយអនុញ្ញាតឱ្យក្រុមការពារក្តីពន្យារពេលបានមួយខែ និងអនុញ្ញាតឱ្យបង្កើន សន្លឹកបន្ថែមចំនួន ១៥ ទំព័រ] ។

៥. នៅក្នុងដីកាដំណោះស្រាយ សចស បានរកឃើញថា អ្នកស្រី អ៊ឹម ចែម ស្ថិតនៅក្រៅដែនយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដោយផ្អែកលើមូលដ្ឋានស្តីពី i) ការកំណត់កត្តាភូមិសាស្ត្រនៃបទចោទប្រកាន់លើ (និងការរួមចំណែករបស់) អ្នកស្រី អ៊ឹម ចែម ត្រឹមតែស្រុកមួយ[13] ii) ដោយសារកម្រិតមុខតំណែងជាផ្លូវការរបស់អ្នកស្រីជាលេខាស្រុក និងជាសមាជិកនៃគណៈតំបន់ (និងការមានភស្តុតាងមិនគ្រប់គ្រាន់ពាក់ព័ន្ធនឹងមុខតំណែងផ្សេងទៀត ដែលត្រូវបានតម្លើងឱ្យអ្នកស្រី)[14] iii) ការពិតដែលមានកម្មាភិបាលជាងមួយរយនាក់ផ្សេងទៀតដែលមានឋានៈស្មើគ្នានាពេលនោះ[15] និង iv) ចំនួនជនរងគ្រោះពីអំពើឧក្រិដ្ឋកម្មដែលត្រូវបានរងការចោទប្រកាន់ នៅពេលពិចារណានៅក្នុងបរិបទនៃរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល (នៅពេលដែលត្រូវបានគេមើលឃើញទាំងឋានៈរបស់អ្នកស្រី អ៊ឹម ចែម ជាមួយដំណើរវិវឌ្ឍន៍ និងសកម្មភាពនានារបស់អ្នកស្រី)[16] ។

៦. សពអ បានលើកឡើងថា សចស មានកំហុសលើអង្គច្បាប់ និង/ឬអង្គហេតុ ចំពោះការវិភាគនៅក្នុងដីកាដំណោះស្រាយ និងស្នះស្វែងសុំឱ្យមានការវាយតម្លៃសារជាថ្មីនូវការរកឃើញរបស់ពួកគាត់ត្រង់ចំណុចដែលថា អ.វ.ត.ក ខ្វះយុត្តាធិការបុគ្គលលើអ្នកស្រី អ៊ឹម ចែម[17] ។

៧. នៅក្នុងការសង្កេតបឋមទាំងនេះ ក្រុមការពារក្តីយល់ឃើញថា បណ្តឹងឧទ្ធរណ៍ទាំងមូល និយាយឱ្យខ្លីទៅ គឺគួរតែត្រូវបានច្រានចោល ។ ជារួម i) នៅក្នុងទឡ្ហីករណ៍ទាំងស្រុង ចាប់ពីទឡ្ហីករណ៍ទី១ ដល់ទឡ្ហីករណ៍ទី៦ សពអ បានខកខានមិនបានពិគ្រោះអំពីបទដ្ឋានត្រឹមត្រូវនៃការពិនិត្យឡើងវិញឡើយ ។ ការបង្ហាញនូវកំហុសអង្គច្បាប់ និងកំហុសអង្គហេតុ[18] ដោយមិនបង្ហាញអំពីផលវិបាកកើតចេញពីការរំលោភបំពានឆន្ទានុសិទ្ធិ មិនបានបំពេញតាមបទដ្ឋានសម្រាប់ធ្វើការពិនិត្យឡើងវិញនោះទេ ។ លើសពីនេះទៅទៀត ii) ទឡ្ហីករណ៍ទី៣ និងទឡ្ហីករណ៍ទី៤ នៃបណ្តឹងឧទ្ធរណ៍ ស្នះស្វែង

---

[13] ដីកាដំណោះស្រាយ, ឯកសារ **D308/3** នៅកថាខណ្ឌ ៣១៣ ។

[14] ដីកាដំណោះស្រាយ, ឯកសារ **D308/3** នៅកថាខណ្ឌ ៣១៥ ។

[15] ដីកាដំណោះស្រាយ, ឯកសារ **D308/3** នៅកថាខណ្ឌ ៣១៦ ។

[16] ដីកាដំណោះស្រាយ, ឯកសារ **D308/3** នៅកថាខណ្ឌ ៣១៧-៣១៩ ។

[17] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ១-៣ និង ៨២ ។

[18] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ១០ ។

ធ្វើការជំទាស់ទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អ្នកស្រី អ៊ឹម ចែម ចំពោះបទល្មើសពាក់ព័ន្ធ ដែលត្រូវបានចោទប្រកាន់ និងដែនកំណត់ជាក់លាក់សម្រាប់ឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល និងការបាត់ខ្លួនដោយបង្ខំ ។ អាស្រ័យហេតុនេះ ទទ្បីករណ៍ទាំងឡាយមិនបានវែកញែកលើស្ថានភាពសម្រាប់ធ្វើការកំណត់ណាមួយនៃដីកាដំណោះស្រាយ ហើយវាស្ថិតនៅក្រៅដែនអំណាចរបស់ អបជ ដើម្បីធ្វើការពិនិត្យឡើងវិញ ។

## ក. ស.អ.៣ ខកខានមិនបានចែកញែកអំពីបទដ្ឋានជាសារវន្តនៃការពិនិត្យឡើងវិញ

៨. ចាប់ពីទទ្បីករណ៍ទី១ ដល់ទទ្បីករណ៍ទី៦ គឺសុទ្ធតែមានវិការៈ ។ ទទ្បីករណ៍នីមួយៗខកខានមិនបានធ្វើការជជែកតវ៉ាអំពីបទដ្ឋានត្រឹមត្រូវសម្រាប់ពិនិត្យលើបណ្តឹងឧទ្ធរណ៍សារឡើងវិញនោះទេ ។ ដូចដែលបានពិភាក្សាខាងក្រោម មិនមែនឱ្យតែរាល់កំហុសអង្គច្បាប់ ឬអង្គហេតុ សុទ្ធសឹងតែនឹងត្រូវធ្វើឱ្យ អបជ បដិសេធចោលនូវសេចក្តីសម្រេចរបស់ សចស ឡើយ[19] ។ ដូចដែលបានថ្លែងដោយ អបជ ដូច្នេះថា ម្ចាស់បណ្តឹងឧទ្ធរណ៍មានបន្ទុកក្នុងការចង្អុលបង្ហាញថា i) កំហុសអង្គច្បាប់នាំឱ្យសេចក្តីសម្រេចគ្មានសុពលភាព ii) កំហុសអង្គហេតុនាំឱ្យមានភាពអយុត្តិធម៌ ឬ iii) សេចក្តីសម្រេច ឬដីកាដែលមិនសមហេតុផលខ្លាំងនាំឱ្យមានសេចក្តីសន្និដ្ឋានថា សចស មិនបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឱ្យបានត្រឹមត្រូវ[20] ។ រាល់សារណារបស់ភាគីទាំងឡាយណាដែល

[19] *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿង លេខ ០០២/១៩-០៩-២០០៧/អវកត/កសចស (អ.ប.ជ. ៦២)*, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹង 'ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ' ធ្វើនៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១០, ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០១០, ឯកសារ **D353/2/3** នៅកថាខណ្ឌ ៨ ។ *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿង លេខ ០០២/១៩-០៩-២០០៧/អវកត/កសចស (អ.ប.ជ. ៦៤)*, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូនៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១០, ឯកសារ **A371/2/12** នៅកថាខណ្ឌ ២២ ។

[20] *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿង លេខ ០០២/១៩-០៩-២០០៧/អវកត/កសចស (អ.ប.ជ. ៦៤)*, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូនៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១០, ឯកសារ **A371/2/12** នៅកថាខណ្ឌ ២២ ។

គ្មានសក្តានុពលបង្កឱ្យមានការកែប្រែ ឬបង្កឱ្យមានការកែសម្រួលដីកាសម្រេចដែលរងការជំទាស់ទេនោះ អាចនឹងត្រូវបានបដិសេធចោលភ្លាមៗដោយអង្គបុរេជំនុំជម្រះ ហើយក៏មិនចាំបាច់ត្រូវធ្វើការពិចារណាលើអង្គសេចក្តីដែរ[21] ។

៩. សរុបមកវិញ ក្រុមការពារក្តីសន្និដ្ឋានថា សពអ i) ខកខានមិនបានពិគ្រោះវែកញែកអំពីបទដ្ឋានត្រឹមត្រូវក្នុងការពិនិត្យលើបណ្តឹងឧទ្ធរណ៍សារឡើងវិញ ដែលអាចអនុវត្តបានចំពោះសេចក្តីសម្រេចឆន្ទានុសិទ្ធិនានា តួយ៉ាងដូចជាសេចក្តីសម្រេចលើការកំណត់យុត្តាធិការបុគ្គល និង ii) ការខកខានមិនបានកំណត់អត្តសញ្ញាណ និងធ្វើការតវ៉ាអំពីថាតើមានហេតុផលអ្វីខ្លះដែលបង្ហាញឱ្យឃើញថាកំហុសអង្គច្បាប់ និងកំហុសអង្គហេតុ កើតចេញពីការរំលោភបំពានឆន្ទានុសិទ្ធិ ដែលតម្រូវឱ្យមានអន្តរាគមន៍ពីសំណាក់អង្គបុរេជំនុំជម្រះ ។

### *i. បទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងឧទ្ធរណ៍ដែលអាចអនុវត្តបានចំពោះសេចក្តីសម្រេចបញ្ហាយុត្តាធិការបុគ្គល*

១០. ដីកាដំណោះស្រាយបានចាត់ទុកថា ការវាយតម្លៃលើលក្ខណៈវិនិច្ឆ័យចំពោះ "ការទទួលខុសត្រូវខ្ពស់បំផុត" នៃលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការបុគ្គលនៅ អ.វ.ត.ក គឺភាគច្រើនជាឆន្ទានុសិទ្ធិ[22] ។ កាន់តែជាក់លាក់ជាងនេះទៅទៀតគឺថា សចស បានសន្និដ្ឋានថា៖ វាតម្រូវឱ្យមានការវាយតម្លៃឱ្យបានទូលំទូលាយ ប៉ុន្តែអាចត្រឹមតែធ្វើការវិនិច្ឆ័យលើសេចក្តីសម្រេចបានខ្លះៗតែប៉ុណ្ណោះ[23] ។ សចស ទទួលបាននូវឆន្ទានុសិទ្ធិដ៏ទូលំទូលាយបំផុតនៅពេលធ្វើការកំណត់ថាតើជនសង្ស័យណាខ្លះស្ថិតនៅក្នុងចំណោមជនដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្ម ។

---

[21] *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿង លេខ ០០២/១៩-០៩-២០០៧/អវតក/កសចស (អ.ប.ជ. ៤៧ និង ៤៨)*, សាលដីកាលើបណ្តឹងឧទ្ធរណ៍លើដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតលេខ D250/3/3 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០ និងដីកាសម្រេចលេខ D250/3/2 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ២០១០ លើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១០, ឯកសារ **D250/3/2/1/5** នៅកថាខណ្ឌ ២២ ។

[22] ដីកាដំណោះស្រាយ, ឯកសារ **D308/3** នៅកថាខណ្ឌ ៩ ។

[23] ដីកាដំណោះស្រាយ, ឯកសារ **D308/3** នៅកថាខណ្ឌ ៩ ។

១១. ចំពោះបញ្ហានៃការកំណត់ប្រភេទនៃ "ការទទួលខុសត្រូវខ្ពស់បំផុត" គឺជាសេចក្ដីសម្រេចឆន្ទានុសិទ្ធិ ដែលត្រូវបានលើកឡើងជាលើកដំបូងទៅកាន់អង្គបុរេជំនុំជម្រះ ។ ទោះជាយ៉ាងណាក្ដី ការណែនាំដ៏មានអត្ថប្រយោជន៍អាចនឹងត្រូវបានបង្កើតឡើងនៅក្នុងសេចក្ដីសម្រេចមុនៗរបស់ អ.វ.ត.ក ។ ក្នុងករណីនេះ អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង០០១ បានបញ្ជាក់យ៉ាងច្បាស់ថា:

> ការកំណត់ថាតើជនជាប់ចោទជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែរឬយ៉ាងណា តម្រូវឱ្យមានការប្រើឆន្ទានុសិទ្ធិយ៉ាងច្រើន ។ ឧទាហរណ៍ តុលាការមិនមានឆន្ទានុសិទ្ធក្នុងការកំណត់យុត្តាធិការពេលវេលា និងយុត្តាធិការលើរឿងក្ដីរបស់ អ.វ.ត.ក នោះទេ ។ យុត្តាធិការទាំងពីរនេះ ត្រូវបានបែងចែកជាក់លាក់តាមរយៈនិយមន័យច្បាស់លាស់ ដូច្នេះហើយ ជនសង្ស័យ និង អ.វ.ត.ក អាចធ្វើការផ្ទៀងផ្ទាត់បាន ពីព្រោះយុត្តាធិការទាំងពីរនេះ ពាក់ព័ន្ធទៅនឹងបញ្ហាអង្គហេតុ ឬ អង្គច្បាប់សុទ្ធសាធ ដែលមានលក្ខណៈច្បាស់លាស់ក្នុងការធ្វើការសម្រេចតាមផ្លូវច្បាប់បាន ។ ផ្ទុយទៅវិញ ទាំងជនសង្ស័យ និង អ.វ.ត.ក មិនអាចបង្ហាញថាតើជនសង្ស័យ គឺជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ឬក៏មិនមែន ដោយអនុលោមទៅតាម*លក្ខណៈវិនិច្ឆ័យច្បាស់លាស់ អរូបិយ និងស្វ័យភាពបានឡើយ*[24] ។

១២. គ្មានហេតុផលរឹងមាំអ្វីរារាំងមិនឱ្យអនុវត្តតាមសេចក្ដីសម្រេចនេះទេ ។ ផ្ទុយទៅវិញ អនុលោមតាមគោលការណ៍នៃភាពច្បាស់លាស់ និងភាពដូចគ្នានៃច្បាប់[25] ហើយក៏ស្របទៅតាមភាពត្រឹមត្រូវ

---

[24] *រឿងក្ដីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច, សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អជតក*, សាលដីកា ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១២, ឯកសារ **F28** ("សាលដីកានៃសំណុំរឿង០០១, ឯកសារ **F28**") នៅកថាខណ្ឌ ៦២ (សង្កត់ន័យបន្ថែមត្រង់អក្សរទ្រេត) ។

[25] ដីកាដំណោះស្រាយ, ឯកសារ **D308/3** នៅកថាខណ្ឌ ១០ ។ *សូមមើលផងដែរ*, សម្រាប់ទស្សនៈដូចគ្នា ដែលបានសម្រេចដោយចៅក្រម Bohlander ម្នាក់ឯង៖ *សំណុំរឿង មាស មុត, រឿងក្ដីលេខ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស*, ដីកាសម្រេចរួមលើសំណើរបស់ មាស មុត ស្ដីពីយុត្តាធិការបុគ្គល ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៦, ឯកសារ **D298.1** ត្រង់កថាខណ្ឌ ២៨ ["តាមវិធានទូទៅ ដើម្បីជាប្រយោជន៍សច្ចភាពផ្លូវច្បាប់ និងសមភាពនៅចំពោះមុខច្បាប់ [សហចៅក្រមស៊ើបអង្កេត] ត្រូវអនុវត្តគោលការណ៍ច្បាប់ និងវិធានឱ្យស្របតាមការយល់ឃើញរបស់ [អង្គជំនុំជម្រះតុលាការកំពូល] ប្រសិនបើមិនមានមូលហេតុផ្ទុយសមស្រប ។ ដូចដែល [អង្គជំនុំជម្រះតុលាការកំពូល] បានបញ្ជាក់សញ្ញាណថ្មីៗរបស់អង្គជំនុំជម្រះនីមួយៗទាក់ទងនឹងទស្សនទានផ្លូវច្បាប់ដែលបានបង្កើតរួចហើយនោះ នឹងធ្វើឱ្យទស្សនទាន

ជាក់ស្តែងនៃច្បាប់ដែលបានថ្លែងប្រកាស សចស ត្រូវតែអនុម័តតាមវិធីសាស្ត្រនេះ ។

១៣. នៅក្នុងករណីនេះ ការពិនិត្យឡើងវិញរបស់អង្គបុរេជំនុំជម្រះទៅលើសេចក្តីសម្រេចឆន្ទានុសិទ្ធិដែលត្រូវបានធ្វើឡើងដោយ សចស គឺកម្រិតត្រឹមថាតើ សចស បានអនុវត្តត្រឹមត្រូវ ឬមិនត្រឹមត្រូវនូវឆន្ទានុសិទ្ធិដែលខ្លួនមាន ដោយយកតាមលំនាំលក្ខណៈវិនិច្ឆ័យដែលបានចងក្រងក្នុងសំណុំរឿង *Milosević* នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គូស្លាវី (“ICTY”)[26] ។ អបជ មិនត្រូវយកការយល់ឃើញរបស់ខ្លួន ទៅជំនួសលើការយល់ឃើញរបស់ សចស ទេ[27] ។ លក្ខណៈវិនិច្ឆ័យដូចដែល អបជ បានសង្កេតឃើញ មានខ្លឹមសារដូចតទៅ ៖

> នៅក្នុងការពិនិត្យមើលឡើងវិញនូវការអនុវត្តឆន្ទានុសិទ្ធិនេះ បញ្ហាចោទមិនមែនថាតើតុលាការកំពូលយល់ស្រប ឬ មិនយល់ស្របជាមួយនឹងសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងនោះទេ ប៉ុន្តែបញ្ហាត្រង់ថា “តើអង្គជំនុំជម្រះសាលាដំបូងបានអនុវត្តត្រឹមត្រូវ ឬមិនត្រឹមត្រូវនូវឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការចេញសេចក្តីសម្រេចនោះ” ។ ដើម្បីអាចតវ៉ានូវសេចក្តីសម្រេចឆន្ទានុសិទ្ធិមួយម្ចាស់បណ្តឹងសារទុក្ខត្រូវបង្ហាញថា “អង្គជំនុំជម្រះសាលាដំបូងសម្រេចខុសដោយខ្លួនឯងលើគោលការណ៍ដែលត្រូវអនុវត្ត ឬច្បាប់ដែលពាក់ព័ន្ធនឹងការអនុវត្តឆន្ទានុសិទ្ធិនេះ” ឬត្រូវបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង “[បានដាក់]ទម្ងន់លើការពិចារណាអង្គហេតុមិនពាក់ព័ន្ធ...ខកខានមិនបានដាក់ទម្ងន់ ឬដាក់ទម្ងន់មិនបានគ្រប់គ្រាន់លើការពិចារណាដល់អង្គហេតុពាក់ព័ន្ធ ឬ...មានការភ័ន្តច្រឡំអង្គហេតុ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន” ឬ

---

ទាំងនេះមានភាពខុសគ្នា ហើយប៉ះពាល់ដល់សច្ចភាពផ្លូវច្បាប់នៃនីតិវិធី និងច្បាប់របស់ អ.វ.ត.ក ហើយតាមការអនុវត្តជាក់ស្តែង សញ្ញាណថ្មីៗទាំងនេះត្រូវចៀសវាង (ដកចំណុចទ្រេតដែលបញ្ជាក់ន័យចេញ)] ។

[26] *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿង លេខ ០០២/១៩-០៩-២០០៧/អវតក/កសចស (អ.ប.ជ. ២៥),* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុក នៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៩, ឯកសារ **D164/3/6** នៅកថាខណ្ឌ ២៥-២៦ ។

[27] *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿង លេខ ០០២/១៩-០៩-២០០៧/អវតក/កសចស (អ.ប.ជ. ២៥),* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុក នៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៩, ឯកសារ **D164/3/6** នៅកថាខណ្ឌ ២៦ ។

សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមាន "ភាពមិនសមហេតុផលទាល់តែសោះ ឬភាពអយុត្តិធម៌យ៉ាងច្បាស់ ដែលអង្គជំនុំជម្រះតុលាការកំពូលអាចទាញការសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងប្រាកដជាខកខានក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឱ្យបានត្រឹមត្រូវ"[28] ។

### *ii. បន្ទុក និងបទដ្ឋាននៃការបង្ហាញភស្តុតាងនៃការមានកំហុសអង្គច្បាប់ និងកំហុសអង្គហេតុ*

១៤. ដូចដែល អបជ ធ្លាប់បានលើកឡើងដូច្នេះថា មិនមែនឱ្យតែរាល់កំហុសអង្គច្បាប់ ឬអង្គហេតុ គឺសុទ្ធតែនឹងធ្វើឱ្យ អបជ បដិសេធចោលនូវសេចក្ដីសម្រេចឆន្ទានុសិទ្ធឡើយ[29] ។ កំហុសមួយដែលអាចនឹងត្រូវយកមកពិចារណាបាន លុះណាតែវាជាកំហុសដែល*មានអានុភាពខ្លាំងក្លា*លើការអនុវត្តឆន្ទានុសិទ្ធិ ដែលជាហេតុនាំឱ្យភាគីធ្វើការប្ដឹងឧទ្ធរណ៍[30] ។ ម្ចាស់បណ្ដឹងឧទ្ធរណ៍មានបន្ទុកក្នុងការបង្ហាញឱ្យឃើញថា i) កំហុសអង្គច្បាប់នាំឱ្យសេចក្ដីសម្រេចគ្មានសុពលភាព ii) កំហុសអង្គហេតុនាំឱ្យមានភាពអយុត្តិធម៌ ឬ iii) សេចក្ដីសម្រេច ឬដីកាមិនសមហេតុផលខ្លាំងដែលនាំឱ្យមាន

---

[28] *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿង លេខ ០០២/១៩-០៩-២០០៧/អវតក/កសចស (អ.ប.ជ. ២៥)*, សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុក នៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៩, ឯកសារ **D164/3/6** នៅកថាខណ្ឌ ២៥[១០] (លុបសេចក្ដីយោង) ។

[29] *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿង លេខ ០០២/១៩-០៩-២០០៧/អវតក/កសចស (អ.ប.ជ. ៦២)*, សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់សហមេធាវីការពារក្ដី អៀង ធីរិទ្ធ ប្រឆាំងនឹង 'ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហមេធាវីការពារក្ដី អៀង ធីរិទ្ធ' ធ្វើនៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១០, ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០១០, ឯកសារ **D353/2/3** នៅកថាខណ្ឌ ៨ ។ *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿង លេខ ០០២/១៩-០៩-២០០៧/អវតក/កសចស (អ.ប.ជ. ៦៤)*, សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូនៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១០, ឯកសារ **A371/2/12** នៅកថាខណ្ឌ ២២ ។

[30] *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿង លេខ ០០២/១៩-០៩-២០០៧/អវតក/កសចស (អ.ប.ជ. ៦២)*, សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់សហមេធាវីការពារក្ដី អៀង ធីរិទ្ធ ប្រឆាំងនឹង 'ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហមេធាវីការពារក្ដី អៀង ធីរិទ្ធ' ធ្វើនៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១០, ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០១០, ឯកសារ **D353/2/3** នៅកថាខណ្ឌ ៨ ។

០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៥០)

សេចក្តីសន្និដ្ឋានថា សចស មិនបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឱ្យបានត្រឹមត្រូវ[31] ។ ទឡ្ហីករណ៍របស់ភាគីណាដែលមិនមានសក្តានុពលនាំឱ្យឈានដល់ការច្រានចោល ឬកែប្រែសេចក្តីសម្រេចដែលត្រូវបានរងការជំទាស់ អបជ អាចច្រានចោលភ្លាមៗ ដោយមិនចាំបាច់ពិនិត្យដល់អង្គសេចក្តី[32] ។

១៥. ដូចដែលត្រូវបានលើកជាអំណះអំណាងបន្ថែមទៀតនៅផ្នែកខាងក្រោម បណ្តឹងឧទ្ធរណ៍ផ្អែកលើការយល់ខុសជាមូលដ្ឋានដែលថា រាល់កំហុសអង្គច្បាប់ ឬកំហុសអង្គហេតុណាមួយក៏ដោយ គឺសុទ្ធតែអាចនាំឱ្យមានការកែប្រែនូវសេចក្តីសម្រេច និងនាំឱ្យមានការវាយតម្លៃសារជាថ្មីនៃច្បាប់គ្រប់គ្រងដំណើរការតុលាការដែលមាន និងអង្គហេតុជាធរមាន ។ សពអ មិនយកចិត្តទុកដាក់លើកាតព្វកិច្ចរបស់ខ្លួន ក្នុងការកំណត់អត្តសញ្ញាណនៃកំហុសតាមការចោទប្រកាន់ទាំងនោះ ហើយប្រសិនជាវាត្រូវបានបង្កើតឡើងក៏ដោយ ថាតើវាកើតមានឡើងរបៀបណាដែលបានបង្កឱ្យមានការបំពានឆន្ទានុសិទ្ធិ ដើម្បីឈានដល់ការសន្និដ្ឋានថា អ.វ.ត.ក ខ្វះយុត្តាធិការលើអ្នកស្រី អ៊ឹម ចែម ។ បណ្តឹងឧទ្ធរណ៍គួរតែត្រូវបានច្រានចោល ដោយសារមានវិការៈ ។

## ខ. ទឡ្ហីករណ៍ទី៣ និងទឡ្ហីករណ៍ទី៤ គឺមិនអាចនឹងទទួលយកបាន

១៦. ក្រុមការពារក្តីស្នើឡើងថា ទឡ្ហីករណ៍ទី៣ និងទឡ្ហីករណ៍ទី៤ គឺសុទ្ធតែមិនអាចទទួលយកបាន ហើយក៏មិនគួរត្រូវបានធ្វើការពិនិត្យពិច័យលើអង្គសេចក្តីនានាដែរ ។ ដូចដែលបានលើកឡើងនៅខាងក្រោម ការចោទប្រកាន់ពីការទទួលខុសត្រូវក្នុងបទព្រហ្មទណ្ឌរបស់អ្នកស្រី អ៊ឹម ចែម និងវិធីសាស្ត្ររបស់អង្គបុរេជំនុំជម្រះ ចំពោះការកំណត់វិសាលភាពនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

---

[31] *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿង លេខ ០០២/១៩-០៩-២០០៧/អវកត/កសចស (អ.ប.ជ. ៦៤)*, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូនៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១០, ឯកសារ **A371/2/12** នៅកថាខណ្ឌ ២២ ។

[32] *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវកត/កសចស (អ.ប.ជ. ៤៧ &៤៨)*, សាលដីកាលើបណ្តឹងឧទ្ធរណ៍លើដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេត លេខ D250/3/3 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ និងដីកាសម្រេចលេខ D250/3/2 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ លើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១០, ឯកសារ **D250/3/2/1/5** នៅកថាខណ្ឌ ២២ ។

សម្រាប់ការសម្លាប់រង្គាល និងការបាត់ខ្លួនដោយបង្ខំ គឺសុទ្ធតែមិនមែនជាបញ្ហាដែលស្ថិតនៅក្នុងអំណាចរបស់អង្គបុរេជំនុំជម្រះធ្វើការពិនិត្យឡើងវិញឡើយ ។ ទឡ្ហីករណ៍នីមួយៗពាក់ព័ន្ធនឹងបញ្ហា (*ចេតនាឧក្រិដ្ឋ* និងការដាក់ដែនកំណត់សម្រាប់ឧក្រិដ្ឋកម្មនានា) ដែលមិនមែនជាការកំណត់នៃដីកាដំណោះស្រាយ ឬបើមិនដូច្នោះទេ វាជាទឡ្ហីករណ៍ស្ថិតនៅក្នុងវិសាលភាពនៃការពិនិត្យឡើងវិញដែលអាចអនុញ្ញាតបាន ។

***i. សពអ ស្នើសុំដែលមិនអាចអនុញ្ញាតបានឱ្យធ្វើការកែតម្រូវកំហុសនៅក្នុងសេចក្តីសន្និដ្ឋានរបស់សចស ស្តីពីការសម្លាប់រង្គាល និងការបាត់ខ្លួនដោយបង្ខំក្នុងគោលបំណងបង្កើតនូវការទទួលខុសត្រូវព្រហ្មទណ្ឌដល់អ្នកស្រី អៀង ធីរិទ្ធ***

១៧. កាតព្វកិច្ចដំបូងរបស់តុលាការមួយ គឺបញ្ជាក់អំពីដែនយុត្តាធិការរបស់ខ្លួនជាមុនសិន[33] ។ ភាពជា

---

[33] *សូមមើល, សាលក្រមរបស់តុលាការរដ្ឋបាលនៃអង្គការពលកម្មអន្តរជាតិលើពាក្យបណ្តឹងដែលបានធ្វើឡើងប្រឆាំងអង្គការអប់រំសង្គម និងវប្បធម៌របស់អង្គការសហប្រជាជាតិ* (IC.J. របាយការណ៍ឆ្នាំ ១៩៥៦) មតិយោបល់ណែនាំ ធ្វើនៅថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៥៦ ។ មតិយោបល់ផ្សេងគ្នារបស់ចៅក្រម Cordova ត្រង់ទំព័រ ១៦៣ [**ភ្ជាប់ជាឯកសារសម្អាង៖ ២៣**] ដោយបានដកស្រង់ចេញពី រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Dusko Tadić* (IT-94-1), ដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ដីកាសម្រេចលើញត្តិរបស់មេធាវីការពារក្តីស្នើសុំឱ្យទទួលយកបណ្តឹងឧទ្ធរណ៍លើបញ្ហាដែនសមត្ថកិច្ចតុលាការ ធ្វើនៅថ្ងៃទី ២ ខែ តុលា ឆ្នាំ ១៩៩៥ ("ដីកាសម្រេចស្តីពីបញ្ហាយុត្តាធិការ ក្នុងរឿងក្តី *Tadić*") ត្រង់កថាខណ្ឌ ១៨ [**ភ្ជាប់ជាឯកសារសម្អាង៖ ១**]។ *សូមមើលផងដែរ, រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Milan Milutinović និងអ្នកផ្សេងទៀត* (IT-05-87-PT), សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង, សេចក្តីសម្រេចលើញត្តិស្តីពីបញ្ហាយុត្តាធិការរបស់ Ojdanic: សហចារីដោយប្រយោល, ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦, ត្រង់កថាខណ្ឌ ២៣, ២៥, ៤០ [**ខ្លឹមសារនៃសារណាត្រង់កថាខណ្ឌ៤០៖** ["អង្គជំនុំជម្រះសាលាដំបូងសូមបញ្ជាក់ថាទម្រង់ នៃការទទួលខុសត្រូវដែលមានចែងក្នុងកថាខណ្ឌ២២ នៃសំណូមពររួមពីអ្នកសុំធ្វើវិសោធនកម្មលើបទចោទប្រកាន់ គឺមិនមាននៅក្នុងច្បាប់អន្តរជាតិទំនៀមទម្លាប់នោះទេ នៅពេលដែលកើតមានព្រឹត្តិការណ៍ដែលត្រូវបានរងការចោទនៅក្នុងដីកាចោទប្រកាន់ ។ អង្គជំនុំជម្រះបានរម្លឹកឡើងវិញនូវសេចក្តីសង្កេតរបស់ខ្លួននៅក្នុងកថាខណ្ឌ២៥ផ្នែកខាងលើថា ប្រសិនបើលក្ខខណ្ឌទាំងពីរដែលបានមកពីអង្គជំនុំជម្រះសាលាឧទ្ធរណ៍កាលពីខែឧសភា ឆ្នាំ ២០០៣ នោះ សេចក្តីសម្រេចរបស់ *Ojdanic* គឺមិនត្រូវបានបំពេញតាមទម្លាប់នៃការទទួលខុសត្រូវទេនោះ តុលាការក៏គ្មានយុត្តាធិការដើម្បីកំណត់ពីទោសកំហុសរបស់ជនជាប់ចោទអនុលោមតាមទម្រង់នោះដែរ ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះនឹងមិនចូលរួមក្នុងការពិនិត្យមើលថាតើលក្ខន្តិកៈមានលក្ខណៈទូលំទូលាយគ្រប់គ្រាន់ឬទេ ដើម្បីរួមបញ្ចូល "សហចារីដោយប្រយោល" ប្រសិនបើទម្រង់នៃការទទួលខុសត្រូវបែបនេះ មិនមាននៅក្នុងទំនៀមទម្លាប់។"] (លុបចោលសេចក្តីយោង) [**ភ្ជាប់ជាឯកសារសម្អាង៖ ៧**]។

ម្ចាស់យុត្តាធិការរបស់តុលាការ គឺត្រូវធ្វើការកំណត់ជាមុននូវសិទ្ធិអំណាចរបស់ស្ថាប័នតុលាការ ដើម្បីបង្កើតនូវអំណះអំណាងផ្លូវច្បាប់*ណាមួយ* ស្តីពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់បុគ្គលម្នាក់ ។ ជាក់ស្តែង អំណះអំណាងបង្ហាញពីកង្វះយុត្តាធិការ គឺស្មើនឹងការខ្វះអំណាចស្របច្បាប់ ដើម្បីធ្វើការសម្រេចតាមផ្លូវតុលាការលើសុពលភាពនៃរឿងក្តីនេះ ។ ដូចដែលបានលើកឡើងដោយអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងសំណុំរឿង០០១ ដូច្នេះថា "តុលាការដែលមានសមត្ថកិច្ច គឺជាបុរេលក្ខខណ្ឌនៃការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ។ ការបន្តកិច្ចដំណើរការនីតិវិធីដោយមិនមានយុត្តាធិការ នឹងធ្វើឱ្យប៉ះពាល់ដល់មូលដ្ឋាននៃអាណត្តិរបស់ អ.វ.ត.ក និងធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងលែងមានអំណាចស្របច្បាប់ដើម្បីជំនុំជម្រះជនជាប់ចោទ"[34] ។ ការរកឃើញទាំងឡាយណារបស់តុលាការលើខ្លឹមសារសំខាន់ៗនៃឧក្រិដ្ឋកម្ម ឬការទទួលខុសត្រូវលើបទល្មើសព្រហ្មទណ្ឌរបស់ជនសង្ស័យ ដែលត្រូវបានរងការចោទប្រកាន់ដោយគ្មានយុត្តាធិការ អាចចាត់ទុកថាជាការធ្វើឡើងនៅ*ចំពោះមុខជនដែលមិនមែនជាចៅក្រម*[35] ។

១៨. ការពិតដែលបញ្ហាយុត្តាធិការបង្កើតបានជាបុរេលក្ខខណ្ឌចាំបាច់មួយ ដើម្បីអាចរកឃើញនូវប្រភពនៃអង្គសេចក្តីនានាដែលកើតចេញមកពីចរិកលក្ខណៈនៃយុត្តាធិការ ។ គ្មានអ្វីក្រៅពី "អំណាចច្បាប់ឡើយ ហេតុដូច្នេះវាជាអំណាចស្របច្បាប់ដ៏សំខាន់ "ដើម្បីលើកឡើងអំពីច្បាប់"[36] ។ បើនិយាយឱ្យកាន់តែច្បាស់ជាងនេះគឺថា តុលាការមួយដែលអវត្តមាននូវកត្តាធម្មនុរូប គឺ "មិនអាចឱ្យតុលាការនោះ អាចធ្វើសេចក្តីសន្និដ្ឋានផ្លូវច្បាប់ណាមួយ ឬក៏ធ្វើការសង្កេតអ្វីក៏ដោយ" លើខ្លឹមសារសំខាន់ៗនៃបញ្ហាចោទនានានៅក្នុងរឿងក្តីនោះបានទេ[37] ។

---

34 សាលដីកានៃសំណុំរឿង០០១, ឯកសារ **F28** ត្រង់កថាខណ្ឌ ៣៤ ។

35 "ចំពោះមុខបុគ្គលដែលមិនមែនជាចៅក្រម," គឺ "គ្មានសមត្ថកិច្ច" ។

36 ដីកាសម្រេចស្តីពីបញ្ហាយុត្តាធិការ ក្នុងរឿងក្តី *Tadić* ត្រង់កថាខណ្ឌ ១០ ។

37 *សំណុំរឿងពាក់ព័ន្ធនឹងការប្រើកម្លាំងតាមផ្លូវច្បាប់ (Serbia និង Montenegro ទល់នឹងប្រទេស Belgium)*, (របាយការណ៍របស់ I.C.J. ឆ្នាំ ២០០៤) សាលដីកាលើការជំទាស់បឋម ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៤, ត្រង់កថាខណ្ឌ ១២៨ ["ទោះយ៉ាងណាក្តី សម្រាប់សំណុំរឿងបច្ចុប្បន្ន កាលណាតុលាការឈានដល់ការធ្វើសេចក្តីសន្និដ្ឋានថា ខ្លួនគ្មានដែនសមត្ថកិច្ចដើម្បីចាត់ការលើការអះអាងដែលមាននៅក្នុងពាក្យស្នើសុំហើយនោះ"] ខ្លួនក៏មិនអាចធ្វើសេចក្តីសន្និដ្ឋាន ឬធ្វើការ

សង្កេតលើបញ្ហាអ្វីក៏ដោយ ទាក់ទងនឹងសំណួរចោទស្តីពីថាតើការរំលោភបំពានត្រូវបានប្រព្រឹត្តទៅដោយរបៀបណា ឬការទទួលខុសត្រូវជាអន្តរជាតិអ្វីខ្លះដែលកើតឡើង។”] [**ភ្ជាប់ជាឯកសារសម្អាង៖ ២៦**]។ *រឿងក្តីពាក់ពន្ធ័នឹងប្រទេសទីម័រខាងកើត* (*រវាងព័រទុយហ្គាល់ ទល់នឹង អូស្ត្រាលី*), (របាយការណ៍របស់ I.C.J. ឆ្នាំ ១៩៩៥) សាលដីកាចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៥ ត្រង់កថាខណ្ឌ ៣៥-៣៦ [កថាខណ្ឌ ៣៦៖ ដោយបានច្រានចោល នូវការជំទាស់លើកទីមួយក្នុងចំណោមពីររបស់ប្រទេសអូស្ត្រាលីដែលការជំទាស់នេះត្រូវបានពិនិត្យវិនិច្ឆ័យ ប៉ុន្តែបានសម្រេចទទួលយកការជំទាស់លើកទីពីរ [ការជំទាស់លើបញ្ហាយុត្តាធិកា] តុលាការយល់ឃើញថា ... តុលាការមិនអាចចេញសេចក្តីសម្រេចលើពាក្យបណ្តឹងរបស់ប្រទេសព័រទុយហ្គាល់បានទេ ទាំងសុពលភាពនៃអង្គសេចក្តីទោះបីមានសំណួរចោទឡើងសំខាន់យ៉ាងណាក៏ដោយ ទាំងការបរិយាយនូវអំណះអំណាងដោយម្ចាស់ពាក្យបណ្តឹង ព្រមទាំងការលើកឡើងវិធានច្បាប់អន្តរជាតិពាក់ព័ន្ធ [**ភ្ជាប់ជាឯកសារសម្អាង៖ ២៥**]។ *រឿងក្តីទាក់ទងនឹងសកម្មភាពប្រដាប់អាវុធនៅលើទឹកដីកុងហ្គោ (ពាក្យសុំថ្មី នៅឆ្នាំ ២០០២)* (*សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ទល់នឹង ប្រទេសរវ៉ាន់ដា*) (របាយការណ៍របស់ I.C.J. ឆ្នាំ ២០០៦) សាលដីកាលើយុត្តាធិការរបស់តុលាការ និងការទទួលយកពាក្យសុំ, ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០០៦, ត្រង់កថាខណ្ឌ ១២៧ [តុលាការបានឈានដល់ការធ្វើសេចក្តីសន្និដ្ឋានដូច្នេះថា ខ្លួនមិនអាចទទួលយកនូវអំណះអំណាងណាមួយដែលបានលើកឡើងដើម្បីបញ្ជូនបន្តទៅ DRC ក្នុងការបង្កើតនូវយុត្តាធិការរបស់ខ្លួន សម្រាប់ រឿងក្តីបច្ចុប្បន្ននេះទេ ហេតុដូច្នេះហើយ យើងក៏មិនអាចចាត់ការលើពាក្យសុំក្រោយៗទៀតដែរ” [**ភ្ជាប់ជាឯកសារសម្អាង៖ ២៧**]។ *សូមមើលផងដែរ, រឿងក្តីរបស់ the Monetary Gold ដែលត្រូវបានដកចេញពីទីក្រុងរ៉ូមនៅឆ្នាំ ១៩៤៣ (ប្រទេសអ៊ីតាលី ទល់នឹង បារាំង, ចក្រភពអង់គ្លេស, ប្រទេសអៀរឡង់ខាងជើង និងសហរដ្ឋអាមេរិក)* (របាយការណ៍របស់ I.C.J. ឆ្នាំ ១៩៥៤) សាលក្រមលើសំណួរបឋមចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៥៤, ត្រង់ទំព័រ ៣២-៣៣ [**ភ្ជាប់ជាឯកសារសម្អាង៖ ២២**]។ រឿងក្តីរវាង *អាហ្វ្រិកភាគនិរតី* (*រឿងក្តីរបស់ប្រទេសអេត្យូព្យ៉ា ទល់នឹង អាហ្វ្រិកខាងត្បូង, សំណុំរឿងប្រទេសលីបេរីយ៉ា ទល់នឹង អាហ្វ្រិកខាងត្បូង*) (របាយការណ៍របស់ I.C.J. ឆ្នាំ ១៩៦៦) សាលដីកាលើការជំនុំជម្រះដំណាក់កាលទីពីរ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៦៦ ត្រង់កថាខណ្ឌ ៥៩។]” [**ភ្ជាប់ជាឯកសារសម្អាង៖ ២៤**] ។ អំណះអំណាងច្បាប់ស្រដៀងគ្នានេះ ក៏ត្រូវបានអនុម័តនៅតុលាការ ICTY (*សូមមើល, រឿងក្តីរបស់ Prosecutor ទល់នឹង Delalić* និងអ្នកផ្សេងទៀត, រឿងក្តីលេខ, (IT-96-21), សាលដីកា, អង្គជំនុំជម្រះតុលាការកំពូល, មតិជំទាស់របស់ចៅក្រម Bennouna ទៅលើបញ្ហាដែនយុត្តាធិការនៃអង្គជំនុំជម្រះសាលាដំបូង ដើម្បីបើកសវនាការជំនុំជម្រះលើបញ្ហានៃការសុំធ្វើការដោះលែងជាបណ្តោះអាសន្ន ធ្វើនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៩៩, ត្រង់កថាខណ្ឌ ១ [“យើងមិនបានធ្វើការសម្រេចលើអង្គសេចក្តីនៃញត្តិនេះទេ ដោយសារយើងជឿថា អង្គជំនុំជម្រះសាលាឧទ្ធរណ៍មិនមានយុត្តាធិការក្នុងការសម្រេចលើបញ្ហានេះ”] [**ភ្ជាប់ជាឯកសារសម្អាង៖ ២**] ហើយនៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសម្រេចថា នៅពេលការអនុវត្តនូវយុត្តាធិការរបស់ខ្លួនត្រូវបានបដិសេធចោល បញ្ហានេះត្រូវបានចាត់ទុកថា ជាករណីដែល “មិនអាចយកមកវិនិច្ឆ័យបាន” ហើយផលវិបាក គឺថាតុលាការគ្មានលទ្ធភាពក្នុងការជំនុំជម្រះលើខ្លឹមសារសំខាន់ៗបានទេ ។ (*សូមមើល, រឿងក្តីរបស់ Prosecutor ទល់នឹង Thomas Lubanga Dyilo, រឿងក្តីលេខ* (ICC-01/04-01/06 (OA4)), អង្គជំនុំជម្រះតុលាការកំពូល, សាលដីកាលើបណ្តឹងសាទុក្ខរបស់លោក Thomas Lubanga Dyilo ប្រឆាំងនឹងសេចក្តីសម្រេចលើការជំទាស់តវ៉ារបស់ក្រុមការពារក្តីទៅនឹងបញ្ហាដែនយុត្តាធិការរបស់តុលាការ ដោយអនុលោមតាមមាត្រា ១៩ (២) នៃលក្ខន្តិកៈ[តុលាការព្រហ្មទណ្ឌ

១៩. និយាយម៉្យាងទៀត ការរកឃើញថា អ.វ.ត.ក ខ្វះយុត្តាធិការលើអ្នកស្រី អ៊ឹម ចែម[38] រារាំងនូវអំណះអំណាងទាំងឡាយណា ដែលលើកឡើងពាក់ព័ន្ធទៅនឹងលទ្ធភាពនៃការទទួលខុសត្រូវរបស់អ្នកស្រីលើបទល្មើសព្រហ្មទណ្ឌទាំងនោះ[39] ។ ការសន្និដ្ឋានណាមួយដែលទាក់ទងនឹងលក្ខខណ្ឌបែបនេះ នឹងធ្វើឱ្យប៉ះពាល់ដល់ភាពចម្បងនៃអាណត្តិរបស់ អ.វ.ត.ក និងជាការធ្វើឡើង *ហួសពីអំណាចច្បាប់* លើវាល់ភាពត្រឹមត្រូវនៃអំណាចស្របច្បាប់ ។ អាស្រ័យហេតុនេះ ទឡ្ហីករណ៍ទី៣ និងទឡ្ហីករណ៍ទី៤ នៃបណ្តឹងឧទ្ធរណ៍ដែលបានពឹងផ្អែកទាំងស្រុងលើការជំទាស់នានា ទាក់ទងនឹងការទទួលខុសត្រូវលើបទល្មើសព្រហ្មទណ្ឌរបស់អ្នកស្រី អ៊ឹម ចែម ត្រូវតែច្រានចោល ។

### *ii. សពអ មិនអាចធ្វើការស្នើសុំឱ្យពិនិត្យសារឡើងវិញនូវវិធីសាស្ត្ររបស់ សចស លើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការសម្លាប់រង្គាលឡើយ*

២០. ក្រុមការពារក្តីយល់ឃើញថា គ្មានការបើកឱកាសសម្រាប់ អបជ ដើម្បីធ្វើការពិនិត្យឡើងវិញនូវវិធីសាស្ត្ររបស់ សចស ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការសម្លាប់រង្គាល និងការបាត់ខ្លួនដោយបង្ខំបានទេ ពីព្រោះដែនកំណត់ជាក់លាក់នៃបទឧក្រិដ្ឋទាំងពីរនេះមិនមែនបានមកពីវិសាលភាពនៃអំណាចរបស់អង្គបុរេជំនុំជម្រះក្នុងការពិនិត្យឡើងវិញនោះទេ ។

២១. សពអ បានចោទប្រកាន់ថា "សចស មានកំហុសអង្គច្បាប់ដោយការរកឃើញថា ចេតនានៅក្នុងឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល គឺជាកាសម្លាប់ក្នុងកម្រិត 'ដ៏ច្រើន' ត្រូវតែត្រូវបានបង្កើតឡើង

---

អន្តរជាតិ] ដែលបានធ្វើនៅថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០០៦, ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៦, ត្រង់កថាខណ្ឌ ២១-២៤ [ខ្លឹមសារនៃកថាខណ្ឌ ២៣៖ "វត្តមានរបស់នរណាម្នាក់ដែលបានថ្លែងរួចហើយ រារាំង...ដែលមិនត្រូវបានបរិយាយម្តងមួយៗនៅក្នុងមាត្រា ១៧ [ជាឧបសគ្គចំពោះការអនុវត្តយុត្តាធិការរបស់តុលាការនេះ] ធ្វើឱ្យរឿងក្តីនេះ មិនអាចទទួលយកបាន ហើយហេតុដូច្នេះ ក៏មានន័យថា តុលាការមិនអាចយករឿងក្តីនេះមកធ្វើការវិនិច្ឆ័យបានដែរ"] [**ភ្ជាប់ជាឯកសារសម្អាង៖ ២០**]។

[38] *សូមមើល*, ដីកាដំណោះស្រាយ (សំអាងហេតុ) ត្រង់កថាខណ្ឌ ៣២៥ ។

[39] *សូមមើលឧទាហរណ៍*, ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ២៨១-៣១២ [ជាពិសេសត្រង់កថាខណ្ឌ ៣០៧៖ "ភស្តុតាងស្តីពីការទទួលខុសត្រូវ ការប្រព្រឹត្ត និងសិទ្ធិអំណាចរបស់អ្នកស្រី អ៊ឹម ចែម បានបង្ហាញយ៉ាងរឹងមាំថា គាត់អាចទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មទាំងអស់នេះ តាមរយៈទម្រង់នៃការទទួលខុសត្រូវដែលមាននៅក្នុងសេចក្តីជូនដំណឹងអំពីបទចោទ"]។

'*ជាមុន*'[40] ។ លើសពីនេះ សពអ បានបន្តចោទប្រកាន់ទៀតថា "សចស បានអនុវត្តខុសនូវនិយមន័យនៃឧក្រិដ្ឋកម្មសម័យទំនើបនៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ដែលមិនមានអត្ថិភាពក្នុងឆ្នាំ ១៩៧៥ ជំនួសឱ្យធាតុផ្សំនានានៃអំពើអមនុស្សធម៌ផ្សេងៗទៀតក្នុងរូបភាពជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"[41] ។ ទោះជាយ៉ាងណាក្តី ការចោទប្រកាន់ពីការមានកំហុសអង្គច្បាប់ទាំងនេះ វាស្ថិតនៅក្រៅដែនអំណាចរបស់ អបជ ក្នុងការពិនិត្យឡើងវិញ ។

២២. ដូចដែលបានបញ្ជាក់ដោយ អបជ ក្នុងសំណុំរឿង ០០២ ដូច្នេះថា "ការជំទាស់ទាក់ទងនឹងបញ្ហាជាក់លាក់មួយចំនួននៃបទល្មើសសំខាន់មួយ ឬទម្រង់នៃការទទួលខុសត្រូវ ... គឺជាបញ្ហាដែលត្រូវដោះស្រាយនៅតុលាការ ។ ឧទាហរណ៍ ការជំទាស់ទៅនឹងនិយមន័យជាក់លាក់ និងការអនុវត្តធាតុផ្សំនៃបទល្មើសដែលត្រូវបានចោទប្រកាន់ មិនអាចទទួលយកបានទេនៅដំណាក់កាលបុរេជំនុំជម្រះ ... បញ្ហានេះ ដោយសារតែការជំទាស់នេះ ជាញឹកញាប់មានការពាក់ព័ន្ធនឹងការសម្រេចលើបញ្ហាពិតប្រាកដ ឬបញ្ហាលាយឡំគ្នានៃអង្គច្បាប់ និងអង្គហេតុដែលត្រូវធ្វើឡើងនៅពេលសវនាការតាមការសួរដេញដោល និងការថ្លឹងថ្លែងលើភស្តុតាងទាំងអស់"[42] ។

២៣. ការជំទាស់តវ៉ារបស់ សពអ ចំពោះវិធីសាស្ត្ររបស់ សចស ក្នុងការវាយតម្លៃលើការសម្លាប់រង្គាល និងការបាត់ខ្លួនដោយបង្ខំ គឺជាវិវាទប្រឈមដ៏ធំមួយដែលវាពាក់ព័ន្ធទៅនឹងដែនកំណត់ជាក់លាក់នៃឧក្រិដ្ឋកម្មនេះ ។ ទឡ្ហីករណ៍ទី៣ ពាក់ព័ន្ធទៅនឹងចំណោទសំណួរលាយឡំគ្នាទាក់ទងនឹងបញ្ហាអង្គ

---

[40] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣៨ ។

[41] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៤៧ ។

[42] *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿង លេខ ០០២/១៩-០៩-២០០៧/អវកត/កសចស (អ.ប.ជ. ១៤៥ & ១៤៦)*, សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ធ្វើនៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១, ឯកសារ **D427/4/7** កថាខណ្ឌ ៦២ *ដកស្រង់ក្នុងនោះ* ពីក្នុង*សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវកត/កសចស (អ.ប.ជ. ៣៨), សំណុំរឿងរបស់ នួន ជា សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម* (JCE) ធ្វើនៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០, ឯកសារ **D97/15/9** ("ដីកាសម្រេចលើសហឧក្រិដ្ឋកម្មរួម"), ត្រង់កថាខណ្ឌ ២៣ (លុបចេញសេចក្តីយោងផ្សេងៗទៀត) ។

ច្បាប់ និងអង្គហេតុ ដែលរាប់បញ្ចូល*អំពើឧក្រិដ្ឋ* និង*ចេតនាឧក្រិដ្ឋ* នៃការសម្លាប់រង្គាល[43] ការអនុវត្តនូវវិធីសាស្ត្រភស្តុតាងដ៏ត្រឹមត្រូវលើបញ្ហានៃការមាន*ចេតនាឧក្រិដ្ឋ* ទៅតាមកាលៈទេសៈនៃរឿងក្តី (ឧទាហរណ៍ថាតើវាមានការចង្អុលបង្ហាញនូវលក្ខខណ្ឌនៃការមានចេតនា*ជាមុន* ក្នុងការសម្លាប់ឬទេ)[44] ហើយថាតើ សចស មានកំហុសអង្គច្បាប់ ដោយសារតែមិនបានរកឃើញថា អ្នកស្រី អ៊ឹម ចែម មាន*ចេតនាឧក្រិដ្ឋ*ជាចាំបាច់ក្នុងការសម្លាប់រង្គាលមែនដែរឬទេ[45] ។ ទឡ្ហីករណ៍ទី៤ ពាក់ព័ន្ធទៅនឹងចំណោទសំណួរលាយឡំគ្នាចំពោះបញ្ហាអង្គច្បាប់ និងអង្គហេតុ ដែលរាប់បញ្ចូល*អំពើឧក្រិដ្ឋ* និង*ចេតនាឧក្រិដ្ឋ* នៃការបាត់ខ្លួនដោយបង្ខំ[46] ថាតើ សចស បានធ្វើខុសដែរឬទេ ក្នុងការតម្រូវថាបុគ្គលណាម្នាក់នោះ ត្រូវតែបានធ្វើការសួររកអំពីទីតាំងរបស់ជនរងគ្រោះ[47] និងវិធីសាស្ត្រត្រឹមត្រូវក្នុងការបង្ហាញភស្តុតាងទាក់ទងទៅនឹងការបាត់ខ្លួនដោយបង្ខំ[48] ។ សំណួរចោទលើបញ្ហាអង្គហេតុ និងបញ្ហាអង្គច្បាប់ទាំងនេះ មិនអាចធ្វើការកំណត់បាននៅចំពោះមុខ អបជ ក្នុងរង្វង់បរិបទនៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចមួយលើបញ្ហាយុត្តាធិការនោះទេ ប៉ុន្តែវាជាបញ្ហាដែលអាចត្រូវបានកំណត់សេចក្តីនៅក្នុងសវនាការ ។ ហេតុដូច្នេះហើយបានជាទឡ្ហីករណ៍ទី៣ និង ទឡ្ហីករណ៍ទី៤ គួរតែត្រូវបានច្រានចោល ។

## IV. ចម្លើយតប

### ក. ទឡ្ហីករណ៍ទី១÷ សចស មិនបានធ្វើខុសដោយការរកឃើញថា បទចោទប្រកាន់ទាំងឡាយណាដែលមានក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ សពអ ត្រូវតែបានធ្វើការចោទប្រកាន់ជាមុនសិន ដើម្បីអាចក្លាយជាផ្នែកមួយនៃដីកាដំណោះស្រាយ

43 បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣៨-៤៤ ។

44 បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣៨-៤០ និងត្រង់កថាខណ្ឌ ៤៥-៤៦ ។

45 បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣៨ និងត្រង់កថាខណ្ឌ ៤៥-៤៦ ។

46 បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៤៧-៥១ ។

47 បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៥២-៥៥ ។

48 បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៥៦-៥៧ ។

២៤. នៅក្នុងកថាខណ្ឌ១១ ដល់កថាខណ្ឌ២២ នៃបណ្ដឹងឧទ្ធរណ៍ សពអ បានអះអាងថា "សចស ខកខានមិនបានពិចារណាលើអំពីការចោទប្រកាន់ផ្នែកអង្គហេតុដែលពួកគាត់ត្រូវបានប្ដឹងទេ ឬ អំណះអំណាងរបស់ [សពអ] នៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់គាត់ ដែលបានបង្ហាញពីរបៀប ដែលភស្តុតាងទាំងនោះ គាំទ្រចំពោះការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ [អ្នកស្រី] អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មដ៏សែនធ្ងន់ធ្ងរជាច្រើនទាំងនោះ"[49] ។ សពអ បានអះអាងថា សចស មាន កាតព្វកិច្ចក្នុងការពិចារណាថាតើភស្តុតាងបញ្ជាក់ណាខ្លះ ដែលកំណត់បានថាជនសង្ស័យដែលមាន ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម មួយចំនួន "មានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មណាមួយនៅក្រោមទម្រង់នៃការ ទទួលខុសត្រូវជាធរមានណាមួយដែរឬទេ"[50] ។

២៥. ដើម្បីគាំទ្រដល់ការអះអាងនេះ សពអ ស្នើឡើងថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកា សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមមួយចំនួន បានផ្ដល់នូវការជូនដំណឹងដល់ក្រុមការពារក្ដីពីអង្គ ហេតុទាំងឡាយដែលអាចនាំឱ្យឈានដល់ការចោទប្រកាន់[51] ហើយថាការសន្និដ្ឋានផ្ទុយរបស់ សចស ជាការដកហូតនូវការផ្ដន្ទាទោសចេញ៖ i) សិទ្ធិចូលរួមក្នុងការដឹងឮអំពីភស្តុតាងលើការ ទទួលខុសត្រូវរបស់អ្នកស្រី អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មទាំងនេះ[52] និង ii) សិទ្ធិក្នុងការប្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងការរកឃើញរបស់ សចស ពាក់ព័ន្ធទៅនឹងអង្គហេតុនានាដែលនាំឱ្យអ្នកស្រី អ៊ឹម ចែម មិនត្រូវបានរងការចោទប្រកាន់[53] ។ ក្រុមការពារក្ដីនឹងធ្វើការវែកញែកនូវអំណះអំណាងនានា ដែល បានលើកឡើងនៅក្នុងបណ្ដឹងឧទ្ធរណ៍ទាក់ទងនឹងទឡ្ហីករណ៍ទី១ នៅផ្នែកខាងក្រោម ។

### *i. ការអនុម័តច្បាប់ខុសទៅជាធរមានរបស់ សចស ទាក់ទងទៅនឹងអង្គហេតុ ដែលអាចនាំឱ្យឈានដល់ការបញ្ជូនរឿងទៅជំនុំជម្រះ*

---

[49] បណ្ដឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ១២ ។

[50] បណ្ដឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ១១ ។

[51] បណ្ដឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ១៣-១៤ ។

[52] បណ្ដឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ១៥ ។

[53] បណ្ដឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ១៦-១៧ ។

២៦. សពអ បានអះអាងថា "ការពឹងផ្អែករបស់ សចស លើដីកាសម្រេចមួយ ដែលបានចេញដោយការិយាល័យរបស់ខ្លួន ក្នុងអំឡុងពេលនៃការស៊ើបអង្កេតក្នុងសំណុំរឿង០០២ នោះ គឺមិនមានភាពគួរឱ្យជឿជាក់នោះឡើយ"[54] ។ ការទាមទារនេះ ត្រូវបានធ្វើឡើងដោយយោងពី*ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យធ្វើការបំភ្លឺ* ("ដីកាស្រាយបំភ្លឺ")[55] ដែលបានលើកឡើងថា សចស "មិនអាចនឹងធ្វើការបញ្ជូនបុគ្គលណាមួយទៅជំនុំជម្រះ ចំពោះអង្គហេតុណាដែលបុគ្គលនោះមិនត្រូវបានដាក់ឱ្យឋិតក្រោមការពិនិត្យជាមុននោះទេ"[56] ។ សពអ បានអះអាងថា សចស បានពឹងផ្អែកលើប្រយោគតែមួយដែលត្រូវបានដកចេញពីក្នុងបរិបទនេះ ហើយ "ប្រយោគយ៉ាងជិតបន្តពីក្រោយមានសារសំខាន់ក្នុងការបកស្រាយដីកាសម្រេចនោះទាំងមូល និងពិតជាផ្ទុយទាំងស្រុងទៅនឹងការលើកឡើងរបស់ សចស ដែលថាដីកាដំណោះស្រាយអាចរំលងចោលអង្គហេតុនានាដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបឋម ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា គ្រាន់តែដោយសារពួកវាមិនបាន "ចោទប្រកាន់" ជនសង្ស័យអំពីឧក្រិដ្ឋកម្មជាក់លាក់ ទាំងអស់នេះ ឬអំពីទម្រង់នៃការទទួលខុសត្រូវ"[57] ។ ប្រយោគដើមកំពុងលើកឡើងអានដូចនេះ៖

> សហចៅក្រមស៊ើបអង្កេតត្រូវវិនិច្ឆ័យលើអង្គហេតុទាំងអស់ ដែលត្រូវបានប្ដឹងដោយត្រឹមត្រូវតាម នីតិវិធីច្បាប់ ។ ក្នុងនោះសហចៅក្រមស៊ើបអង្កេតអាចនឹងចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬ ដីកាលើកលែងការចោទប្រកាន់[58] ។

២៧. សពអ បានបន្ថែមទៀតថា "គោលបំណងតែមួយគត់" នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

---

[54] បណ្ដឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ១៨ ។

[55] *សំណុំរឿងក្ដី នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវកត/កសចស,* ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យធ្វើការបំភ្លឺ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩, ឯកសារ **D198/1** ។

[56] *សំណុំរឿងក្ដី នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវកត/កសចស,* ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យធ្វើការបំភ្លឺ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩, ឯកសារ **D198/1**, កថាខណ្ឌ ១០ ។

[57] បណ្ដឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ១៩ ។

[58] *សំណុំរឿងក្ដី នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវកត/កសចស,* ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យធ្វើការបំភ្លឺ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩, ឯកសារ **D198/1**, កថាខណ្ឌ ១០ ។

បឋម និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមនានា គឺដើម្បីធ្វើការជូនដំណឹង "ជាលម្អិតអំពីលក្ខណៈ និងហេតុផលនៃការចោទប្រកាន់" ដែលជនម្នាក់បានទទួលរងនូវការចោទប្រកាន់ប្រឆាំងនឹងខ្លួន[59] ។ ទាំងនេះគឺជាការអះអាងខុស ទាំងបញ្ហាអង្គច្បាប់ និងអង្គហេតុ ។

២៨. ទីមួយ ការអះអាងរបស់ សពអ ដែលថា សចស មិនបានចេញសេចក្ដីសម្រេចស្របគ្នា និងប្រកបដោយភាពច្បាស់លាស់លើបញ្ហានេះ គឺជាការអះអាងខុស ។ នៅពេលដែលអ្នកស្រី អ៊ឹម ចែម ត្រូវបានចោទប្រកាន់*ដោយកំបាំងមុខ* ពីសំណាក់អតីត សចស អន្តរជាតិ Harmon គាត់ក៏បានបញ្ជាក់យ៉ាងច្បាស់ថា *វាគឺ*ជាការជូនដំណឹងអំពីបទចោទប្រកាន់ ដែលជាមូលដ្ឋានក្នុងការផ្ដល់នូវព័ត៌មានលម្អិតទៅជនត្រូវចោទអំពីលក្ខណៈ និងមូលហេតុនៃការចោទប្រកាន់ដូចដែលបានថ្លែងដូចតទៅ៖

> ដើមហេតុ និងលក្ខណៈនៃបទចោទប្រកាន់ប្រឆាំងនឹង អ៊ឹម ចែម ព្រមទាំងព័ត៌មានលម្អិតផ្ទាល់ខ្លួនរបស់គាត់ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀត គឺមានបញ្ជាក់នៅក្នុងការជូនដំណឹងអំពីបទចោទប្រកាន់ដែលភ្ជាប់ជាមួយដីកាសម្រេចនេះ[60] ។

២៩. ទីពីរ ភស្តុតាងជាក់ស្ដែង គឺជាការអះអាងរបស់ សពអ ដែលបានលើកឡើងថា សចស មានកាតព្វកិច្ចវិនិច្ឆ័យលើអង្គហេតុនីមួយៗទាំងអស់ ដែលត្រូវបានប្ដឹងដោយត្រឹមត្រូវតាមនីតិវិធីច្បាប់ ទាំងទៅលើការចេញដីកាបញ្ជូនរឿងក្ដីទៅជំនុំជម្រះ ឬដីកាសម្រេចលើកលែងការចោទប្រកាន់ គឺជាការអះអាងខុស ។ កាតព្វកិច្ចដើម្បីដោះស្រាយលើអង្គហេតុពាក់ព័ន្ធនីមួយៗដែលទាក់ទងនឹងការចោទប្រកាន់ និងការចេញដីកាបញ្ជូនរឿងក្ដីទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់ កើតមានឡើងតែនៅពេលដែលបញ្ហាយុត្តាធិការត្រូវបានកំណត់ប៉ុណ្ណោះ ។

៣០. ដូចដែលបានពិគ្រោះខាងលើនៅក្នុងកថាខណ្ឌ១៧ ដល់កថាខណ្ឌ១៩ ការបង្កើតដែនយុត្តាធិការគឺជាបុរេលក្ខខណ្ឌមិនអាចខ្វះបានចំពោះតុលាការទាំងណា ដែលត្រូវធ្វើការសម្រេចអំពីសុពលភាពនៃរឿងក្ដីមួយ ។ អំណះអំណាងរបស់ សពអ គឺវាផ្ទុយទៅនឹងគោលការណ៍ជាមូលដ្ឋាននេះ ។ ការរកឃើញពីកង្វះយុត្តាធិការ និងការគ្មានសមត្ថកិច្ចលើរឿងក្ដី នឹងនាំឱ្យឈានដល់ការទម្លាក់

---

59 បណ្ដឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ២២ ។

60 ដីកាសម្រេចដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥, កថាខណ្ឌ ៧៥ ។

ចោលនូវបទចោទប្រកាន់ក្នុងសំណុំរឿងនេះដោយស្វ័យប្រវត្តិ ។ ដូច្នេះ វាបញ្ចៀសនូវតម្រូវការ និងកាតព្វកិច្ចក្នុងការវិនិច្ឆ័យសម្រេចលើ "អង្គហេតុទាំងអស់ដែល [សចស] ត្រូវបានប្ដឹងដោយត្រឹមត្រូវតាមនីតិវិធីច្បាប់ ទាំងការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់"[61] ។ អវត្តមាននូវការបង្ហាញឱ្យឃើញថា អ.វ.ត.ក មានយុត្តាធិការលើអ្នកស្រី អ៊ឹម ចែម ទាក់ទងនឹងបញ្ហាចោទលើអង្គហេតុនានា ដែលអាចបង្កើតបានជាបទប្រកាន់ដើម្បីបញ្ជូនរឿងក្ដីទៅជំនុំជម្រះនោះ គឺមិនបានកើតមានឡើងនោះទេ ។ ដូចដែលនឹងត្រូវធ្វើការលើកឡើងខាងក្រោម ទាក់ទងនឹងទឡ្ហីករណ៍ទី២ សពអ បរាជ័យក្នុងការចង្អុលបង្ហាញរបស់ខ្លួន ។

### *ii. សពអ បានបកស្រាយខុសលើសំអាងហេតុ ដែលថាក្រុមការពារក្ដីត្រូវបានគេជូនដំណឹងអំពីអង្គហេតុ ដែលអាចនាំឱ្យមានការបញ្ជូនរឿងទៅជំនុំជម្រះ*

៣១. សពអ បានលើកឡើងថា ក្រុមការពារក្ដីត្រូវបានជូនដំណឹងអំពីអង្គហេតុ ដែលអាចនាំឱ្យមានការចោទប្រកាន់តាមរយៈសិទ្ធិអាចពិនិត្យមើលបាននៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបឋម និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមនានា[62] ។ ទោះជាយ៉ាងណាក្ដី អំណះអំណាងនេះមិនយកចិត្តទុកដាក់ទាល់តែសោះចំពោះបញ្ហាវិវឌ្ឍន៍ទៅមុខដ៏សំខាន់មួយនៃសំណុំរឿងនេះ ពោលគឺនៅពេលដែលកិច្ចស៊ើបអង្កេតតាមផ្លូវតុលាការត្រូវបានបញ្ចប់ (នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ សម្រាប់សំណុំរឿង០០៤/១[63]) ។ អ្នកស្រី អ៊ឹម ចែម ត្រូវបានជូនដំណឹងថា វិសាលភាព និងការបញ្ជាក់ពីអង្គហេតុពាក់ព័ន្ធនានាដែលគួរជឿជាក់បាន នឹងត្រូវបានកំណត់នៅក្នុងសេចក្ដីជូនដំណឹងពីបទចោទប្រកាន់ និងមិនមែនជាការកំណត់ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបឋម និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមនោះទេ ។ អំណះអំណាងរបស់ក្រុមការពារក្ដីលើបញ្ហា

---

[61] *សំណុំរឿងក្ដី នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/កសចស,* ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យធ្វើការបំភ្លឺ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩, ឯកសារ **D198/1**, កថាខណ្ឌ ១០ ។

[62] បណ្ដឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ១៣ ។

[63] សេចក្ដីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំងនឹង អ៊ឹម ចែម ចេញនៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥, ឯកសារ **D285** ។

នេះត្រូវបានរៀបរាប់នៅក្នុងចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ[64] ។ កម្មវត្ថុ និងគោលបំណងនៃការជូនដំណឹងពីបទចោទប្រកាន់ គឺដើម្បីជូនដំណឹងដល់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេស គឺជូនដំណឹងជនសង្ស័យពីលក្ខណៈ និងបុព្វហេតុនៃការចោទប្រកាន់ ដែលមានការជាប់ទាក់ទង និងលទ្ធភាពដែលអាចនឹងឈានទៅរកការចោទប្រកាន់ ។

៣២. អាស្រ័យហេតុនេះ ការអះអាងរបស់ សពអ ដែលថាការដាក់សំណើសុំបំពេញកិច្ចស៊ើបអង្កេតសួរទាក់ទងនឹងទំនប់អាងទឹកត្រពាំងថ្ម នៅថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៥[65] គឺជាការបង្ហាញឱ្យឃើញពីការដឹងខ្លួនរបស់អ្នកស្រី អ៊ឹម ចែម ថាអ្នកស្រីអាចនឹងត្រូវបានបញ្ជូនទៅជំនុំជម្រះលើអង្គហេតុដែលអ្នកស្រីមិនត្រូវបានចោទប្រកាន់[66] គឺជាការអះអាងដោយការកាត់យល់ខុស ។ ទីមួយ សំណើទាក់ទងនឹងទំនប់អាងទឹកត្រពាំងថ្ម មិនមែនជាសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរនោះទេ[67] ។ វាផ្ទុយពីសំណើរបស់ សពអ សុំឱ្យដាក់ឯកសារចូលទៅក្នុងសំណុំរឿង០០៤/១ ដែលត្រូវបានចាត់ទុកថាជាសំណើសុំបំពេញកិច្ចស៊ើបសួរ[68] ទាក់ទងនឹងទំនប់អាងទឹកត្រពាំងថ្ម ត្រូវបានធ្វើឡើងក្នុងគោល

---

[64] ចម្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងអនកស្រី តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ធ្វើនៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦, ឯកសារ **D304/6** ត្រង់កថាខណ្ឌ ២០-២៩ ។ *សូមមើលផងដែរ*, ចម្លើយតបរបស់អ្នកស្រ អ៊ឹម ចែម ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ឆ្លើយតបនឹងដីកាសម្រេចបំបែកអ្នកស្រី អ៊ឹម ចែម ចេញពីសំណុំរឿង ០០៤ ធ្វើនៅថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០១៦, ឯកសារ **D300/1** ត្រង់កថាខណ្ឌ ២៦-២៧ ។ សំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម ស្នើសុំ (១) ចេញដីកាបង្គាប់ឱ្យដកព័ត៌មានចេញ ប្រឆាំងនឹងព័ត៌មានសង្ខេបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និង (២) ស្នើសុំសហចៅក្រមស៊ើបអង្កេតទាំងពីរចេញសេចក្តីថ្លែងការណ៍សាធារណៈរួមមួយ ធ្វើនៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦, ឯកសារ **D306** ត្រង់កថាខណ្ឌ ២៥ ។

[65] សំណើរបស់អ្នកស្រី អ៊ឹម ចែម ស្នើឱ្យដាក់បង្ហាញរាល់ប្រតិចារឹកនៃសំណុំរឿង ០០២ ដែលមិនមែនជាសំណៅកោសលុបព្រមទាំងឯកសារមួយចំនួនទៀតដែលពាក់ព័ន្ធនឹងអ្នកស្រី ធ្វើនៅថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៥, ឯកសារ **D283** ("សំណើទាក់ទងនឹងទំនប់អាងទឹងត្រពាំងថ្ម, ឯកសារ **D283**") ។

[66] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ១៤ *ផ្អែកលើ* សំណើទាក់ទងនឹងទំនប់អាងទឹងត្រពាំងថ្ម, ឯកសារ **D283** ។

[67] នៅក្នុងសំណើពាក់ព័ន្ធនឹងអាងទឹកត្រពាំងថ្ម ក្រុមការពារក្តីបានស្នើ សចស ឱ្យអនុញ្ញាតក្រុមការពារក្តីចូលពិនិត្យមើលសម្ភារៈតឹកតាង និងសុំឱ្យដាក់ប្រតិចារិកទាំងអស់ដែលពាក់ព័ន្ធអ្នកស្រី អ៊ឹម ចែម ទៅក្នុងសំណុំរឿង ០០៤ ។ *សូមមើល*, សំណើទាក់ទងនឹងអាងទឹកត្រពាំងថ្ម ឯកសារ **D283** ត្រង់ទំព័រ ៦ ។

[68] ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់ឯកសារចូលក្នុងសំណុំរឿង ០០៤/១ ចុះថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១៦, ឯកសារ **D300/2** ត្រង់កថាខណ្ឌ ៩ ["អង្គបុរេជំនុំជម្រះ ("អ.ប.ជ") ធ្លាប់បានសម្រេចថា សំណើសុំបង្គាប់ឱ្យ

បំណងអនុវត្តស្របគ្នានឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការអនុញ្ញាតឱ្យការិយាល័យសហចៅក្រមស៊ើបអង្កេត ចូលពិនិត្យមើលប្រតិចារឹកក្នុងសំណុំរឿង002 ទាំងអស់ដែលមានសំណៅជាឯកសារសម្ងាត់[69] ។

៣៣. ទីពីរ សំណើទាក់ទងនឹងទំនប់អាងទឹកត្រពាំងថ្មត្រូវបានដាក់នៅថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៥ បានធ្វើឡើងបីថ្ងៃមុនពេលបញ្ចប់កិច្ចស៊ើបសួរ[70] ជាពេលវេលាដែលអ្នកស្រី អ៊ឹម ចែម នៅតែអាចត្រូវបានទទួលរងនូវការចោទប្រកាន់ដោយ សចស សម្រាប់បទឧក្រិដ្ឋបន្ថែមទៀត (ដែលនៅទីបំផុតទៅក៏មិនត្រូវបានកំណត់នៅក្នុងសេចក្តីជូនដំណឹងអំពីបទចោទប្រកាន់) ។ ទោះបីជាយ៉ាងណាក្តី ក្រោយពីការបញ្ចប់កិច្ចស៊ើបសួរនៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥[71] សេចក្តីជូនដំណឹងអំពីការចោទប្រកាន់បានផ្តល់ព័ត៌មានចុងក្រោយដល់អ្នកស្រី អ៊ឹម ចែម ពីបទចោទប្រកាន់*ជាក់ស្តែង* និងការកំណត់នូវវិសាលភាពដែលមានសក្តានុពលមួយចំនួនក្នុងការបញ្ជូនទៅជំនុំជម្រះ ។ ដូចដែលបានសន្និដ្ឋានយ៉ាងត្រឹមត្រូវដោយ សចស ដូច្នេះថា ជនត្រូវចោទអាចត្រូវបានចោទប្រកាន់បញ្ជូនទៅជំនុំជម្រះតែចំពោះបទឧក្រិដ្ឋដែលគាត់ត្រូវបានចោទប្រកាន់ ហើយនិងបានជូនដំណឹងត្រឹមត្រូវប៉ុណ្ណោះ[72] ។ រាល់ការចោទប្រកាន់ពីបទឧក្រិដ្ឋទាំងឡាយណា ដែលស្ថិតនៅក្រៅការចោទប្រកាន់ដែលមានចុះនៅក្នុងសេចក្តីជូនដំណឹងអំពីបទចោទប្រកាន់ គឺលែងមានការជាប់ពាក់ព័ន្ធទៀតហើយ ឬក៏វាជាប្រធានបទនៃការរៀបចំការពារក្តី ។

---

ដាក់ឯកសារចូលក្នុងសំណុំរឿង គឺជាសំណើអនុលោមតាមវិធានផ្ទៃក្នុង ៥៥(១០) ពីព្រោះថាសំណើនេះតម្រូវឱ្យ ស.ច.ស វាយតម្លៃឯកសារនោះ ដើម្បីស្វែងរកភាពពាក់ព័ន្ធនឹងកិច្ចស៊ើបសួរ ហើយតាមគោលបំណងនៃសំណើបែបនេះ គឺដើម្បីបញ្ជាក់ពីការពិត"] ។

69 ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូង ទៅនឹងសំណើពីការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលបានស្នើសុំពិនិត្យប្រតិចារឹកសម្ងាត់នៃកិច្ចដំណើរការនីតិវិធីសវនាការលើសំណុំរឿង 002 ធ្វើនៅថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារ **D127/1** ។

70 *សូមមើល*, សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំងនឹង អ៊ឹម ចែម ចេញនៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥, ឯកសារ **D285** ។

71 សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំងនឹង អ៊ឹម ចែម ចេញនៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥, ឯកសារ **D285** ។

72 ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ២៤៥ ។

### *iii. "សិទ្ធិធ្វើសវនាការ" លើភស្តុតាងដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ អ្នកស្រី អ៊ីម ចែម និង "សិទ្ធិក្នុងការប្តឹងឧទ្ធរណ៍" លើការរកឃើញរបស់ សចស*

### *"សិទ្ធិធ្វើសវនាការ"*

៣៤. ការអះអាងរបស់ សពអ ដែលថា "គោលជំហររបស់ សចស បដិសេធដាច់អហង្ការចំពោះសិទ្ធិរបស់សហព្រះរាជអាជ្ញាដើម្បីធ្វើសវនាការលើភស្តុតាងស្តីពីការទទួលខុសត្រូវរបស់[អ្នកស្រី] អ៊ឹម ចែម សម្រាប់ឧក្រិដ្ឋកម្មទាំងនេះ"[73] គឺជាការប្តឹងតវ៉ាដែលគ្មានមូលដ្ឋានច្បាប់ ។ ដូចដែលបានចង្អុលបង្ហាញយ៉ាងត្រឹមត្រូវនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ សពអ ថា "វិធានផ្ទៃក្នុងមិនផ្តល់ឱកាសណាមួយដល់សហព្រះរាជអាជ្ញា ដើម្បីធ្វើសវនាការថាតើឧក្រិដ្ឋកម្មណាមួយដែល សចស នឹងបញ្ចូលទៅក្នុងសេចក្តីជូនដំណឹងអំពីបទចោទរបស់ពួកគេ អនុលោមតាមវិធាន៥៧ នៃវិធានផ្ទៃក្នុងទេ"[74] ។ គឺ សចស ជាអ្នកដែលមានកាតព្វកិច្ចស៊ើបអង្កេតលើរាល់អង្គហេតុទាំងឡាយដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបឋម និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ហើយមានអំណាចក្នុងការកំណត់ថាតើអង្គហេតុណាមួយ ដែលអាចជាមូលដ្ឋាននៃការចោទប្រកាន់[75] ដោយផ្អែកលើភស្តុតាងដែលមានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់គ្នា[76] ។ ស្របទៅនឹងគោលការណ៍

---

[73] បណ្តឹងឧទ្ធរណ៍ គ្រង់កថាខណ្ឌ ១៥ ។

[74] បណ្តឹងឧទ្ធរណ៍ គ្រង់កថាខណ្ឌ ១៥ ។

[75] *រឿងក្តី នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវកត/កសចស*, ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យធ្វើការបំភ្លឺ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩, ឯកសារ **D198/1**, កថាខណ្ឌ ១០ ។

[76] វិធាន ៥៥(៤) នៃវិធានផ្ទៃក្នុង ។ *សំណុំរឿងក្តី នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវកត/កសចស*, ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យធ្វើការបំភ្លឺ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩, ឯកសារ **D198/1**, កថាខណ្ឌ ១០ ["កាតព្វកិច្ចស៊ើបអង្កេតលើអង្គហេតុទាំងមូលដែលមាននៅក្នុងបណ្តឹង មិនត្រូវមានការភ័ន្តច្រឡំជាមួយនឹង "កាតព្វកិច្ចដាក់ឱ្យស្ថិតក្រោមការពិនិត្យ" បុគ្គលអំពីអង្គហេតុទាំងនេះនោះទេ ព្រោះកាតព្វកិច្ចចុងក្រោយនេះ មិនតម្រូវចំពោះចៅក្រមស៊ើបអង្កេតនោះឡើយ ។ ប្រសិនបើតម្រូវឱ្យចៅក្រមស៊ើបអង្កេតគោរពកាតព្វកិច្ចនេះ នោះវានឹងប៉ះពាល់ដល់ការបំពេញការងារក្នុងមុខងារជាចៅក្រមឯករាជ្យ ... ការដាក់ឱ្យស្ថិតក្រោមការពិនិត្យអាចធ្វើទៅបានចំពោះតែបុគ្គលដែលមានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា បុគ្គលនោះអាចជាអ្នកទទួលខុសត្រូវក្នុងការ

សមភាពក្នុងការតទល់ក្តី មិនថា សពអ ឬ ក្រុមការពារក្តីទេ មានសិទ្ធិធ្វើសវនាការមុនពេលមានការកំណត់លើបញ្ហាទាំងនេះដោយ សចស ។

៣៥. ការអះអាងរបស់ សពអ ដែលថាខ្លួនមិនត្រូវបានអញ្ជើញឱ្យចូលរួម "ស្តាប់សវនាការពេល [អ្នកស្រី អ៊ឹម ចែម] ត្រូវបានជូនដំណឹងអំពីបទចោទប្រកាន់"[77] គឺវាស្មើនឹងការអះអាងឥតប្រយោជន៍សម្រាប់ជាគោលការណ៍ ឬជាការអនុវត្តជាក់ស្តែង ។ អ្នកស្រី អ៊ឹម ចែម ត្រូវបានជូនដំណឹងអំពីការចោទប្រកាន់*ដោយកំបាំងមុខ* តាមរយៈការសម្រេចរបស់តុលាការ[78] ។ គ្មានសវនាការត្រូវបានធ្វើឡើងនោះទេ ។ ប្រសិនបើការចោទប្រកាន់ត្រូវបានកើតឡើងនៅក្នុងសវនាការនៃការបង្ហាញខ្លួនលើកដំបូង និងមិនមែន*តាមរយៈ* សេចក្តីសម្រេចរបស់តុលាការទេនោះ វិធានផ្ទៃក្នុង ៥៧ (គ្រប់គ្រងនីតិវិធីនៃការចោទប្រកាន់នៅពេលជនត្រូវចោទចូលបង្ហាញខ្លួនជាលើកដំបូង) មិនផ្តល់ឱកាសឱ្យ សពអ មានវត្តមាននៅក្នុងអំឡុងពេលនៃការចូលបង្ហាញខ្លួនលើកដំបូងនេះឡើយ ។ ការអនុវត្តរបស់ អ.វ.ត.ក អនុញ្ញាតឱ្យតែមេធាវីការពារក្តីរបស់ជនសង្ស័យប៉ុណ្ណោះ មានវត្តមានក្នុងអំឡុងពេលនៃការចោទប្រកាន់កូនក្តីរបស់ខ្លួន[79] ។

---

ប្រព្រឹត្តបទឧក្រិដ្ឋកម្ម ដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ [របស់ សពអ] ប៉ុណ្ណោះ"] ។ *រឿងក្តី នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/កសចស,* ដីកាសម្រេចបដិសេធការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យបន្ថែម ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១០, ឯកសារ **D298/2**, ត្រង់កថាខណ្ឌ ១៣ ["ការដាក់ឱ្យស្ថិតក្រោមការពិនិត្យ ... មិនមែនជាទម្រង់ការនីតិវិធីធម្មតាទេ ប៉ុន្តែជាសេចក្តីសម្រេចតុលាការមួយរបស់សហចៅក្រមស៊ើបសួរ នៅពេលណាដែលខ្លួនយល់ឃើញថាមានភស្តុតាងជាក់លាក់ និងស៊ីសង្វាក់ប្រឆាំងនឹងជនណាមួយ។ តាមសេចក្តីសម្រេចរបស់ខ្លួននេះ សហចៅក្រមស៊ើបអង្កេតត្រូវសម្រេចផងដែរអំពីពេលវេលាសមស្របដើម្បីដាក់ឱ្យស្ថិតក្រោមការពិនិត្យ និងវិសាលភាពនៃការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យនោះ" (លុបចោលសេចក្តីយោង) ]។

[77] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ១៥ ។

[78] *សូមមើល*, ដីកាសម្រេចចោទប្រកាន់ អ៊ឹម ចែម *ដោយកំបាំងមុខ*, **D239** ។

[79] *សូមមើលជាឧទាហរណ៍, រឿងក្តីរបស់ អោ អាន, សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩/អ.វ.ត.ក/កសចស,* កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ អោ អាន ធ្វើនៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥, ឯកសារ **D242** ត្រង់ទំព័រ ២ ។ *រឿងក្តីរបស់ យឹម ទិត្យ, សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩/អ.វ.ត.ក/កសចស,* កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ យឹម ទិត្យ ធ្វើនៅថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១៤, ឯកសារ **D281** ត្រង់ទំព័រ ១ ។ *រឿងក្តីរបស់ នួន ជា និងអ្នក*

៣៦. ទោះបីជាយ៉ាងណាក៏ដោយ នៅមុនពេលបញ្ចប់កិច្ចស៊ើបអង្កេតតាមផ្លូវតុលាការ សពអ អាចនឹងត្រូវបានដាក់សារណាឯករាជ្យដើម្បីបញ្ជាក់ពីជំហររបស់ខ្លួន ជាការតវ៉ាសុំឱ្យមានការកែតម្រូវនូវទម្រង់នៃការចោទប្រកាន់ ដោយរួមបញ្ចូលនូវភស្តុតាងជាមូលដ្ឋានសម្រាប់ធ្វើការស្នើសុំឱ្យមានការចោទប្រកាន់បន្ថែម ។ នេះគឺជាសកម្មភាពដែលត្រូវបានធ្វើឡើងដោយសហព្រះរាជអាជ្ញាក្នុងសំណុំរឿង០០២ ក្នុងការស្នើសុំទៅកាន់ សចស ឱ្យធ្វើការចោទប្រកាន់ ឌុច ពីបទឧក្រិដ្ឋកម្មមុននឹងធ្វើការចោទប្រកាន់មួយដែលអាចនឹងត្រូវបញ្ជូនសំណុំរឿងនេះទៅជំនុំជម្រះ[80] ។ ចំពោះហេតុផលដែលនៅតែមិនទាន់បានពន្យល់ គឺ សពអ បានបដិសេធមិនទទួលយកអត្ថប្រយោជន៍នៃនីតិវិធីនៃការការពារដ៏ជាក់លាក់នេះ ។

**"សិទ្ធិក្នុងការប្តឹងឧទ្ធរណ៍"**

៣៧. សពអ បានអះអាងថា "គ្មាន 'សេចក្តីសម្រេច' ណាមួយសម្រាប់សហព្រះរាជអាជ្ញា ដើម្បីប្តឹងឧទ្ធរណ៍ក្នុងពេលណាមួយនៅក្នុងអំឡុងនៃកិច្ចស៊ើបសួរ"[81] ដែលនេះ ជាការបដិសេធនូវសិទ្ធិរបស់ព្រះរាជអាជ្ញាក្នុងការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចមួយចំនួនរបស់ សចស ទាក់ទងនឹង "សំអាងហេតុនៃសេចក្តីសម្រេចណាមួយដែលមិនចោទប្រកាន់ចំពោះឧក្រិដ្ឋកម្ម ឬទម្រង់នៃការទទួលខុសត្រូវជាក់លាក់នោះ"[82] ។ ការប្តឹងតវ៉ានេះ គឺជាការតវ៉ាដែលគ្មានគុណវុឌ្ឍិទាំងស្រុង ។ សពអ ត្រូវបានជូនដំណឹងអំពីដីកាសម្រេចដាក់អ្នកស្រី អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ហើយដែលសេចក្តីសម្រេចនេះ អមជាមួយដោយសេចក្តីជូនដំណឹងអំពីបទចោទប្រកាន់

*ផ្សេងទៀត, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវកត/កសចស,* កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ អៀង សារី ធ្វើនៅថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៧, ឯកសារ **E3/92**, ត្រង់ទំព័រ ៤ ។

[80] *សូមមើល, រឿងក្តីរបស់ នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវកត/កសចស,* សំណើរបស់សហព្រះរាជអាជ្ញាសុំធ្វើសេចក្តីជូនដំណឹងអំពីបទចោទប្រកាន់ កាំង ហ្កេកអ៊ាវ ហៅ ឌុច ធ្វើនៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១០, ឯកសារ **D334**, ត្រង់កថាខណ្ឌ ១-៤ ។

[81] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ១៦ ។

[82] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ១៦ ។

លើសំណុំរឿង០០៤/១ ក្នុងពេលតែមួយជាមួយក្រុមការពារក្ដី[83] ។

៣៨. ទាំង សពអ និងក្រុមការពារក្ដីមានសិទ្ធិប្ដឹងឧទ្ធរណ៍ជំទាស់ទៅនឹងសេចក្ដីសម្រេចនេះដែលអនុញ្ញាតឱ្យធ្វើការតតាំងចំពោះភាពសមហេតុផលនៃការសម្រេចនេះ (ដែលមិនបានធ្វើការចោទប្រកាន់ទៅលើអង្គហេតុជាក់លាក់ណាមួយ) សម្រាប់ការពិភាក្សាដេញដោល ។ ក្រុមការពារក្ដីបានប្ដឹងឧទ្ធរណ៍ជំទាស់ទៅនឹងសេចក្ដីសម្រេចនេះ[84] ហើយ សពអ បានឆ្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍របស់យើង[85] ។ ហេតុនេះវាសបញ្ជាក់ឱ្យឃើញថា មិនមានឧបសគ្គទេ ទាំងតាមទិដ្ឋភាពគោលការណ៍ ឬការអនុវត្តរាំង សពអ មិនឱ្យធ្វើការបង្ហាញហេតុផលណាមួយ ដែលទាក់ទងនឹងភស្តុតាង ភាពអាចអនុវត្តទៅបានចំពោះការកំណត់លក្ខខណ្ឌលើ "ភស្តុតាងដែលមានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់" ក៏ដូចជាភាពសមស្របនៃការចោទប្រកាន់បន្ថែម ដោយផ្អែកលើអង្គហេតុពាក់ព័ន្ធ និងគួរជឿជាក់បាន ។ ការបរាជ័យក្នុងការទាញយកប្រយោជន៍ពីឱកាសទាំងនេះ មិនអាចបង្កើតជាមូលដ្ឋានសម្រាប់ការទាមទារថយក្រោយវិញ ស្ដីពីការរំលោភលើសិទ្ធិក្នុងការប្ដឹងឧទ្ធរណ៍បានទេ កុំថាឡើយវាបង្កើតឱ្យមានជាកំហុសអង្គច្បាប់ដែលមានលទ្ធភាពធ្វើឱ្យការរកឃើញរបស់ សចស លើបញ្ញាយុត្តាធិការបុគ្គលជាការរកឃើញគ្មានសុពលភាពនោះ ។

៣៩. យោងតាមការលើកឡើងខាងលើបង្ហាញឱ្យឃើញថា អំណះអំណាងរបស់ សពអ ទាក់ទងនឹងការអំណាចក្នុងការកាត់បន្ថយវិសាលភាពនៃការស៊ើបអង្កេតអនុលោមតាមវិធាន ៦៦ *ស្ទួន* គឺជាអំណះអំណាងដែលគ្មានភាពជាប់ពាក់ព័ន្ធទៅនឹងបញ្ហាកំពុងប្រឈម ។ ការតវ៉ារបស់ សពអ ដែលថា សចស "មិនអាចចេះតែទម្លាក់ចោលការស៊ើបអង្កេតលើអង្គហេតុនានាដែលពួកគេត្រូវបានប្ដឹង

---

[83] *សូមមើល,* ដីកាសម្រេចដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*, ឯកសារ **D239** ។ សេចក្ដីជូនដំណឹងពីបទចោទប្រកាន់, ឯកសារ **D239.1** ។

[84] បណ្ដឹងឧទ្ធរណ៍របស់[អ្នកស្រី] អ៊ឹម ចែម ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចដាក់អ្នកស្រីឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ធ្វើថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥, ឯកសារ **D239/1/2** ។

[85] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់[អ្នកស្រី] អ៊ឹម ចែម ប្រឆាំងនឹងដីកាសម្រេចដាក់ឱ្យគាត់ស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ធ្វើថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥, ឯកសារ **D239/1/6** ។

ដោយមិនមានការសុំយោបល់ពីសហព្រះរាជអាជ្ញា”[86] គឺជាការលើកឡើងមិនចំបញ្ហា ។ វិធាន៦៦ *ស្ទួន* ផ្តល់សិទ្ធិធ្វើការដេញដោលបានតាមកាលៈទេសៈជាក់លាក់មួយចំនួន រាប់បញ្ចូលទាំងករណីនៃការកាត់បន្ថយវិសាលភាពកិច្ចស៊ើបសួរ ។ ទោះបីជាយ៉ាងណាក្តី សចស មិនបានកាត់បន្ថយវិសាលភាពនៃការស៊ើបសួរនៅក្នុងសំណុំរឿងរបស់អ្នកស្រី អ៊ឹម ចែម ឡើយ ។ ការពិតដែលគ្រាន់តែថាអ្នកស្រី អ៊ឹម ចែម មិនត្រូវបានចោទប្រកាន់លើរាល់បទចោទទាំងអស់ដែលបានធ្វើនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបឋម និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមនោះ មិនមែនបានសេចក្តីថា សចស បានកាត់បន្ថយវិសាលភាពនៃការស៊ើបសួរ ដោយមិនទទួលយកយោបល់ពីភាគីនានាដូចដែលមានចែងក្នុងវិធាន៦៦ *ស្ទួន* នោះទេ ។ វាមានន័យយ៉ាងសាមញ្ញថា លក្ខខណ្ឌតម្រូវក្នុងការចោទប្រកាន់លើអង្គហេតុជាក់លាក់នានា មិនទាន់ត្រូវបានកំណត់ ។ ម្យ៉ាងវិញទៀត ដូចបានរៀបរាប់ខាងលើនៅក្នុងកថាខណ្ឌ៣៧ ដល់កថាខណ្ឌ៣៨ មានឱកាសបរិបូណ៌ព្រមទាំងនីតិវិធីនៃការការពារជាច្រើន ដែលអនុញ្ញាត សពអ បញ្ចេញយោបល់ និងតតាំងជាមួយនឹងការរកឃើញទាំងនោះ ។ មិនមែនទើបតែឥឡូវនេះទេ ដែល សពអ ស្រាប់តែធ្វើការប្តឹងឧទ្ធរណ៍ដោយផ្អែកលើការបរាជ័យមិនប្រើឱកាសដែលខ្លួនត្រូវប្រើកន្លងមកនោះ ។

## ខ. ឧទ្ធរណ៍ទី២÷ សចស គ្មានកំហុសអង្គច្បាប់ នៅក្នុងការអនុវត្តវិធីសាស្ត្រលើអង្គហេតុនានាដែលត្រូវបានប្តឹងទៅពួកគាត់ ប៉ុន្តែមិនត្រូវបានចោទប្រកាន់

៤០. ចាប់ពីកថាខណ្ឌ ២៣ ដល់កថាខណ្ឌ ៣៧ នៃបណ្តឹងឧទ្ធរណ៍ សពអ បានលើកឡើងថា សចស មានកំហុសលើអង្គច្បាប់ដោយសារតែមិនបានដោះស្រាយ “ការចោទប្រកាន់ជាច្រើន” ដែលជា “ឧក្រិដ្ឋកម្មដ៏សំខាន់ៗ” ដូចបានដាក់បង្ហាញជូននៅក្នុងដីកាសន្និដ្ឋានស្ពាព “ដែលត្រូវបានប្តឹងទៅ សចស នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបឋម និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់ សពអ ដែលមិនត្រូវបាន ‘ចោទប្រកាន់’ ដោយ សចស”[87] ។ សពអ បានកំណត់ប្រភេទអង្គហេតុចំនួនប្រាំដែលអ្នកស្រី អ៊ឹម ចែម មិនបានត្រូវបានចោទប្រកាន់ និងចោទជាបន្តថា

[86] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ១៧ ។

[87] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ២៣ ។

វាមិនត្រូវបានយកមកពិចារណា[88] ។ ទាំងនេះរួមមានដូចជា៖ i) ការបោសសម្អាតនៅភូមិភាគពាយព្យ ii) ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅទូទាំងតំបន់១៣ នៃភូមិភាគនិរតី និងតំបន់៥ នៃភូមិភាគពាយព្យ iii) ការធ្វើទុក្ខបុកម្នេញលើជាតិពន្ធុវៀតណាមនៅក្នុងតំបន់៥ iv) ឧក្រិដ្ឋកម្មប្រឆាំងនឹងខ្មែរក្រោមនៅក្នុងតំបន់១៣ នៃភូមិភាគនិរតី និង v) ឧក្រិដ្ឋកម្មជាច្រើនផ្សេងៗទៀតដែល សពអ បានប្ដឹងទៅ សចស[89] ។

៤១. ក្រុមការពារក្តីសូមស្នើថា ទឡ្ហីករណ៍ទី២ គឺជាទឡ្ហីករណ៍ដែលខុសទម្រង់ ។ សពអ ខកខានក្នុងការពិគ្រោះវែកញែកអំពីបទដ្ឋានត្រឹមត្រូវនៃបណ្ដឹងឧទ្ធរណ៍ដែលអាចអនុវត្តបាន ក្នុងការកំណត់យុត្តាធិការបុគ្គល និងខកខានមិនបានកំណត់ពីរបៀបដែលកំហុសផ្លូវច្បាប់ និងកំហុសអង្គហេតុដែលត្រូវបានចោទថាជាការរំលោភបំពានឆន្ទានុសិទ្ធិ ។ លើសពីនេះ ដូចដែលបានគូសបញ្ជាក់ខាងក្រោម ក្រុមការពារក្ដីយល់ឃើញថា i) សចស បានធ្វើការវាយតម្លៃត្រឹមត្រូវ និងបានពិចារណាលើរាល់អង្គហេតុទាំងអស់ ប្អូករួមទាំងអង្គហេតុនានាដែលត្រូវបានប្ដឹងទៅកាន់ពួកគាត់ និង ii) សចស បានធ្វើការពិចារណាសមហេតុផល និងបញ្ជាក់ដោយសំអាងហេតុជាក់ស្តែងដែលពាក់ព័ន្ធទាំងអស់ ក្នុងការកំណត់យុត្តាធិការបុគ្គល ។

### *i. សចស បានវាយតម្លៃត្រឹមត្រូវ និងបានធ្វើការពិចារណាលើអង្គហេតុទាំងអស់ ប្អូករួមទាំងអង្គហេតុទាំងឡាយណាដែលត្រូវបានប្ដឹង និងមិនមែនគ្រាន់តែពិចារណាលើអង្គហេតុដែលបានចោទប្រកាន់នោះទេ*

៤២. ដូចដែលបានទទួលយកដោយសហព្រះរាជអាជ្ញាក្នុងសំណុំរឿង០០២[90] រួចមកហើយថា វិធានផ្ទៃ

---

[88] *សូមមើល*, បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ២៣, *យោងលើ* ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ២៤៦ ។

[89] *សូមមើល*, បណ្ដឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ២៣ ។ *សូមមើលផងដែរ*, បណ្ដឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ២៤-៣៧ ។

[90] *រឿងក្ដីរបស់ នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ ៧១)*, ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់ កសចស បដិសេធមិនទទួលយកចម្លើយតបរបស់មេធាវីការពារក្ដីទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងសំណើសុំផ្អាកដំណើរការនីតិវិធី ចុះថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារ **D390/1/2/2**, ត្រង់កថាខណ្ឌ ២ ["ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម គឺជាអនុសាសន៍

ក្នុង៦៧(៣) ចែងថា សចស មិនជាប់កាតព្វកិច្ចធ្វើតាមសារណារបស់សហព្រះរាជអាជ្ញាឡើយ នៅពេលធ្វើដីកាដំណោះស្រាយ ។ ដរាបណាមិនមានការចង្អុលបង្ហាញឱ្យឃើញថា សចស មិនបានយកចិត្តទុកដាក់ទាល់តែសោះលើរាល់បំណែកនៃភស្តុតាងជាក់លាក់ណាមួយ នោះនឹងគ្មានការតម្រូវឱ្យពួកគាត់ធ្វើការបញ្ជាក់ពីការកំណត់លើបញ្ហាទាក់ទងនឹងការចោទប្រកាន់នីមួយៗ របស់ សពអ នោះទេ ហើយពួកគាត់គ្មានកាតព្វកិច្ចក្នុងការយោងទៅលើរាល់អង្គហេតុ ឬគ្រប់បំណែកនៃភស្តុតាងនោះដែរ[91] ។ អង្គជំនុំជម្រះមិនត្រូវបានតម្រូវឱ្យអនុវត្តតាមយន្តការវិធីសាស្ត្រ នៅគ្រប់អំណះអំណាងដែលបានលើកឡើងដោយភាគីណាមួយនោះទេ[92] ។

៤៣. ដូចដែលបានជូនដំណឹងដល់ភាគីនានាជាច្រើនលើកច្រើនសាររួចមកហើយថា បញ្ហាសំខាន់នៅក្នុង

---

កំណត់ពីបរិបទខាងអង្គហេតុនៃកិច្ចស៊ើបសួរ ហើយ*ដីកាសន្និដ្ឋានស្ថាពរ មានផ្ទុកអនុសាសន៍ទាំងឡាយដែលមិនចងកាតព្វកិច្ចចំពោះសហចៅក្រមស៊ើបអង្កេតទេ*” (សង្កត់ន័យបន្ថែមត្រង់អក្សរទ្រេត)] ។ ត្រង់កថាខណ្ឌ ៧ [“វិធាន៦៦ និង ៦៧ បង្កើតជានីតិវិធីដែលនៅចុងបញ្ចប់នៃការស៊ើបសួរ គេតម្រូវឱ្យសហព្រះរាជអាជ្ញាដាក់ដីកាសន្និដ្ឋានស្ថាពរមួយ ហើយ បន្ទាប់ពីនោះ *សហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយរបស់ខ្លួនដោយឯករាជ្យ គឺមិនជាប់កាតព្វកិច្ចធ្វើ តាមដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាទេ*” (សង្កត់ន័យបន្ថែមត្រង់អក្សរទ្រេត)] ។

91 *រឿងក្តីរបស់ Prosecutor ទល់នឹង Momčilo Krajišnik*, រឿងក្តីលេខ (IT-00-39-A), អង្គជំនុំជម្រះសាលាឧទ្ធរណ៍, សាលដីកា ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩, ត្រង់កថាខណ្ឌ ១៩ **[ភ្ជាប់ជាឯកសារសម្អាង៖ ១១]**។

92 *សូមមើល, រឿងក្តីរបស់ នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿងលេខ 002/19-09-2007/អ.វ.ត.ក/អ.ជ.ត.ក, សាលដីកាអង្គជំនុំជម្រះតុលាការកំពូល* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦, ឯកសារ **F36**, (“សាលដីកាតុលាការកំពូលក្នុងសំណុំរឿង 002/1, **F36**”) ត្រង់កថាខណ្ឌ ២០៧, *ដកស្រង់ចេញពី, រឿងក្តី Van de Hurk ទល់នឹង The Netherlands* (ពាក្យសុំលេខ: 16034/90), តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECtHR), សាលក្រម ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៤, ត្រង់កថាខណ្ឌ ៦១ [“មាត្រា ៦ កថាខណ្ឌ ១ [នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស] បានតម្រូវឱ្យតុលាការផ្តល់សំអាងហេតុសម្រាប់សេចក្តីសម្រេចរបស់ខ្លួន ប៉ុន្តែពុំចាំបាច់តម្រូវឱ្យមានព័ត៌មានពិស្តារចំពោះរាល់អំណះអំណាងនោះឡើយ”] **[ភ្ជាប់ជាឯកសារសម្អាង៖ ២៨]**។ *រឿងក្តី García Ruiz ទល់នឹង Spain* (ពាក្យសុំលេខ: 30544/96), តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECtHR), ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៩, សាលក្រមរបស់អង្គជំនុំជម្រះជាន់ខ្ពស់ ត្រង់កថាខណ្ឌ ២៦ **[ភ្ជាប់ជាឯកសារសម្អាង៖ ៣០]**។ ខែ *Helle ទល់នឹង Finland* (ពាក្យសុំលេខ: 157/1996/776/977), តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECtHR), សាលក្រម ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧, ត្រង់កថាខណ្ឌ ៥៥ **[ភ្ជាប់ជាឯកសារសម្អាង៖ ២៩]**។

សំណុំរឿង០០៤/១ គឺជាបញ្ហាយុត្តាធិការបុគ្គល[93] ។ ក្រៅពីការពិតដែល សចស បានសន្និដ្ឋានថា ស្ដីពីការចោទប្រកាន់ទាំងឡាយទាក់ទងនឹងអង្គហេតុដែលអ្នកស្រី អ៊ឹម ចែម មិនត្រូវបានចោទប្រកាន់នោះ គឺវា "ពុំចាំបាច់...ពិនិត្យមើលលម្អិតថាតើវិសាលភាពនៃភស្តុតាងអង្គហេតុណាមួយ ដែលពុំបានដាក់ឱ្យស្ថិតក្រោមការពិនិត្យ[អ្នកស្រី] អ៊ឹម ចែម អាចត្រូវបានប្រើសម្រាប់ការសម្រេចលើយុត្តាធិការបុគ្គលនោះទេ"[94] ដោយពួកគាត់បានពិនិត្យពិចារណារ និងបានសន្និដ្ឋានយ៉ាងច្បាស់ថា អង្គហេតុទាំងនេះ មិនប៉ះពាល់ឡើយដល់ដីកាដំណោះស្រាយ[95] ។ ហេតុដូច្នេះ វាមិនមានគុណវុឌ្ឍិអ្វីឡើយក្នុងការអះអាងថា សចស មិនបានធ្វើការវាយតម្លៃលើរាល់អង្គហេតុទាំងអស់ដែលមាននោះ ។

៤៤. ការពិតដែលថា សចស បានជ្រើសយកការថ្លឹងថ្លែងលើអង្គហេតុដែលមិនបានចោទប្រកាន់ មិនមែនបានសេចក្ដីថាវាបានបង្កើតនូវកាតព្វកិច្ចណាមួយក្នុងការផ្ដល់នូវសំអាងហេតុពិស្ដារ ទាក់ទងនឹងសំណុំនៃឧក្រិដ្ឋកម្មនីមួយៗឡើយ ។ ម្យ៉ាងវិញទៀត ដូចដែលបានលើកឡើងខាងក្រោមនេះ សចស បានផ្ដល់នូវយោបល់ក្នុងសំអាងហេតុដែលបានបំពេញក្នុងតម្រូវការពាក់ព័ន្ធទាំងអស់សម្រាប់ដំណើរការនីតិវិធីដ៏ត្រឹមត្រូវមួយ ។

### *ii. សចស បានពិចារណាយ៉ាងត្រឹមត្រូវអំពីអង្គហេតុទាំងអស់ដែលមានភាពពាក់ព័ន្ធ និងបានច្រានចោលនូវរាល់អង្គហេតុទាំងឡាយណាដែលគ្មានការជាប់ពាក់ព័ន្ធក្នុងការកំណត់លើយុត្តាធិការបុគ្គល*

៤៥. អំណះអំណាងរបស់ សពអ គឺមានមានវិការៈ ។ នៅក្រោមអនុទទ្បីករណ៍នីមួយៗ សពអ អះអាងថា មានសម្ភារៈតឹកតាងមួយចំនួនគឺមិនត្រូវបាន សចស យកមកពិនិត្យពិចារណា ប៉ុន្តែ សពអ មិន

---

[93] សេចក្ដីជូនដំណឹងអំពីគោលបំណងលើកលែងការចោទប្រកាន់ប្រឆាំង អ៊ឹម ចែម និងបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំងគាត់ ចុះនៅថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ២០១៥, ឯកសារ **D286** នៅកថាខណ្ឌ ៥ ។ សេចក្ដីជូនដំណឹងមេធាវីការពារក្ដីអំពីកាលបរិច្ឆេទកំណត់ក្នុងការឆ្លើយតបទៅនឹងដីកាសន្និដ្ឋាន[ស្ថាពរ]តាមវិធាន ៦៦(៥) របស់សហព្រះរាជអាជ្ញា ធ្វើនៅថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១៦, ឯកសារ **D304/4** នៅកថាខណ្ឌ ៦ ។

[94] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ២៤៦ ។

[95] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ២៤៦ ។

បានជជែកវែកញែកឡើយអំពីរបៀបល្មើសទៅនឹងឆន្ទានុសិទ្ធិដែលបានចោទប្រកាន់នេះ ថាវាបានបង្កឱ្យមានការរំលោភនូវឆន្ទានុសិទ្ធិដូចម្តេចខ្លះ ។

**ការចោទប្រកាន់ទាក់ទងទៅនឹងភូមិភាគនិរតី**

៤៦. សពអ បានអះអាងថា សចស មានកំហុសអង្គច្បាប់ដោយមិនបានពិចារណាលើការចោទប្រកាន់ទាក់ទងនឹង i) ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងតំបន់១៣ នៃភូមិភាគនិរតី[96] និង ii) ឧក្រិដ្ឋកម្មប្រឆាំងនឹងខ្មែរក្រោម កើតឡើងនៅក្នុងតំបន់១៣ នៃភូមិភាគនិរតី[97]។ ទោះជាយ៉ាងណាក្តី ការពិនិត្យមើលក្នុងដីកាដំណោះស្រាយបង្ហាញឱ្យឃើញថា សពអ មិនត្រឹមតែមិនយកចិត្តទុកដាក់លើការសំអាងហេតុដ៏សាមញ្ញដូចដែលបានរៀបរាប់ខាងលើនៅកថាខណ្ឌ៤២ ដល់កថាខណ្ឌ៤៣ ប៉ុណ្ណោះទេ ថែមទាំងមិនធ្វើការបង្ហាញពីកំហុសឆ្គងណាមួយ ដែលបង្កឱ្យមានការរំលោភបំពានលើឆន្ទានុសិទ្ធិទៀតផង ។

៤៧. ជាបឋម សចស បានវាយតម្លៃភស្តុតាងពាក់ព័ន្ធនឹងតួនាទី និងសិទ្ធិអំណាចរបស់អ្នកស្រី អ៊ឹម ចែម នៅក្នុងភូមិភាគនិរតី ។ សចស បានវាយតម្លៃ និងផ្តល់ការវិភាគយ៉ាងពិស្តារ អំពីការចោទប្រកាន់របស់ សពអ ហើយបានសន្និដ្ឋានថាតួនាទីរបស់អ្នកស្រី អ៊ឹម ចែម នៅក្នុងភូមិភាគនិរតីត្រូវបានកម្រិតត្រឹមជាលេខាសមាគមនារីនៃតំបន់១៣[98] ។ នៅក្នុងតួនាទីនេះ អ្នកស្រី "ទទួលខុសត្រូវលើការអប់រំនយោបាយដល់ស្ត្រីនៅតាមស្រុកក្នុងតំបន់១៣"[99] ។ ដោយផ្អែកលើការរកឃើញនេះ សចស បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា អ្នកស្រី អ៊ឹម ចែម មិនមានសិទ្ធិពាក់ព័ន្ធនឹងការធ្វើសេចក្តីសម្រេចនានាក្នុងស្រុកកោះអណ្តែត និងនៅក្នុងតំបន់១៣ នោះទេ[100] ដែលហេតុផលលម្អិតនឹងត្រូវបានបង្ហាញនៅក្រោមទទ្លីករណ៍ទី៥ និងទទ្លីករណ៍ទី៦[101] ។ ពួកគាត់បានសន្និដ្ឋានបន្ថែមទៀតថា

---

[96] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ២៧-២៨ ។

[97] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣៣-៣៤ ។

[98] *សូមមើល*, ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១៤៣-១៥០ ។

[99] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១៤៣, ១៥០ ។

[100] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១៤៣ ។

[101] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ២៤៧ ។

មិនមានភស្តុតាងណាមួយដែលបង្ហាញឱ្យឃើញពីការជាប់ពាក់ព័ន្ធរបស់អ្នកស្រី អ៊ឹម ចែម ជាមួយប្រតិបត្តិការនៅវត្តអង្គសិរីមាលី និងវត្តព្រៃសុខុនឡើយ ដែលទាំងពីរនេះ គឺជាទីតាំងឧក្រិដ្ឋកម្មស្ថិតនៅក្នុងភូមិភាគនិរតី[102] ។

៤៨. ដោយយោងតាមការរកឃើញដែលថាអ្នកស្រី អ៊ឹម ចែម មិនបានពាក់ព័ន្ធក្នុងការធ្វើសេចក្តីសម្រេចនានានៅភូមិភាគនិរតី ទើបបានជា សចស មិនត្រូវបានតម្រូវឱ្យធ្វើការវាយតម្លៃលម្អិតលើភស្តុតាងពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទថាបានប្រព្រឹត្តទៅនៅក្នុងភូមិភាគនិរតី ក៏ដូចជាភស្តុតាងទាក់ទិននឹងការចោទប្រកាន់ទាំងឡាយណាដែលអ្នកស្រី អ៊ឹម ចែម មិនត្រូវបានចោទប្រកាន់ (ដូចជា៖ អាពាហ៍ពិពាហ៍បង្ខំនៅក្នុងតំបន់១៣ និងឧក្រិដ្ឋកម្មប្រឆាំងនឹងខ្មែរក្រោមនៅក្នុងតំបន់១៣) ។ យ៉ាងណាក៏ដោយចុះ ក្រុមការពារក្តីសូមផ្តល់នូវការវិភាគជាសង្ខេបទៅលើអំណះអំណាងរបស់ សពអ ដើម្បីបង្ហាញឱ្យឃើញបន្ថែមទៀតពីការខ្វះនូវគុណវុឌ្ឍិនៅក្នុងអំណះអំណាងរបស់ សពអ ដែលដាក់គាំទ្រនៅក្រោមទទ្បីករណ៍នានានៃបណ្តឹងឧទ្ធរណ៍ ។

- ***អាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងតំបន់១៣***

៤៩. សពអ បានអះអាងថា សចស ខកខានមិនបានត្រិះរិះលើភស្តុតាងនៃការទទួលខុសត្រូវរបស់អ្នកស្រី អ៊ឹម ចែម ចំពោះការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងតំបន់១៣ នៃភូមិភាគនិរតី[103] ។

៥០. ទោះជាយ៉ាងណា សំណុំរឿងទាំងមូលរបស់ព្រះរាជអាជ្ញាទាក់ទងនឹងការចោទប្រកាន់អំពីទំនួលខុសត្រូវរបស់អ្នកស្រី អ៊ឹម ចែម ពាក់ព័ន្ធនឹងការរៀបការដោយបង្ខំនៅភូមិភាគនិរតីបានកើតចេញពីការថ្លែងចោទតែមួយគត់ ដែលជាការថ្លែងគ្មានភស្តុតាងគាំទ្រ ដោយយោងតាមការលើកឡើងថាអ្នកស្រីបានជំរុញឱ្យនារីៗរៀបការជាមួយ "យុវជនដែលត្រូវរៀបការជាមួយពួកគាត់ ភាគច្រើនជាយុវជនពិការជើង"[104] ។

---

[102] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ២៤៧, ២៥១ ។

[103] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ២៧-២៨ ។

[104] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ២៧ *យោងលើ* ដីកាសន្និដ្ឋានស្ថាពរ ឯកសារ **D304/2** ត្រង់កថាខណ្ឌ ១៣៤ (*យោងលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ រុំ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤, ឯកសារ **D119/108** ត្រង់ចម្លើយ A108 ។

៥១. ទីមួយ ដោយសារវាមិនពាក់ព័ន្ធនឹងព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងតំបន់១៣ នៃភូមិភាគនិរតី ប៉ុន្តែនៅស្វាយ[ស៊ីសុផុន]ក្នុងភូមិភាគពាយព្យ[105] ។ ទីពីរ ទោះបីជាវាជាប់ពាក់ព័ន្ធក៏ដោយ ក៏ភស្តុតាងដូច្នេះ មិនអាចមានគុណសម្បត្តិប្រកបដោយអត្ថន័យណាមួយដែលមានភាពជាប់ពាក់ព័ន្ធ ឬក៏ជាភស្តុតាងដែលមានភាពអាចជឿជាក់បាននោះឡើយ ។ វាជាភស្តុតាងចចាមអារ៉ាម ដែលគ្មានប្រភព និងការបញ្ជាក់បន្ថែម[106] ។ ប្រសិនបើការចោទប្រកាន់ទាំងនេះ ត្រូវបានចោទ ប្រកាន់វិញនោះ អង្គជំនុំជម្រះមានហេតុផលទាំងអស់ អាចមានភារកិច្ចមិនផ្តល់ទម្ងន់លើភស្តុតាង ប្រភេទនេះ ។ សពអ ខកខានក្នុងការបង្ហាញឱ្យឃើញពីរបៀបដែលភស្តុតាងមានភាព "ជាប់ពាក់ព័ន្ធច្បាស់លាស់" ឬរបៀបធ្វើការច្រានចោលនៃភស្តុតាងដោយសារមានការរំលោភឆន្ទានុសិទ្ធិ ។

- ***ឧក្រិដ្ឋកម្មនានាប្រឆាំងនឹងខ្មែរក្រោម***

៥២. ការចោទប្រកាន់ថាឧក្រិដ្ឋកម្មប្រឆាំងនឹងខ្មែរក្រោមគួរតែត្រូវបានពិចារណាដោយ សចស ផ្អែកលើការអះអាងជាសំខាន់របស់ សពអ ដែលថា៖ i) សចស បានកត់សម្គាល់ថា "ខ្មែរក្រោម គឺជាក្រុមធំមួយដែលបានជាប់ឃុំនៅវត្តអង្គសេរីមាលី និងបានយកទៅសម្លាប់នៅព្រៃសុខុនជាទៀងទាត់" [107] និង ii) អ្នកស្រី អ៊ឹម ចែម គឺជាលេខាស្រុកកោះអណ្តែត ហើយទីតាំងឧក្រិដ្ឋកម្មទាំងពីរ គឺស្ថិតក្នុងស្រុកនេះ[108] ។

៥៣. ដូចដែលបានកត់សម្គាល់ខាងលើនៅកថាខណ្ឌ៤៧ ហើយបានលម្អិតការឆ្លើយតបទៅនឹងទឡ្ហីករណ៍ទី៥ សចស បានរកឃើញថា អ្នកស្រី អ៊ឹម ចែម មិនមែនជាលេខាស្រុកកោះអណ្តែត និងក៏មិនមាន

---

105 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ រុំ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤, ឯកសារ **D119/108** ត្រង់សំណួរ និងចម្លើយ A108 ["ស៖ ពេលនៅ*ស្វាយ* តើលោកស្រីធ្លាប់បាចូលរួមប្រជុំដែរឬទេ? ឆ៖ ខ្ញុំមិនបានចូលរួមប្រជុំទេ។ បងៗនារីបានចូលរួមប្រជុំជាមួយយាយចែមនៅស្វាយ ។ នៅក្នុងកិច្ចប្រជុំ យាយចែម តែងតែនិយាយជំរុញឱ្យបងៗនារីរៀបការ... "]។

106 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ រុំ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤, ឯកសារ **D119/108** ត្រង់ចម្លើយ A108-09 ។

107 បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣៣ *យោងពី* កថាខណ្ឌ ២៤៨ នៃដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ២៤៨ ។

108 បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣៣ ។

អំណាចប្រតិបត្តិនៅក្នុងតំបន់នោះដែរ[109] ។ ជាងនេះទៅទៀត ខណៈដែល សចស ពិតជាបានចាត់ទុកថា "ខ្មែរក្រោម គឺជាក្រុមធំមួយដែលបានជាប់ឃុំនៅវត្តអង្គសេរីមាលី និងបានយកទៅសម្លាប់នៅព្រៃសុខុនជាទៀងទាត់"[110] សចស ក៏បានរកឃើញដែរថា ពុំមានភស្តុតាងណាបញ្ជាក់បានថាអ្នកស្រី អ៊ឹម ចែម ជាប់ពាក់ព័ន្ធជាមួយនឹងទីតាំងឧក្រិដ្ឋកម្មទាំងនេះទេ[111] ។ ដោយហេតុនេះសារណារបស់ សពអ ជាសារណាដែលគ្មានមូលដ្ឋាន និងធ្វើឡើងដោយការគិតខុសទាំងស្រុង ។

## ការចោទប្រកាន់ទាក់ទងនឹងអង្គហេតុនៅក្នុងតំបន់ភូមិភាគពាយព្យ

៥៤. សពអ បានអះអាងថា សចស មានកំហុសអង្គច្បាប់ដោយមិនបានពិចារណាលើការចោទប្រកាន់ និងអំណះអំណាងមួយចំនួនទាក់ទងនឹង i) ការបោសសម្អាតនៅភូមិភាគពាយព្យ ii) ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅតំបន់៥ នៃភូមិភាគពាយព្យ iii) ការធ្វើទុក្ខបុកម្នេញលើជាតិពន្ធុវៀតណាមនៅក្នុងតំបន់៥ iv) "ឧក្រិដ្ឋកម្មជាច្រើនផ្សេងៗទៀត" ដែល សពអ បានប្តឹង[112] ។

- ***ការបោសសម្អាតនៅក្នុងភូមិភាគពាយព្យ***

៥៥. តាមរយៈការអានដីកាដំណោះស្រាយបង្ហាញឱ្យឃើញថា សចស បានពិនិត្យមើលភស្តុតាងទាក់ទងនឹងការទទួលខុសត្រូវរបស់អ្នកស្រី អ៊ឹម ចែម ដែលត្រូវបានចោទប្រកាន់ថាបានជាប់ពាក់ព័ន្ធនឹងការបោសសម្អាតនៅភូមិភាគពាយព្យដ៏យូរ[113] ។ ពួកគាត់បានវាយតម្លៃលើការពិចារណាពាក់ព័ន្ធទាំងអស់ រួមទាំងទំនាក់ទំនងរបស់អ្នកស្រីជាមួយ តាម៉ុក[114] និងតួនាទីរបស់អ្នកស្រី[115] ។ ផ្ទុយពីការ

---

[109] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១៤៣, ២៤៧ ។

[110] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣៣ *យោងពី* កថាខណ្ឌ ២៤៩ នៃដីកាដំណោះស្រាយ, ឯកសារ **D308/3** ។

[111] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ២៥១ ។

[112] *សូមមើល*, បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ២៣ ។ *សូមមើលផងដែរ*, បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ២៤-៣៧ ។

[113] *សូមមើល*, ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ២៥១-១៥៥ ។

[114] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ២៨៤ ។ *សូមមើលផងដែរ*, ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ២៥១ ["តាម៉ុកដែលជាលេខាភូមិភាគនិរតី បានបញ្ជូនកម្មាភិបាលជាច្រើនក្រុមពីភូមិភាគនិរតីឱ្យទៅជំនួសកម្មាភិបាលមូលដ្ឋាននៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលនៃភូមិភាគពាយព្យ"] ។ ត្រង់កថាខណ្ឌ ១៥២ ["តាម៉ុក បាន

អះអាងរបស់ សពអ សចស មិនបានសន្និដ្ឋានថាអ្នកស្រី អ៊ឹម ចែម "បានដឹកនាំ និងចូលរួមក្នុងអ្វីដែល សចស រៀបរាប់ថាជា "ការងារសម្រេចសម្រួលដ៏សំខាន់" ដែលជាការបោសសម្អាតភូមិភាគពាយព្យ" នោះទេ[116] ។ នៅកម្រិតខ្ពស់បំផុត គឺ សចស បានរកឃើញថា អ្នកស្រីបានដឹកនាំការ*ផ្ទេរ*កម្មាភិបាលភូមិភាគនិរតីទៅកាន់ភូមិភាគពាយព្យ[117] ។

៥៦. ដោយបានច្រានចោលការអះអាងថាអ្នកស្រីបានដើរតួនាទីយ៉ាងសំខាន់ នៅក្នុងឧក្រិដ្ឋកម្មទាំងនោះ ព័ត៌មាន*ពិស្តារ*នៃឧក្រិដ្ឋកម្ម (ផ្ទុយទៅនឹងចរិតលក្ខណៈសំខាន់ៗនៃឧក្រិដ្ឋកម្មទាំងនោះ និងចំណងទំនាក់ទំនងទៅអ្នកស្រី អ៊ឹម ចែម) គឺពាក់ព័ន្ធតិចតួចណាស់ក្នុងការកំណត់យុត្តាធិការបុគ្គល ។ ហេតុដូច្នេះ សពអ មិនត្រឹមតែបង្ហាញខុសពីដីកាដំណោះស្រាយតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងខកខានមិនបានបង្ហាញឱ្យឃើញពីការមានកំហុសអង្គច្បាប់ ឬការរំលោភឆន្ទានុសិទ្ធិ ។

- ***ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅតំបន់៥***

៥៧. សពអ បានអះអាងថា សចស មិនបានពិចារណាលើភស្តុតាងនៃការទទួលខុសត្រូវរបស់អ្នកស្រី អ៊ឹម ចែម ចំពោះការបង្ខំឱ្យរៀបការ[118] នៅទីតាំងឧក្រិដ្ឋកម្មមួយចំនួនដែលត្រូវបានចោទប្រកាន់ថាស្ថិតនៅក្រោមសិទ្ធិអំណាចរបស់អ្នកស្រី អ៊ឹម ចែម បូករួមទាំងនៅការដ្ឋានស្ពានស្រែង[119] និងទំនប់អាងទឹកត្រពាំងថ្ម[120] ក្នុងភូមិភាគពាយព្យ ។

៥៨. ទាក់ទងនឹងការដ្ឋានស្ពានស្រែង ដំបូង សពអ យោងទៅកថាខណ្ឌ ២៦៩ នៃដីកាសន្និដ្ឋានស្ថាពររបស់គាត់ ដោយដកស្រង់ការលើកឡើងរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

---

បញ្ជូនកម្មាភិបាលភូមិភាគនិរតីទៅភូមិភាគពាយព្យបីដង"] ។ កថាខណ្ឌ ១៥៣ ["តាម៉ុក បានចាត់តាំងកងទ័ពភូមិភាគនិរតីឱ្យធ្វើការបោសសម្អាតកម្មាភិបាលភូមិភាគពាយព្យ"] ។ ត្រង់កថាខណ្ឌ ២៥៤ ["តាម៉ុក បានបោសសម្អាត"] ។

[115] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ២៥២-១៥៣, កថាខណ្ឌ ១៥៦, និង ៣១៦ ។

[116] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ២៤ ។ *សូមមើលផងដែរ*, បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ២៦ ។

[117] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១៥២, ១៥៦, និង ៣១៦ ។

[118] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ២៧-២៨ ។

[119] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ២៧ *យោងពី* ដីកាសន្និដ្ឋានស្ថាពរ, ឯកសារ **D304/2** ត្រង់កថាខណ្ឌ ២៦៩ ។

[120] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ២៧ *យោងពី* ដីកាសន្និដ្ឋានស្ថាពរ, ឯកសារ **D304/2** ត្រង់កថាខណ្ឌ ២៨៨ ។

តែម្នាក់គត់ឈ្មោះ សែន សុផុន ដើម្បីគាំទ្រការអះអាងថាអាពាហ៍ពិពាហ៍ដោយបង្ខំបានកើតឡើងនៅទីតាំងឧក្រិដ្ឋកម្ម[121] ។ ការពិនិត្យមើលឡើងវិញនូវភស្តុតាងដែលផ្តល់ដោយ សែន សុផុន បង្ហាញឱ្យឃើញថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ មិនបានចោទប្រកាន់អ្នកស្រី អ៊ឹម ចែម ថាអ្នកស្រីបានចូលរួមក្នុងពិធីអាពាហ៍ពិពាហ៍ដោយបង្ខំនោះទេ[122] ហើយសាក្សីបានចង្អុលបង្ហាញថា "មិនដឹងរឿងច្រើនពីគាត់ទេ" នៅពេលសួរអំពីអ្នកស្រី អ៊ឹម ចែម[123] ។

៥៩. ទាក់ទងនឹងទំនប់អាងទឹកត្រពាំងថ្ម សចស បានរកឃើញថា ខណៈពេលដែលអ្នកស្រី អ៊ឹម ចែម បានទៅមើលទីតាំងនេះ "វិសាលភាពនៃការចូលរួម និងសិទ្ធិអំណាចរបស់គាត់ទៅលើគម្រោងសាងសង់នោះ គឺមិនច្បាស់លាស់" នោះទេ[124] ។ សពអ មិនបានជំទាស់ទេត្រង់ចំណុចនេះ ។ ដោយហេតុនោះហើយ បានជាភស្តុតាងនៃពិធីរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅទំនប់អាងទឹកត្រពាំងថ្ម គឺមិនទាក់ទងនឹងដីកាដំណោះស្រាយឡើយ ។

៦០. ចុងក្រោយបំផុត សពអ បានយោងទៅលើភស្តុតាងដែលផ្តល់ដោយលោក ថង ធឿយ និងបានអះអាងថា អ្នកស្រី អ៊ឹម ចែម បានធ្វើជាអធិបតីក្នុងពិធីរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅភូមិភាគពាយព្យហើយក្រោយមកទៀត អ្នកស្រីបានបង្គាប់ឱ្យកម្មាភិបាលក្រោមបង្គាប់ឈ្លបយកការណ៍ពី

---

[121] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ២៧ *យោងពី* ដីកាសន្និដ្ឋានស្ថាពរ, ឯកសារ **D304/2** ត្រង់កថាខណ្ឌ ២៦៩ ។ ["មេកងក្រោមការគ្រប់គ្រងរបស់ **អ៊ឹម ចែម** រៀបចំអាពាហ៍ពិពាហ៍ដោយបង្ខំឱ្យពលករនៅការដ្ឋានស្ពានស្រែង ។ ប្រជាជនមិនអាចបដិសេធមិនព្រមរៀបអាពាហ៍ពិពាហ៍បាននោះទេ បើមិនដូច្នោះទេ ពួកគេនឹងត្រូវបានចាត់ទុកថាជា "ខ្មាំង" " *ដកស្រង់ចេញពី* ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការ (សក្ខីកម្មរបស់ សែន សុផុន) ធ្វើនៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥, ឯកសារ **D219/494.1.1** និងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែន សុផុន ធ្វើនៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥, ឯកសារ **D219/506** ] ។

[122] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការ (សក្ខីកម្មរបស់ សែន សុផុន) ធ្វើនៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៥, **D219/494.1.1**, EN ERN 01122690 ។

[123] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែន សុផុន ធ្វើនៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥, ឯកសារ **D219/506** ត្រង់ចម្លើយលេខ ៣៦ ។

[124] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១៧៤ ។

គូស្វាមីភរិយាដើម្បីធានាថាអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់ទៅដោយការរួមដំណេក[125] ។ វាជាសេចក្តីថ្លែងការណ៍តែមួយគត់ដែលពាក់ព័ន្ធនឹងការបង្កើតឱ្យមានការជាប់ពាក់ព័ន្ធរបស់អ្នកស្រី អ៊ឹម ចែម នៅក្នុងដំណើរប្រព្រឹត្តទៅដូចដែលត្រូវបានចោទប្រកាន់ថាវាបណ្តាលឱ្យមានអាពាហ៍ពិពាហ៍ដោយបង្ខំ ។ គ្មានសាលាក្តីមានហេតុផលណាមួយ អាចពឹងផ្អែកលើលក្ខណៈនៃភស្តុតាងដែលស្នើឡើងដោយ សពអ នោះទេ ។ តក្កវិទ្យាដ៏សមទំនងមួយចំពោះ "ការរួមចំណែករបស់ អ៊ឹម ចែម ក្នុងយុទ្ធនាការនៃអាពាហ៍ពិពាហ៍ដោយបង្ខំ" នេះ ត្រូវតែបានគាំទ្រដោយ *ទម្ងន់មួយ*នៃសាក្សីផ្ទាល់ភ្នែក ឬប្រភពនានាផ្សេងទៀត[126] ។ តាមនិយមន័យ សាក្សីតែម្នាក់ គឺមិនអាចផ្តល់ភស្តុតាងបានមធ្យ័តគ្រប់គ្រាន់ ស៊ីសង្វាក់ ឬភស្តុតាងដែលត្រូវបានបញ្ជាក់បន្ថែម ដើម្បីផ្តល់ឱ្យបានច្រើនជាងភស្តុតាងគាំទ្រ ដែលមានភាពអាចជឿជាក់បានតិចតួចបំផុតសម្រាប់ទង្វើបែបនេះ ។

៦១. ដោយយោងទៅតាមលក្ខខណ្ឌខាងលើ សចស មានឆន្ទានុសិទ្ធិដាច់ខាតក្នុងការផ្តល់តម្លៃឱ្យភស្តុតាងនូវកម្រិតនៃភាពជឿជាក់តិចតួច ឬជាភស្តុងដែលគ្មានតម្លៃគួរជឿជាក់បានទាល់តែសោះក្នុងការទម្លាក់កំហុសលើអ្នកស្រី អ៊ឹម ចែម ក្នុងបទចោទប្រកាន់លើពីអាពាហ៍ពិពាហ៍ដោយបង្ខំ ។ សពអ មិនបានធ្វើការបង្ហាញឱ្យឃើញនូវការមានកំហុស ឬការរំលោភបំពានឆន្ទានុសិទ្ធិ ។

- ***ការធ្វើទុក្ខបុកម្នេញចំពោះជនជាតិវៀតណាមនៅតំបន់៥ នៃភូមិភាគពាយព្យ***

៦២. សពអ បានអះអាងថា សចស ខកខានមិនបានពិចារណាលើ "ចំណែកភាគច្រើននៃការចោទប្រកាន់" ទាក់ទងនឹងការប្រព្រឹត្តរបស់អ្នកស្រី អ៊ឹម ចែម ទៅលើជនជាតិវៀតណាម បូករួមទាំងអំណះអំណាងនានារបស់ព្រះរាជអាជ្ញាទាក់ទងនឹងស្ថានទម្ងន់នូវឧក្រិដ្ឋកម្មទាំងនេះ និងការទទួលខុសត្រូវរបស់អ្នកស្រី[127] ។ សពអ បានអះអាងថា សចស មិនបានធ្វើការពិចារណាលើការចោទប្រកាន់នានា និងការសម្លាប់នៅមន្ទីរសន្តិសុខចំការខ្នុរ នៅទីតាំងសម្លាប់ព្រៃតារុត នៅការដ្ឋានទំនប់

125 បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ២៧ *យោង* ដីកាសន្និដ្ឋានស្ថាពរ, ឯកសារ **D304/2** ត្រង់កថាខណ្ឌ ១៣២ ។

126 បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ២៨ ។

127 បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣២ ។ សូមមើលផងដែរ, បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ២៩-៣២ ។

អាងទឹកត្រពាំងថ្ម នៅមន្ទីរសន្តិសុខភ្នំចក្រី និងនៅវត្តព្រះនេត្រព្រះ[128] ។ អំណះអំណាងរបស់ សពអ គឺ ជាអំណះអំណាងល្អមើលតែសំបកក្រៅ ហើយគួរតែត្រូវបានច្រានចោល ។

៦៣. ជាវិធីសាស្ត្រសមហេតុផលមួយក្នុងការកំណត់នូវតម្លៃនៃភស្តុតាងដែលមានភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បានរបស់វាទាក់ទងនឹងការកំណត់យុត្តាធិការបុគ្គល សចស បានវាយតម្លៃជាបឋមលើភស្តុតាងពាក់ព័ន្ធនឹងតួនាទី និងសិទ្ធិអំណាចរបស់អ្នកស្រី អ៊ឹម ចែម នៅក្នុងភូមិភាគពាយព្យ ហើយបានរកឃើញថា វានៅតែមិនមានភាពច្បាស់លាស់ក្នុងការបង្ហាញឱ្យឃើញពី "ព្រំដែនច្បាស់លាស់នៃសិទ្ធិអំណាច[របស់អ្នកស្រី]ទៅលើបញ្ហានានាពាក់ព័ន្ធនឹងថ្នាក់តំបន់"[129] នៅវត្តចំការខ្នុរ[130] និងនៅទំនប់ត្រពាំងថ្ម[131] ឬទាក់ទងទៅនឹងការស្លាប់ និងការចាប់ខ្លួននៅវត្តព្រះនេត្រព្រះ[132] ។

៦៤. ដោយសារតែសិទ្ធិអំណាចរបស់អ្នកស្រី អ៊ឹម ចែម នៅ ទីតាំងឧក្រិដ្ឋកម្មនានាមិនត្រូវបានបង្កើតឡើងបានឧក្រិដ្ឋកម្មទាំងនេះលែងពាក់ព័ន្ធនឹងសំណួរចោទលើបញ្ហាយុត្តាធិការបុគ្គលទៀតហើយ ។ ការរកឃើញអំពីសិទ្ធិអំណាចដែលត្រូវបានចោទប្រកាន់ លើការធ្វើទុក្ខបុកម្នេញចំពោះជនជាតិវៀតណាមនៅវត្តចម្ការខ្នុរ នៅទំនប់ត្រពាំងថ្ម នៅវត្តព្រះនេតព្រះ គឺជាបុរេវិន័យមួយសម្រាប់យកមកពិចារណាជាបន្តលើឧក្រិដ្ឋកម្មទាំងនោះ ។ ពុំមានច្បាប់ ឬអ្នកវិនិច្ឆ័យអង្គហេតុដ៏មានហេតុផលណាម្នាក់ អាចធ្វើការកំណត់ផ្សេងពីនេះឡើយ ។ ឧក្រិដ្ឋកម្មទាំងនេះ នឹងមិនត្រូវបានយកមកពិចារណាបន្ថែមទៀតទេនៅក្នុងចម្លើយតបនេះ ។

៦៥. យ៉ាងណាក៏ដោយចុះ ក្រុមការពារក្តីនឹងធ្វើការវិភាគខ្លីៗអំពីអំណះអំណាងរបស់ សពអ ដែលនៅសេសសល់ទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានចោទ ប៉ុន្តែមិនត្រូវបានពិចារណាដោយ សចស ក្នុងការវាយតម្លៃរបស់ពួកគាត់លើបញ្ហាយុត្តាធិការបុគ្គល ។ សចស បានបូកបញ្ចូលនូវទីតាំងសម្លាប់នៅ

---

[128] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣១ *យោង* ដីកាសន្និដ្ឋានស្ថាពរ, ឯកសារ **D304/2** ត្រង់កថាខណ្ឌ ១៨៩, ១៩១, និងកថាខណ្ឌ ៤៧៤ ។

[129] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១៧៣ ។

[130] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ២៤៧ ។

[131] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១៧៤ និង ២៤៧ ។

[132] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ២៥៩ ។

ព្រៃតារុត នៅមន្ទីរសន្តិសុខភ្នំចក្រី និងការសម្លាប់ស្ត្រីជនជាតិវៀតណាមពីរនាក់នៅក្នុងទីតាំងគ្មានអ្នកស្គាល់[133] ។ វាត្រូវបានទទួលស្គាល់រួចមកហើយថា សចស មិនបានផ្តល់នូវការបញ្ជាក់ និងសំអាងហេតុដាច់ដោយឡែកពាក់ព័ន្ធលើសិទ្ធិអំណាចរបស់អ្នកស្រី អ៊ឹម ចែម ចំពោះទីតាំងឧក្រិដ្ឋកម្មទាំងនេះទេ ។

៦៦. ទាក់ទងនឹងការចោទប្រកាន់អំពីយុទ្ធនាការចាប់ខ្លួន ការឃុំឃាំង និងការសម្លាប់ជនជាតិវៀតណាមនៅទីតាំងសម្លាប់ព្រៃតារុត សពអ បានលើកសំអាងចេញពីសេចក្តីថ្លែងការណ៍របស់សាក្សីពីរនាក់[134] ។ សាក្សីទី១ គឺ ស៊ិន ឃិន[135] គឺជាសាក្សីដែលជាប់ពាក់ព័ន្ធជាមួយនឹងអ្នកស៊ើបអង្កេតមកពី DC-Cam ដែលបានចូលរួមក្នុងការធ្វើសេចក្តីព្រាងរបាយការណ៍មួយ ដែលកត់ត្រាពីបេសកកម្មចុះតាមទីតាំងឧក្រិដ្ឋកម្មនានានៅថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៩៧[136] ។ សពអ មិនបាន

---

[133] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣១ ។

[134] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣១ *យោង* ដីកាសន្និដ្ឋានស្ថាពរ, ឯកសារ **D304/2** ត្រង់កថាខណ្ឌ ១៨៩, ជើងទំព័រលេខ ៩៤៦ ដល់ ៩៤៧ *យោងទៅ* កំណត់ហេតុនៃការស្តាប់ចម្លើយរបស់ ស៊ិន ឃិន ធ្វើនៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៥, ឯកសារ **D219/206** ត្រង់ចម្លើយ A20-21 [សាក្សីបានទៅចំការខ្នុរ៖ សំណួរ: ហើយចុះអ្នកដែលគេកប់នៅកន្លែងហ្នឹង តើជាខ្មោចដែលគេសម្លាប់នៅទីនោះតែម្តង ឬគេយកមកពីណាមកកប់នៅកន្លែងនោះ? ចម្លើយA20: គឺអត់មានយកពីណា គឺគេដឹក តាមឡាន ១០ ទៅ ២០ឡាន ហើយយកមកសម្លាប់ ឬយកទៅដាក់ឃុំឃាំងមុននឹងយកទៅសម្លាប់ ។ សំណួរ: ពួកអ្នកដែលគេយកទៅសម្លាប់នៅកន្លែងហ្នឹង តើជាប្រភេទមនុស្សបែបណា? ចម្លើយA21: គឺជាអតីតទាហាន លន់ នល់ មន្ត្រីរដ្ឋការ ជនស៊ីវិល សិស្ស-និស្សិត សាស្ត្រាចារ្យ ប៉ូលីស ប៉េអឹម...។ល។ មានជនជាតិខ្មែរ ចិន យួន ហើយសម្លាប់នោះ មានទាំងក្មេង ទាំងចាស់ ទាំងប្រុស ទាំងស្រី ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ក់ វន្នី នៅថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៤, ឯកសារ **D119/125** ត្រង់ចម្លើយ A18 [សាក្សីគឺជាពលករក្នុងក្នុងកងចល័តដែលត្រូវបានបញ្ជូនទៅឃុំជប់វារី និងបានស្នាក់នៅជាប់នឹងផ្លូវទៅព្រៃតារុត៖ សំណួរ: តើលោកដឹងថា អ្នកដែលត្រូវបានគេដឹកតាមឡាននោះ ត្រូវពួកខ្មែរក្រហមចាប់មកពីទីកន្លែងណា? ចម្លើយA18: "បាទ មានបុរសម្នាក់ គាត់បាននៅរស់ក្រោយពេលខ្មែរក្រហមអារកគាត់ (បច្ចុប្បន្នគាត់ស្លាប់ហើយ) គាត់បាននិយាយប្រាប់ខ្ញុំថា មនុស្សដែលគេចាប់ហើយដាក់តាមឡានយកមកសម្លាប់នៅព្រៃតារុតនោះ គឺត្រូវបានគេចោទថាជាជនជាតិវៀតណាម ហើយសូម្បីតែអ្នកមានសប្បុរស ក៏ត្រូវបានគេចោទថា ជាជនជាតិវៀតណាម ហើយចាប់យកទៅសម្លាប់នៅព្រៃតារុតដែរ"] ។

[135] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣១ *យោង* ដីកាសន្និដ្ឋានស្ថាពរ, ឯកសារ **D304/2** ត្រង់កថាខណ្ឌ ១៨៩, ជើងទំព័រលេខ ៩៤៦ (*ដែលបានសំអាងលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ធ្វើនៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៥, ឯកសារ **D219/206**)។

[136] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១១៣-១១៤ ។

បង្ហាញឱ្យឃើញថា ការវាយតម្លៃរបស់ សចស លើរបាយការណ៍នេះ ថាជារបាយការណ៍ដែល "មានតម្លៃជាភស្តុតាងតិចតួច" និង "ពុំអាចទុកចិត្តបាន"[137] ឡើយ អាស្រ័យហេតុនេះហើយ ទើបភស្តុតាងដូច្នេះ មិនត្រូវបានយោងជាសំអាងមិនថាតាមមធ្យោបាយណាក៏ដោយ[138] ។ បន្ថែមពីនេះ សេចក្តីថ្លែងការណ៍ដែលត្រូវបានដកស្រង់នោះ មិនទាំងពាក់ព័ន្ធនឹងព្រៃតារុតផង ប៉ុន្តែនៅចម្ការខ្នុរ[139] ជាទីតាំងដែល សចស បានរកឃើញថា មិនមានការពាក់ព័ន្ធនឹងអ្នកស្រី អ៊ឹម ចែម[140] ។ សាក្សីម្នាក់ទៀត គឺលោក ម៉ក់ វន្នី បានថ្លែងថា មានជនមិនស្គាល់ឈ្មោះម្នាក់ (ដែលបានស្លាប់ទៅហើយនោះ) បានប្រាប់គាត់ថា អ្នកដែលត្រូវបានគេចោទថាជាជនជាតិវៀតណាម ត្រូវបានចាប់ខ្លួន និងយកទៅសម្លាប់នៅព្រៃតារុត[141] ។ គ្មានអង្គជំនុំជម្រះមានហេតុផលណា អាចដាក់ទម្ងន់លើភស្តុតាងចចាមអារ៉ាម និងគ្មានការការបញ្ជាក់បន្ថែមដូច្នេះទេ ។

៦៧. បន្ថែមពីនេះ សម្រាប់ការចោទប្រកាន់ទាក់ទងនឹងភ្នំចក្រី ការចោទប្រកាន់របស់ សពអ គឺបានផ្អែកទៅលើសេចក្តីថ្លែងការណ៍ដូចគ្នានឹងការថ្លែងរបស់សាក្សី ម៉ក់ វន្នី ដែលទើបតែបានរៀបរាប់មុននេះបន្តិច[142] ។ មិនត្រឹមតែប៉ុណ្ណោះទៀតសោត សេចក្តីថ្លែងការណ៍នេះ ក៏មិនទាក់ទងនឹងព្រឹត្តិការណ៍

---

137 ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១៣៥ ។

138 ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១៣៥ ។

139 *សូមមើល,* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ធ្វើនៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៥, ឯកសារ **D219/206** ត្រង់ចម្លើយ A13, A20-21 ។

140 ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ២៤៧ ។

141 បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣១ *យោង* ដីកាសន្និដ្ឋានស្ថាពរ, ឯកសារ **D304/2** ត្រង់កថាខណ្ឌ ១៨៩, ជើងទំព័រលេខ ៩៤៧ *ដែលបានសំអាងលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ក់ វន្នី ធ្វើនៅថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៤, ឯកសារ **D119/125** ត្រង់ចម្លើយ A18 ។

142 បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣១ *យោង* ដីកាសន្និដ្ឋានស្ថាពរ, ឯកសារ **D304/2** ត្រង់កថាខណ្ឌ ៤៧៤ ។ សេចក្តីយោងតែមួយគត់ចំពោះការប្រព្រឹត្តលើជនជាតិវៀតណាមនៅភ្នំចក្រី គឺនៅកថាខណ្ឌ ៤៧៤ នៃសេចក្តីសន្និដ្ឋានស្ថាពរ ត្រង់លេខយោងជើងទំព័រ ២១៧៧ ដោយយោងទៅលើកថាខណ្ឌ ២២៣ និង ២២៥ នៃសេចក្តីសន្និដ្ឋានស្ថាពរ ។ សេចក្តីយោងតែមួយគត់ដែលទាក់ទងទៅនឹងការប្រព្រឹត្តលើរបស់ជនជាតិវៀតណាមក្នុងកថាខណ្ឌទាំងនេះ ត្រូវបានដកស្រង់នៅលេខយោងជើងទំព័រ១១៣២ នៃការសន្និដ្ឋានស្ថាពរ *ដែលបានសំអាងលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ក់ វន្នី ធ្វើនៅថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៤, ឯកសារ **D119/125** ត្រង់ចម្លើយ A18 ។

នៅភ្នំចក្រីដែរ ប៉ុន្តែនៅព្រៃតារុត[143] ។ ដូចដែលបានរៀបរាប់ខាងលើ សចស បានធ្វើការសន្និដ្ឋាន ពោរពេញដោយភាពសមហេតុសមផលបំផុតក្នុងការរកឃើញថា សេចក្តីថ្លែងការណ៍របស់លោក ម៉ក់ វន្នី គឺជាសេចក្តីថ្លែងការណ៍ដែលមិនអាចទុកចិត្តបាន និងមានតម្លៃជាភស្តុតាងតិចតួច ។

៦៨. ចុងក្រោយ សពអ បានអះអាងថា សចស មានកំហុសដោយសារតែមិនបានពិចារណាអំពីការចោទប្រកាន់លើករណីដែលអ្នកស្រី អ៊ឹម ចែម បានបញ្ជាដោយផ្ទាល់ឱ្យសម្លាប់ស្ត្រីជនជាតិវៀតណាមពីររូប នៅទីតាំងគ្មានអ្នកស្គាល់[144] ។ ផ្ទុយទៅវិញ សចស បានធ្វើការពិចារណាចំពោះការចោទប្រកាន់នេះ ហើយបានសន្និដ្ឋានដោយសមរម្យថា "មានភស្តុតាងពុំគ្រប់គ្រាន់បង្ហាញពីការកាប់សម្លាប់ និងការរំលោភសេពសន្ថវៈដែលបានចោទប្រកាន់ ទីតាំង និងពេលវេលា អត្តសញ្ញាណរបស់ចារីផ្ទាល់ និងកងចល័តណាមួយដែលបានចូលរួមពាក់ព័ន្ធនឹងហេតុការណ៍នេះ"[145] ។ សពអ មិនបានតវ៉ាជាមុននូវអំណះអំណាងមានហេតុផលណាមួយ ថាតើការរកឃើញរបស់ សចស ស្តីពីភាពគ្រប់គ្រាន់នៃភស្តុតាងដូចម្តេចខ្លះដែលមិនសមហេតុផល ឬបើមិនដូច្នេះទេ ក៏ត្រូវបរិយាយពីរបៀបដូចម្តេចនៃការមានកំហុសនោះដែរ ។

៦៩. សរុបមក សចស មានឆន្ទានុសិទ្ធិដាច់ខាត ក្នុងការផ្តល់តម្លៃជាភស្តុតាងដែលមានភាពជឿជាក់ត្រឹមកម្រិតតិចតួច ឬជាភស្តុងដែលគ្មានតម្លៃគួរជឿជាក់បានទាល់តែសោះ ដើម្បីទម្លាក់កំហុសដល់អ្នកស្រី អ៊ឹម ចែម នៅក្នុងការធ្វើទុក្ខបុកម្នេញលើជនជាតិវៀតណាមនៅភូមិភាគពាយព្យ ។

- ***"ឧក្រិដ្ឋកម្មជាច្រើនផ្សេងទៀត" ដែល សចស ត្រូវបានប្តឹងឱ្យដោះស្រាយ***

៧០. សពអ បានលើកឡើងថា សចស មិនបានយកចិត្តទុកដាក់ពិចារណាលើ "ការពាក់ព័ន្ធរបស់

[143] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣១ *យោង* ដីកាសន្និដ្ឋានស្ថាពរ, ឯកសារ **D304/2** ត្រង់កថាខណ្ឌ១៨៩ ជើងទំព័រ ៩៤៧ *ដែលបានសំអាងលើ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ក់ វន្នី ធ្វើនៅថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៤, ឯកសារ **D119/125** ត្រង់ចម្លើយ A18 ។

[144] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣១ *យោង* ដីកាសន្និដ្ឋានស្ថាពរ, ឯកសារ **D304/2** ត្រង់កថាខណ្ឌ១៩២ ។

[145] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ២៨០ ។ *សូមមើលផងដែរ*, ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ២៧៩ ។

[អ្នកស្រី] អ៊ឹម ចែម ក្នុងការប្រព្រឹត្តអំពើធ្វើទុក្ខបុកម្នេញប្រឆាំងក្រុមជាតិពន្ធុ និងក្រុមនយោបាយខុសៗគ្នា"[146] រួមមានដូចជាការធ្វើទុក្ខបុកម្នេញទៅលើជនជាតិភាគតិចចាម ចិន ឡាវ នៅចម្ការខ្នុរ[147] និងខ្មែរលើនៅទីតាំងវត្តអង្គសិរីមាលី[148] ។ ខណៈដែលទទួលស្គាល់ថា សចស បានរកឃើញ "សោះតែខាន" ថាមានការធ្វើទុក្ខបុកម្នេញបានកើតឡើងនៅទីតាំងឧក្រិដ្ឋកម្មមួយចំនួន ដែលមិនត្រូវបានចោទប្រកាន់[149] សពអ បានអះអាងថា សចស បានធ្វើខុសដោយមិនបានបញ្ជាក់ថាតើក្រុមណាមួយក្នុងចំណោមក្រុមមនុស្សនានា ដែលជាជនរងគ្រោះពីអំពើឧក្រិដ្ឋកម្ម គឺជាការបរាជ័យក្នុងការវាយតម្លៃនូវភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងបរាជ័យក្នុងការរែកញែកពីការទទួលខុសត្រូវរបស់អ្នកស្រី អ៊ឹម ចែម នៅក្នុងឧក្រិដ្ឋកម្មទាំងនោះ[150] ។

៧១. ប៉ុន្តែ ការអានឱ្យត្រឹមត្រូវនៃដីកាដំណោះស្រាយបង្ហាញឱ្យឃើញថា សចស បានរកឃើញថា ពុំមានភស្តុតាងច្បាស់លាស់ណាមួយអំពីការចូលរួមរបស់អ្នកស្រី អ៊ឹម ចែម នៅទីតាំងឧក្រិដ្ឋកម្មមួយចំនួន ដូចបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងការធ្វើទុកបុកម្នេញដែលបានចោទប្រកាន់នោះទេ[151] ។ ហេតុដូច្នេះ វាគ្មានភាពចាំបាច់អ្វីនឹងត្រូវធ្វើការវាយតម្លៃលម្អិតលើភស្តុតាងនេះ

---

[146] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣៥ ។

[147] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣៥, ជើងទំព័រលេខ ៧៧-៧៩ *យោងលើ* ដីកាសន្និដ្ឋានស្ថាពរ, ឯកសារ **D304/2** ត្រង់កថាខណ្ឌ ២៤០ ។

[148] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣៥, ជើងទំព័រលេខ ៨០ *យោងលើ* ដីកាសន្និដ្ឋានស្ថាពរ, ឯកសារ **D304/2** ត្រង់កថាខណ្ឌ ១៦៨ ។

[149] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣៦ ។

[150] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣៦ ។

[151] *សូមមើល*, ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១៥២ ["ផ្ទុយពីការចោទប្រកាន់ដែលធ្វើឡើងដោយ សពអ មិនមានភស្តុតាងបង្ហាញឱ្យឃើញថាអ្នកស្រី អ៊ឹម ចែម មានតួនាទីទាក់ទងនឹងប្រតិបត្តិការនៅវត្តអង្គសិរីមានលី ឬវត្តព្រៃសុខុន ភស្តុតាងដែលបង្ហាញថាអ្នកស្រីបានចុះមកពិនិត្យទីតាំងទាំងនេះ ឬថាអ្នកស្រីបានដាក់បញ្ជាដោយផ្ទាល់ ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មទាំងនេះ"] ។ ត្រង់កថាខណ្ឌ ២៤៧ ["ទាំងនៅចម្ការខ្នុរ និងទំនប់ទឹកត្រពាំងថ្មគឺស្ថិតនៅក្នុងស្រុកស៊ីសូផុន និងស្រុកភ្នំស្រុកនៃតំបន់៥ ។ យើងបានធ្វើសេចក្តីសន្និដ្ឋាននៅក្នុងផ្នែក៤.៤ ខាងលើ ទាក់ទងនឹងការចោទប្រកាន់ថា [អ្នកស្រី] អ៊ឹម ចែម មានមុខតំណែងជាគណៈតំបន់៥ បន្ទាប់ពីមានការដកចេញសមាជិកមួយចំនួននៃភូមិភាគពាយព្យ និងថា មានការចង្អុលបង្ហាញថាសិទ្ធិអំណាចរបស់អ្នកស្រីហួសពីព្រំដែនរដ្ឋបាលនៃស្រុកព្រះនេត្រព្រះ ។ ទោះជាយ៉ាងណា

ឡើយ ដោយសារវាជាភស្តុតាងដែលវាមិនអាចមានឥទ្ធិពលអ្វីក្នុងការកំណត់យុត្តាធិការបុគ្គល ។ ការរកឃើញនេះ មិនត្រូវបានពិគ្រោះវែកញែកឡើយ ដោយ សចអ ។

៧២. លើសពីនេះទៀត សចអ បានអះអាងបន្ថែមទៀតថា សចស មានកំហុសដោយសារមិនបានធ្វើការវាយតម្លៃការចោទប្រកាន់មួយចំនួន ចំពោះការធ្វើទារុណកម្មនៅមន្ទីរសន្តិសុខភ្នំត្រយោង[152] និងនៅចម្ការខ្នុរ[153] ការដាក់ឃុំឃាំង និងការបាត់ខ្លួនដោយបង្ខំនៅវត្តអង្គសិរីមាលី[154] ព្រមទាំងលក្ខខណ្ឌរស់នៅបែបអមនុស្សធម៌នៅភ្នំចក្រី[155] ។ ទោះជាយ៉ាងណាក្តី ពាក្យបណ្តឹងនេះ មានវិការៈ ហើយគួរត្រូវបានច្រានចោលភ្លាមៗ ។ សចអ គ្រាន់តែវាយឈ្មោះបទចោទប្រកាន់នានា ដោយមិនខ្វល់នឹងផ្តល់ការពន្យល់វែកញែកថាតើកំហុសណាមួយ ដែលញ៉ាំងឱ្យមានការធ្វើមោឃភាពលើការរកឃើញនានានៃដីកាដំណោះស្រាយ ឬបើមិនដូច្នោះទេ ក៏ត្រូវបង្ហាញហេតុផលដែលបង្កឱ្យមានជាការបំពានឆន្ទានុសិទ្ធិ ។

៧៣. សរុបមក នៅក្រោមទឡ្ហីករណ៍ទី២ ក្រុមការពារក្តីសន្និដ្ឋានថា សចអ មិនបានចង្អុលបង្ហាញពីរបៀបដែលភស្តុតាងជាលក្ខណៈដាច់ដោយឡែកពីគ្នា ឬជាភស្តុតាងត្រួតគ្នាមានកំហុសដោយការមិនបាន "ដោះស្រាយការចោទប្រកាន់ជាច្រើនដែលមាននៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់ សចអ [អន្តរជាតិ]"[156] គឺនាំឱ្យឈានដល់ការសន្និដ្ឋានមួយថា សចស បានរំលោភបំពានឆន្ទានុសិទ្ធិរបស់ខ្លួនទាំងស្រុង ក្នុងការសម្រេចថា អ.វ.ត.ក ខ្វះយុត្តាធិការលើអ្នកស្រី អ៊ឹម ចែម ។

## ខ. ទឡ្ហីករណ៍ទី៣៖ សហចៅក្រមស៊ើបអង្កេតមានកំហុសអង្គច្បាប់នៅពេលកំណត់និយមន័យលើបទឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល និងការអនុវត្តនិយមន័យនេះ

---

ក៏ដោយ យើងក៏បានរកឃើញដែរថាវិសាលភាព និងខ្សែបន្ទាត់នៃសិទ្ធិអំណាចនេះមិនត្រូវបានកំណត់ច្បាស់លាស់ដោយការស៊ើបអង្កេតនោះទេ"] ។

[152] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣៧ *យោង* ដីកាសន្និដ្ឋានស្ថាពរ, ឯកសារ D304/2 ត្រង់កថាខណ្ឌ២០៨ ដល់ ២១១ ។

[153] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣៧ *យោង* ដីកាសន្និដ្ឋានស្ថាពរ, ឯកសារ D304/2 ត្រង់កថាខណ្ឌ ២៣៨ ។

[154] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣៧ *យោង* ដីកាសន្និដ្ឋានស្ថាពរ, ឯកសារ D304/2 ត្រង់កថាខណ្ឌ ១៦៨ ។

[155] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣៧ *យោង* ដីកាសន្និដ្ឋានស្ថាពរ, ឯកសារ D304/2 ត្រង់កថាខណ្ឌ ២២៤ ។

[156] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ២៣ ។

## នៅលើការរកឃើញរបស់ពួកគាត់ក្នុងដីកាដំណោះស្រាយ

៧៤. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតមានកំហុសចំពោះការមិនដាក់អ្នកស្រី អ៊ឹម ចែម ឱ្យទទួលខុសត្រូវលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលបានចោទប្រកាន់ថាបានប្រព្រឹត្តទៅនៅមន្ទីរសន្តិសុខភ្នំត្រយោង[157] ។ ចំណុចជាក់លាក់ សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា សចស មានកំហុសអង្គច្បាប់ចំពោះលក្ខខណ្ឌតម្រូវនៃការមាន *ចេតនាឧក្រិដ្ឋ (ធាតុផ្សំអត្តនោម័ត)* ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលត្រូវបានបង្កើតឡើង *ជាមុន* និងថា សចស មានកំហុសអង្គហេតុក្នុងការខកខានមិនបានរកឃើញថាអ្នកស្រី អ៊ឹម ចែម មាន *ចេតនាឧក្រិដ្ឋ*ជាចាំបាច់សម្រាប់ឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល[158] ។

៧៥. ដូចដែលនឹងត្រូវបង្ហាញលម្អិតខាងលើនៅកថាខណ្ឌ១៧ ដល់កថាខណ្ឌ១៩ ក្រុមការពារក្តីស្នើថាទឡ្ហីករណ៍ទី៣ គឺមិនអាចទទួលយកបានថាត្រឹមត្រូវតាមច្បាប់នោះទេ និងគួរតែត្រូវច្រានចោល ។ ដីកាដំណោះស្រាយ មិនបានផ្តល់ហេតុផលសម្រាប់ពិចារណាពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អ្នកស្រី អ៊ឹម ចែម ដូចដែលបានចោទប្រកាន់ឡើយ ។ លទ្ធផលដែលកើតចេញពីសេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតដែលថា អ.វ.ត.ក ខ្វះយុត្តាធិការបុគ្គល គឺបានមកពីសំណួរចោទស្តីពីបញ្ហានៃការមាន *ចេតនាឧក្រិដ្ឋ*របស់អ្នកស្រី អ៊ឹម ចែម ដែលជាបញ្ហាមួយមិនត្រូវបានរកឃើញសម្រាប់ធ្វើការពិចារណា ហើយក៏មិនត្រូវបានធ្វើការវាយតម្លៃលើបញ្ហានេះដែរ ។ លើសពីនេះ ដូចដែលបានលើកឡើងនៅក្នុងកថាខណ្ឌ២០ ដល់កថាខណ្ឌ២៣ ទឡ្ហីករណ៍ទី៣របស់សហព្រះរាជអាជ្ញាអន្តរជាតិ ធ្វើការស្នើសុំដែលមិនអាចអនុញ្ញាតឱ្យធ្វើទៅបានឡើយ ដោយសុំឱ្យពិនិត្យឡើងវិញនូវវិធីសាស្ត្ររបស់ សចស ចំពោះដែនកំណត់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិសម្រាប់ការសម្លាប់រង្គាល ។

៧៦. បន្ថែមពីនេះទៀត បើទោះបីជាទឡ្ហីករណ៍ទី៣អាចទទួលយកបានក៏ដោយ ក៏អង្គសេចក្តីនានាក្នុង

---

[157] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣៨ ។

[158] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣៨ ។

ផ្នែកនេះ គប្បីត្រូវបានច្រានចោល ។ ក្រុមការពារក្តីស្នើថា៖ i) សចស គ្មានកំហុសអង្គច្បាប់នៅក្នុងការកំណត់និយមន័យស្តីពី *ចេតនាឧក្រិដ្ឋ* សម្រាប់ការសម្លាប់រង្គាលនោះទេ និង ii) បើទោះបីជាកំហុសអង្គច្បាប់ត្រូវបានបង្កើតឡើងក្តី ក៏សហព្រះរាជអាជ្ញាអន្តរជាតិខកខានមិនបានតវ៉ា ឬបង្ហាញឱ្យឃើញថា កំហុសនោះបានបង្កឱ្យមានជាការរំលោភបំពានឆន្ទានុសិទ្ធិទាក់ទងនឹងដីកាដែលរងការជំទាស់នេះ ។

### *i. សចស មិនមានកំហុសអង្គច្បាប់នៅក្នុងការកំណត់និយមន័យស្តីពី ចេតនាឧក្រិដ្ឋ នៃការសម្លាប់រង្គាលនោះទេ*

៧៧. ប្រសិនជាវិធីសាស្ត្ររបស់ សចស ចំពោះឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលត្រូវបានសម្រេចថា បញ្ហានេះ ស្ថិតនៅក្នុងដែនអំណាចរបស់ អបជ ក្នុងការពិនិត្យឡើងវិញមែននោះ ទោះក្នុងករណីណាក៏ដោយក្រុមការពារក្តីយល់ឃើញថា សចស មិនបានវិនិច្ឆ័យខុសឡើយក្នុងការកំណត់និយមន័យនៃ *ចេតនាឧក្រិដ្ឋ* ។

៧៨. សពអ បានចោទថា សចស “មានកំហុសអង្គច្បាប់ដោយការរកឃើញថា ចេតនាសម្រាប់ឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល...ត្រូវតែបានបង្កើតឡើង *‘ជាមុន*”[159] ។ សពអ បញ្ជាក់អះអាងថា សចស បានសម្រេចថា ការកំណត់និយមន័យលើបទឧក្រិដ្ឋមួយតម្រូវឱ្យ “ជនជាប់ចោទត្រូវតែមានចេតនាជាក់លាក់សម្រាប់ឧក្រិដ្ឋកម្មសម្លាប់រង្គាល ... មុនពេលការសម្លាប់ណាមួយកើតមានឡើង”[160] ។

៧៩. ទោះជាយ៉ាងណាក៏ដោយ ទាំងការអានត្រង់ៗ ឬក៏អានក្នុងបំណងជាក់លាក់នៃដីកាដំណោះស្រាយ គឺគ្មានចំណុចណាគាំទ្រដល់ការអះអាងដូច្នេះទេ: នៅពេលធ្វើការកំណត់និយមន័យលើបញ្ហា*ចេតនាឧក្រិដ្ឋ*សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការសម្លាប់រង្គាល សចស មិនបានបញ្ចូលលក្ខខណ្ឌតម្រូវឱ្យមានការព្យាករ *ជាមុន* ទៅក្នុងធាតុផ្សំរបស់*ចេតនាឧក្រិដ្ឋ* នៃបទឧក្រិដ្ឋ

---

[159] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣៨ *បានដកស្រង់ចេញពី* ដីកាដំណោះស្រាយត្រង់កថាខណ្ឌ ២៨៨ ។

[160] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៤០ ។

នោះទេ ។ ផ្ទុយទៅវិញ ពួកគាត់បានកំណត់ធាតុផ្សំផ្នែកស្មារតី (ធាតុផ្សំអត្តនោម័ត) ផ្អែកតាមលក្ខខណ្ឌដូចតទៅ: "ចេតនាសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំ ឬបង្ករបួសលើរូបរាងកាយធ្ងន់ធ្ងរ ឬបង្កើតលក្ខខណ្ឌនៃការរស់នៅដែលនាំឱ្យមានការបំផ្លាញផ្នែកសំខាន់ណាមួយនៃក្រុមនោះ"[161] ។ ដូច្នេះមានន័យថា សចស បានអនុម័តច្បាប់ដ៏ត្រឹមត្រូវដូចដែលត្រូវបានកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល[162] ។

៨០. វិធីសាស្ត្រទូទៅរបស់ សចស មិនបង្ហាញឱ្យឃើញថា សចស មានចេតនាងាកចេញពីនិយមន័យនេះឡើយ[163] ។ ដូចដែលបានគូសបញ្ជាក់ខាងក្រោម ការសន្និដ្ឋានរបស់ សចស ដែលតម្រូវថាភស្តុតាងគប្បីបង្កើតឱ្យឃើញនូវការប៉ុនប៉ង *ជាមុន* ក្នុងកាលៈទេសៈជាក់ស្តែងនៃទិដ្ឋភាពសំណុំរឿងក្តីនេះ សបញ្ជាក់ឱ្យឃើញថា ពួកគាត់គ្មានបំណងនឹងធ្វើការណែនាំឱ្យប្រើនូវ ធាតុផ្សំច្បាប់ថ្មីទៅក្នុងបទបង្ហាញស្តីពីច្បាប់នៃអង្គជំនុំជម្រះតុលាការកំពូលនោះទេ ។ ផ្ទុយទៅវិញ វាជាវិធីសាស្ត្រសមហេតុផលមួយ ដើម្បីបង្ហាញភស្តុតាងនៅក្នុងស្ថានភាពជាក់ស្តែងដែលត្រូវបានបង្កើតឡើងផ្អែកតាមអ្វីដែលបានរកឃើញពីនៅក្នុងទីតាំងជាក់លាក់ ពោលគឺនៅមន្ទីរសន្តិសុខភ្នំត្រយោង ។ ជារួម សចស បានសន្និដ្ឋានដោយសមហេតុផលថារាល់ការចោទប្រកាន់នានានៅក្នុងទីតាំងនោះ ការ *មានតែ*ចេតនាតម្រូវជាចាំបាច់ក្នុងការសម្លាប់រង្គាល ដូចដែលបានថ្លែងដោយអង្គជំនុំជម្រះតុលាការកំពូល តុលាការមិនអាចជឿជាក់បានពេញលេញសម្រាប់ការកំណត់ន័យឧក្រិដ្ឋកម្មនេះបានទេ ដរាបណាគ្មានការបង្ហាញឱ្យឃើញពីគោលបំណង *ជាមុន*ទេនោះ[164] ។

៨១. ជាក់ស្តែងគឺថា សចស មិនបានតម្រូវឱ្យមានគោលបំណងសម្រាប់ការសម្លាប់រង្គាលដើម្បីបង្ហាញ

---

[161] ដីកាដំណោះស្រាយ ត្រង់កថាខណ្ឌ ៦៨(ខ) ។

[162] ដីកាដំណោះស្រាយ ត្រង់កថាខណ្ឌ ៦៨(ខ) [*ដកស្រង់ចេញពី*, សាលដីកានៃសំណុំរឿង០០២/១, ឯកសារ F36 ត្រង់កថាខណ្ឌ ៥២០, និងកថាខណ្ឌ ៥២២ ["[ចេតនាផ្ទាល់ក្នុងការសម្លាប់ទ្រង់ទ្រាយធំ ត្រូវតែបង្ហាញឱ្យឃើញនូវ [*ចេតនាឧក្រិដ្ឋ* ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការសម្លាប់រង្គាល]"។]]។

[163] ដីកាដំណោះស្រាយ ត្រង់កថាខណ្ឌ ២៨៧ ដល់ ២៨៨ ។

[164] ដីកាដំណោះស្រាយ ត្រង់កថាខណ្ឌ ២៨៧ ដល់ ២៨៨ ។

ឱ្យកាន់តែច្បាស់ពីការមានការប៉ុនប៉ងជាចាំបាច់ "មុនពេលការសម្លាប់*ណាមួយ*កើតមានឡើង"[165] ឡើយ នៅក្នុងទីតាំងនីមួយៗដែលកំពុងត្រូវបានពិចារណា ។ ផ្ទុយទៅវិញ ការសង្កេតជាក់ស្តែងរបស់ សចស ត្រូវបានកម្រិតត្រឹមតែកាលៈទេសៈនៃអង្គហេតុជាក់លាក់មួយចំនួន ដែលត្រូវបានរកឃើញថាមានអត្ថិភាពនៅក្នុងមន្ទីរសន្តិសុខភ្នំត្រយោង ហើយអ្វីដែលជាបញ្ហាត្រូវពិចារណានៅពេលធ្វើសេចក្តីសម្រេច គឺលើបញ្ហាអង្គហេតុដែលថា "ការសម្លាប់ [នៅក្នុងទីតាំងនេះ] ត្រូវបានធ្វើឡើងក្នុងរយៈពេលយូរ ហើយប្រហែលជាធ្វើឡើងដោយចារីផ្ទាល់ផ្សេងៗគ្នាផង"[166] ។ ជាផលវិបាកនៃលក្ខណៈខុសស្រឡះពីគ្នានៃចំនួនចារីច្រើននាក់ ដែលអាចត្រូវបានប្រព្រឹត្តបទល្មើសដោយផ្ទាល់ ហើយលក្ខណៈនៃការសម្លាប់នៅមន្ទីរសន្តិសុខភ្នំត្រយោងក៏ត្រូវបានប្រព្រឹត្តទៅតាមគំរូមួយដែលចែកជាវគ្គៗដាច់ៗពីគ្នា សចស បានកំណត់ថាពួកគាត់មិនអាចជឿជាក់បានទេដែលថា *ចេតនាឧក្រិដ្ឋ*សម្រាប់ការសម្លាប់រង្គាល ត្រូវបានបង្កើតឡើងដោយសារគ្មានភស្តុតាងនៃការប៉ុនប៉ង*ជាមុន*ក្នុងការសម្លាប់ជាទ្រង់ទ្រាយធំ ហើយការដែលគ្មានចេតនាត្រៀមទុកជាមុន គឺជាកង្វះខាតនូវកាលៈទេសៈជាក់លាក់នៃការសម្លាប់នៅមន្ទីរសន្តិសុខភ្នំត្រយោង[167] ។

៨២. ការកំណត់នេះ គឺជាវិធីសាស្ត្រសមហេតុសមផលបំផុតចំពោះភស្តុតាងនៅក្នុងកាលៈទេសៈនៃការចោទប្រកាន់ដែលពាក់ព័ន្ធ និងក៏ស្របតាមបទដ្ឋានវិធីសាស្ត្រអន្តរជាតិចំពោះឧក្រិដ្ឋកម្ម[168] ។ ការ

---

[165] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៤០ (សង្កត់ន័យបន្ថែមត្រង់អក្សរទ្រេត) ។

[166] ដីកាដំណោះស្រាយ ត្រង់កថាខណ្ឌ ២៨៨ ។

[167] ដីកាដំណោះស្រាយ ត្រង់កថាខណ្ឌ ២៨៨ ។

[168] *សំណុំរឿង* The Prosecutor *ទល់នឹង* Milan Lukić *និង* Sredoje Lukić, *សំណុំរឿងលេខ* (IT-98-32/1-A), អង្គជំនុំជម្រះសាលាឧទ្ធរណ៍, សាលដីកា, ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១២, ត្រង់កថាខណ្ឌ ៥៣៨ ["កត្តាពាក់ព័ន្ធ [ដើម្បីបង្កើតជាឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល] រាប់បញ្ចូល*ក្នុងនោះ*រួមមាន ពេលវេលា...នៃការសម្លាប់ទាំងនោះ"] [**ភ្ជាប់ជាឯកសារសម្អាង៖ ១៦**]។ *សំណុំរឿង* The Prosecutor *ទល់នឹង* Vujadin Popović *និងអ្នកផ្សេងទៀត, សំណុំរឿងលេខ* (IT-05-88-T), អង្គជំនុំជម្រះសាលាដំបូង II, សាលក្រម ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ ត្រង់កថាខណ្ឌ ៨០៥ [ក្នុងការរកឃើញថា បទឧក្រិដ្ឋនៃការសម្លាប់រង្គាលត្រូវបានកើតឡើង អង្គជំនុំជម្រះបានយកចិត្តទុកដាក់លើបញ្ហា "បណ្តោះអាសន្ន...ចំណងទាក់ទងគ្នានៃការសម្លាប់"] [**ភ្ជាប់ជាឯកសារសម្អាង៖ ១៤**]។ *សំណុំរឿង* The Prosecutor *ទល់នឹង* Édouard Karemera *និង* Matthieu Ngirumpatse, *សំណុំរឿងលេខ* (ICTR-98-44-A), អង្គជំនុំជម្រះសាលាឧទ្ធរណ៍, សាលដីកា ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤, ត្រង់កថាខណ្ឌ ៦៦១ [អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសម្រេចថា

សម្លាប់រង្គាលពាក់ព័ន្ធនឹងការមានបំណងបំផ្លាញ "ផ្នែកសំខាន់ណាមួយនៃក្រុម[ប្រជាជន]នោះ" ដែលចំនួននៃក្រុមប្រជាជននេះត្រូវបានយកមកធ្វើការ "គណនា" និង "សន្មតថាមានការរៀបចំក្នុងកម្រិតសំខាន់មួយ" ដើម្បីឱ្យមានជាលទ្ធផលមួយ[169] ។ ជនជាប់ចោទត្រូវតែ "មានចេតនាបង្កឡើងនូវលទ្ធផលបែបនេះ"[170] ។ នៅក្នុងកាលៈទេសៈដែលឈានដល់កម្រិតមួយទាក់ទងនឹងភាពមិនប្រាកដប្រជានូវអត្តសញ្ញាណរបស់ចារីផ្ទាល់មួយចំនួន (បុគ្គលផ្សេងៗគ្នា) និងទំនាក់ទំនងរវាង

---

ឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលមិនអាចត្រូវបានបង្កើតឡើង "ដោយការពិចារណាសមូហភាពទៅលើព្រឹត្តិការណ៍ខុសៗគ្នាដែលបានប្រព្រឹត្តទៅ...ដោយចារីផ្សេងៗគ្នា និងត្រូវបានកើតឡើងក្នុងរយៈពេលយូរមកហើយនោះឡើយ។"] **[ភ្ជាប់ជាឯកសារសម្អាង៖ ១៩]**។ *សំណុំរឿង The Prosecutor ទល់នឹង Théoneste Bagosora និង Anatole Nsengiyumva, សំណុំរឿងលេខ* (ICTR-98-41-A)*,* អង្គជំនុំជម្រះសាលាឧទ្ធរណ៍, សាលដីកា, ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១, ត្រង់កថាខណ្ឌ ៣៩៦ [អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសម្រេចថា ឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលមិនអាចត្រូវបានបង្កើតឡើង "ដោយផ្អែកលើការពិចារណាសមូហភាពនៃព្រឹត្តិការណ៍ដែលបានប្រព្រឹត្តឡើងដោយចារីផ្សេងៗគ្នា និងដែលការប្រព្រឹត្តនេះស្ថិតក្នុងរយៈពេលពីរខែ។] **[ភ្ជាប់ជាឯកសារសម្អាង៖ ១៨]**។

169 សាលដីកានៃសំណុំរឿង០០២/១, ឯកសារ **F36** ត្រង់កថាខណ្ឌ ៥២១ [ដកស្រង់ដោយការអនុម័តស្របគ្នាជាមួយនឹង *សំណុំរឿងក្តី The Prosecutor ទល់នឹង Radislav Kristić, សំណុំរឿងលេខ* (IT-98-33-T), អង្គជំនុំជម្រះសាលាដំបូង, សាលក្រម ចុះថ្ងៃទី ២ ខែ សីហា ឆ្នាំ ២០០១ ត្រង់កថាខណ្ឌ ៥០៣] ។ *សំណុំរឿង The Prosecutor ទល់នឹង Radislav Kristić, សំណុំរឿងលេខ* (IT-98-33-T), អង្គជំនុំជម្រះសាលាដំបូង, សាលក្រម ចុះថ្ងៃទី ២ ខែ សីហា ឆ្នាំ ២០០១ ត្រង់កថាខណ្ឌ ៥០១] **[ភ្ជាប់ជាឯកសារសម្អាង៖ ៣]** ។ *សំណុំរឿងក្តី The Prosecutor ទល់នឹង Clément Kayishema និង Obed Ruzindana, សំណុំរឿងលេខ* (ICTR-95-1-T), អង្គជំនុំជម្រះសាលាដំបូង, សាលក្រម ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩, ត្រង់កថាខណ្ឌ ១៤៦ ["ការសម្លាប់រង្គាលមិនត្រឹមតែរួមបញ្ចូលនូវការអនុវត្តការសម្លាប់ ទ្រង់ទ្រាយធំប៉ុណ្ណោះទេ ... ប៉ុន្តែបូករួមទាំងការធ្វើផែនការផងដែរ ។ ក្នុងករណីនេះ ព្រះរាជអាជ្ញាត្រូវតែបង្ហាញពីទំនាក់ទំនងរវាងផែនការ និងការសម្លាប់ពិតប្រាកដ]" **[ភ្ជាប់ជាឯកសារសម្អាង៖ ១៧]**។

170 *សំណុំរឿងក្តី នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អ.វ.ក.ត./អ.ជ.ត.ក.*, សាលដីកានៃអង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០១៦, ឯកសារលេខ **F36** ត្រង់កថាខណ្ឌ ៥២១ [ដកស្រង់ដោយការអនុម័តស្របគ្នាជាមួយនឹង*សំណុំរឿងក្តី The Prosecutor ទល់នឹង Elizaphan Ntakirutimana និង Gérard Ntakirutiman, សំណុំរឿងលេខ* (ICTR-96-10-A និង*សំណុំរឿងលេខ* (ICTR-96-17-A), អង្គជំនុំជម្រះសាលាឧទ្ធរណ៍, សាលដីកា ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៤ ត្រង់កថាខណ្ឌ ៥២២] ។ *សំណុំរឿងក្តី The Prosecutor ទល់នឹង Milomir Stakić, សំណុំរឿងលេខ* (IT-97-24-A) , អង្គជំនុំជម្រះសាលាឧទ្ធរណ៍, សាលដីកា ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦, ត្រង់កថាខណ្ឌលេខ ២៦០ ["*ចេតនាឧក្រិដ្ឋ*នៃការសម្លាប់រង្គាល ច្បាស់ណាស់តម្រូវឱ្យមានបំណងក្នុងការសម្លាប់ជាទ្រង់ទ្រាយធំ"។] **[ភ្ជាប់ជាឯកសារសម្អាង៖ ៨]**។

ព្រឹត្តិការណ៍សម្លាប់ត្រូវបានប្រព្រឹត្តទៅខុសៗគ្នា ភស្តុតាងពេញលេញបង្ហាញឱ្យឃើញពីចេតនា *ជាមុន*ក្នុងការសម្លាប់ដែលរុំព័ទ្ធទាំងស្រុងនូវ (ក្នុងពេលវេលាជាវគ្គៗ ឬក្នុងព្រឹត្តិការណ៍ដាច់ដោយឡែកពីគ្នាជាច្រើនករណី) ព្រឹត្តិការណ៍សម្លាប់ទាំងនោះ គឺជាភស្តុតាងតម្រូវដ៏សមហេតុផលមួយ ដែលស្របទៅនឹងបន្ទុក និងបទដ្ឋាននៃការបង្ហាញភស្តុតាង ក៏ដូចជាស្របនឹងគោលការណ៍កំណត់លើបញ្ហាពិរុទ្ធភាព[171] ។

៨៣. អាស្រ័យហេតុនេះ ស្ថានភាពមិនប្រាកដនៃមេបញ្ជាការដែលចេញបញ្ជាឱ្យមានការកម្ទេចក្រុមជនស៊ីវិលតូចៗជាច្រើន ដែលទីបំផុតទៅបានសម្លាប់មនុស្សអស់រាប់ពាន់នាក់ គឺជាការលើកឡើងមិន

---

[171] សាលដីកានៃសំណុំរឿង០០២/១, ឯកសារ **F36** ត្រង់កថាខណ្ឌ ៥២០ និង ៥២២ ។ *សូមមើលផងដែរ, សំណុំរឿងក្តី The Prosecutor ទល់នឹង Milomir Stakić, សំណុំរឿងលេខ* (IT-97-24-A), អង្គជំនុំជម្រះសាលាឧទ្ធរណ៍, សាលដីកា ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦, ត្រង់កថាខណ្ឌ ២៥៨ ដល់ ២៥៩ [ការរក្សាយុត្តិសាស្ត្រពីមុននៃអង្គជំនុំជម្រះសាលាដំបូងរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ (តុលាការ ICTY) ដោយកត់សម្គាល់នូវអត្ថិភាពនៃ "គ្រោងការណ៍ធំធេងនៃការសម្លាប់មនុស្សដោយឃាតករជាក្រុម" នៅពេលអនុវត្តលើបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិនៃការសម្លាប់រង្គាលមិនបានបង្កើតបាននូវធាតុផ្សំផ្នែកច្បាប់បន្ថែមមួយទៀត ដែលតម្រូវសម្រាប់ការសម្លាប់រង្គាលនោះទេ ដោយសារតែផ្នែកខ្លះ ស្ថិតលើការពិតដែលថា "សាលក្រមលើរឿងក្តីរបស់ *Vasiljević* មិនបានរាប់បញ្ចូលនូវ 'ការដឹងឮនូវគម្រោងធំធេងនៃការសម្លាប់មនុស្សដោយឃាតករជាក្រុម' នៅក្នុងសេចក្តីសង្ខេប នៃធាតុផ្សំនៃឧក្រិដ្ឋកម្ម សម្លាប់រង្គាលនោះទេ (លុបចោលការដកស្រង់) [**ភ្ជាប់ជាឯកសារសម្អាង៖ ៨**]។ *សំណុំរឿងក្តី The Prosecutor ទល់នឹង Radoslav Brdanin, សំណុំរឿងលេខ* (IT-99-36-T), អង្គជំនុំជម្រះសាលាដំបូង, សាលក្រម ចុះថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០០៤, ត្រង់កថាខណ្ឌ ៣៩៤ ["អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់យ៉ាងច្បាស់ថា 'ការដឹងឮរបស់លោក *Vasiljević* ដែលថាសកម្មភាពរបស់គាត់ គឺជាផ្នែកមួយនៃការចូលរួមសម្លាប់យ៉ាងទូលំទូលាយ ដែលមានមនុស្សមួយចំនួនធំត្រូវបានធ្វើការកត់សម្គាល់ជាប្រព័ន្ធដើម្បីយកទៅសម្លាប់ ឬបានសម្លាប់រួចហើយ' បើសិនជាចេតនានេះត្រូវបានរកឃើញ នោះវានឹងត្រូវគេចាត់ទុកថាជាភស្តុតាងដើម្បីបង្ហាញពីចំណេះដឹងរបស់ជនជាប់ចោទ ក្នុងការបញ្ជាក់ថា ទង្វើរបស់គាត់ គឺជាផ្នែកមួយនៃការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធប្រឆាំងនឹងប្រជាជនស៊ីវិល និងមិនឱ្យលើសពីនោះឡើយ"។ (លុបចោលការដកស្រង់)] [**ភ្ជាប់ជាឯកសារសម្អាង៖ ៤**] (បានធ្វើការដកស្រង់នូវការអនុម័តស្របគ្នានៅក្នុង *សំណុំរឿងក្តី The Prosecutor ទល់នឹង Vidoje Blagojević និង Dragan Jokić, សំណុំរឿងលេខ* (IT-02-60-T), អង្គជំនុំជម្រះសាលាដំបូង, សាលក្រម ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥, ត្រង់កថាខណ្ឌ ៥៧៦ ["អង្គជំនុំជម្រះសាលាដំបូងយល់ស្របជាមួយទស្សនៈនេះ ហើយមិនធ្វើការពិចារណាលើអត្ថិភាពនៃ 'ការចូលរួមសម្លាប់យ៉ាងទូលំទូលាយ' ជាធាតុផ្សំដាច់ដោយឡែកនៃឧក្រិដ្ឋកម្មឡើយ ហើយវាក៏មិនមែនជាស្រទាប់បន្ថែមមួយទៀតលើ *ចេតនាឧក្រិដ្ឋ* ដែលតម្រូវសម្រាប់ឧក្រិដ្ឋកម្មនោះដែរ"]) [**ភ្ជាប់ជាឯកសារសម្អាង៖ ៥**]។

សមស្រប និងមិនបានលើកតម្កើងអ្វីដល់អំណះអំណាងរបស់ សពអ ទេ[172] ។ វិធីសាស្ត្ររបស់ សចស មិនបានចាប់ផ្តើមដោយការបង្ហាញថា ចេតនាក្នុងការសម្លាប់ទ្រង់ទ្រាយធំមិនអាចត្រូវបានបង្កើតឡើងគ្រាន់តែដោយសារ "ក្រុមទីមួយនៃជនរងគ្រោះដែលស្ថិតនៅក្រោមការត្រួតត្រារបស់កងកម្លាំងគាត់នោះ មិនស្ថិតក្នុងចំនួនច្រើន"[173] នោះឡើយ ។ ផ្ទុយទៅវិញ សចស គ្រាន់តែបានសង្កេតឃើញថា នៅក្នុងកាលៈទេសៈទាំងនេះ និងផ្អែកលើភស្តុតាងនេះ ចេតនាចាំបាច់មិនអាចត្រូវបានគេទាញការយល់ឃើញដោយគ្មានភស្តុតាងចង្អុលបង្ហាញពីការមានចេតនា *ជាមុន*នោះទេ ។

៨៤. វានឹងគ្មានន័យអ្វីឡើយ ហើយវានឹងបំពានលើគោលការណ៍កំណត់លើបញ្ហាពិរុទ្ធភាព ក្នុងការដាក់ការទទួលខុសត្រូវចំពោះការសម្លាប់រង្គាលលើមេបញ្ជាការមិនប្រាកដ ដោយគ្មានការកំណត់ឱ្យឃើញថាការសម្លាប់ "ជនស៊ីវិលជាតិក្រុមតូចៗ" ត្រូវបានចាត់ទុកថាជាការសម្លាប់ទ្រង់ទ្រាយធំ ហើយដែលចេតនារបស់គាត់ទៀតសោត ក៏មានគ្រប់គ្រាន់ចូលរួមពាក់ព័ន្ធក្នុងព្រឹត្តិការណ៍ទាំងនោះដែរ ។ អាស្រ័យលើទំនាក់ទំនងភស្តុតាងរវាងព្រឹត្តិការណ៍សម្លាប់ទាំងនោះ តម្រូវការបង្ហាញភស្តុតាងនៃការមានចេតនា *ជាមុន* អាចជាមធ្យោបាយតែមួយគត់ដើម្បីឱ្យមានការជឿជាក់លើការមានចេតនាតម្រូវសម្រាប់និយមន័យនៃការសម្លាប់រង្គាល ។

***ii. ទោះក្នុងស្ថានភាពណាក៏ដោយ បើទោះបីជាកំហុសអង្គច្បាប់ត្រូវបានបង្កើតឡើងក្តី ក៏សហព្រះរាជអាជ្ញាអន្តរជាតិខកខានមិនបានតវ៉ា ឬបង្ហាញឱ្យឃើញថា កំហុសនោះបានបង្កឱ្យមានជាការរំលោភបំពានឆន្ទានុសិទ្ធិទាក់ទងនឹងដីកាដំណោះស្រាយដែរ***

៨៥. ក្នុងករណីណាក៏ដោយ បើទោះបីជាអំណះអំណាងមួយចំនួនក្នុងទឡ្ហីករណ៍ទី៣នៃបណ្តឹងឧទ្ធរណ៍មានគុណតម្លៃដែលសមនឹងទទួលយកបានក្តី ក៏ទឡ្ហីករណ៍ដែលបានស្នើឡើង ត្រូវបានធ្វើឡើងដោយខុសទំនង ។ សពអ ខកខានមិនបានធ្វើការតវ៉ា ឬបង្ហាញឱ្យឃើញថាមានកំហុសអង្គច្បាប់ណាមួយបង្កឱ្យមានការបំពានលើឆន្ទានុសិទ្ធិ ។

---

[172] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៤១ ។

[173] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៤១ ។

៨៦. ផ្ទុយទៅវិញ បើឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលត្រូវបានក្លាយជាឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ និងអាចបង្ហាញផ្លូវទៅរកការសម្រេចលើយុត្តាធិការបុគ្គល វានឹងមិនអាចរងការប៉ះពាល់ជាសត្យានុម័តដល់ដីកាដំណោះស្រាយឡើយ ។ ដូចដែល សចស បានសន្និដ្ឋានប្រកបដោយភាពសមហេតុសមផលដូច្នេះថា:

> ការកំណត់ប្រភេទបទល្មើសជាច្រើនដែលអាចមាន សម្រាប់អង្គហេតុតែមួយ (ជាឧទាហរណ៍ ការធ្វើទុក្ខបុកម្នេញ ឬអំពើអមនុស្សធម៌ដទៃទៀត ឬបទល្មើសមនុស្សឃាតតាមច្បាប់) អនុញ្ញាតឱ្យមានបទចោទប្រកាន់ជាច្រើន ហើយអាចនាំដល់ការផ្តន្ទាទោស ប៉ុន្តែបទចោទទាំងអស់នេះ មិនបានបង្កើតភាពធ្ងន់ធ្ងរនៃសកម្មភាពរបស់ [អ្នកស្រី] អ៊ឹម ចែម ឡើយ[174] ។

៨៧. អង្គហេតុនានាដែលទាក់ទងនឹងការសម្លាប់នៅឯមន្ទីរសន្តិសុខភ្នំត្រយោង ដែលនៅក្នុងសារណារបស់សហព្រះរាជអាជ្ញាអន្តរជាតិចាត់ទុកថា ឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល គឺត្រូវបានយកមកពិចារណាដើម្បីកំណត់យុត្តាធិការជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមរូបភាពជាការធ្វើមនុស្សឃាត[175] ។ ហេតុដូច្នេះ ការធ្វើចំណាត់ថ្នាក់ច្បាប់នៃបទឧក្រិដ្ឋមួយចំនួនដែលជាឧក្រិដ្ឋកម្មសម្លាប់រង្គាល ថាវាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អាចនឹងក្លាយជាការណែនាំឱ្យប្រើធាតុផ្សំផ្លូវច្បាប់ថ្មីៗ ប៉ុន្តែវានឹងមិនអាចជាការណែនាំឱ្យមានជនរងគ្រោះថ្មី (មនុស្សម្នាក់អាចក្លាយជាជនរងគ្រោះម្នាក់ ទោះបីជាពួកគេទទួលរងនូវឧក្រិដ្ឋកម្មពីរដងក៏ដោយ) ឬច្រើនជាងនេះបន្តិចបន្តួចដើម្បីបង្ហាញឱ្យឃើញនូវអំពើឧក្រិដ្ឋកាន់តែធ្ងន់ធ្ងរឡើយ ។ វានឹងមិនអាចធ្វើឱ្យមានការរងផលប៉ះពាល់ជាសត្យានុម័តនូវសេចក្តីសម្រេចទាំងមូល ឬក៏បានផ្តល់ជាមូលហេតុដែលកើតឡើងពីការរំលោភឆន្ទានុសិទ្ធិនោះទេ ។

៨៨. ដូចដែលបានរកឃើញដោយ សចស លក្ខណៈវិនិច្ឆ័យចម្បងមួយសម្រាប់ធ្វើការពិនិត្យពិចារណាលើបញ្ហាយុត្តាធិការបុគ្គលក្នុងសំណុំរឿងរបស់អ្នកស្រី អ៊ឹម ចែម គឺត្រូវបានពិចារណាលើទំហំ និង

---

[174] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ៣២៣ (សង្កត់ន័យបន្ថែមត្រង់អក្សរទ្រេត) ។

[175] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ២៨៥ ដល់ ២៨៨ ។

ភាពធ្ងន់ធ្ងរដែលបានឃើញតាមរយៈការវាយតម្លៃលើចំនួនជនរងគ្រោះដោយអំពើឧក្រិដ្ឋនានា ។ សរុបសេចក្តីទៅ សចស បានសន្និដ្ឋានដោយសមហេតុផលថា នៅពេលពិចារណាក្នុងបរិបទនៃរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល ចំនួននៃជនរងគ្រោះ គឺជាកត្តាដ៏មានឥទ្ធិពលមួយដែលបានជំទាស់នឹងសេចក្តីសន្និដ្ឋានលើបញ្ហាយុត្តាធិការបុគ្គល[176] ។ ក្នុងន័យនេះ សចស បានចាត់ទុកផលប៉ះពាល់នៃការរកឃើញ ពាក់ព័ន្ធនឹងជនរងគ្រោះដែលត្រូវបានប៉ាន់ស្មានថាមានចំនួនប្រហែលជា ២.០០០ នាក់នៅមន្ទីរសន្តិសុខភ្នំត្រយោង[177] ដោយពិនិត្យមើលទៅលើ "បរិបទនៃព្យសនកម្មទាំងអស់ដែលបណ្តាលមក ពីការអនុវត្តគោលនយោបាយរបស់របបនេះ ហើយនិង ... ចំនួនអ្នកស្លាប់សរុប ... នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ"[178] ។ និយាយម្យ៉ាងទៀត សចស បានធ្វើការវិនិច្ឆ័យដោយយកលំនាំពាក់ព័ន្ធសំខាន់បំផុតនៃភស្តុតាង ។ វាមិនអាចជា អះអាងដែលសមហេតុផលនោះទេដែលថា៖ ការធ្វើចំណាត់ថ្នាក់ផ្លូវច្បាប់ជាថ្មីនៃការសម្លាប់រង្គាល (ដែលមិនមែនជាការកែប្រែនូវការពិចារណា ឬការវាយតម្លៃទាំងនេះ) គឺមិនអាចមានឥទ្ធិពលជាសត្យានុម័តនូវការវាយតម្លៃថាតើលក្ខខណ្ឌកំណត់នៃយុត្តាធិការបុគ្គលអាចត្រូវបានបំពេញឬយ៉ាងណា ។

៨៩. លើសពីនេះ ចំពោះលក្ខណៈវិនិច្ឆ័យសេសសល់ដែលបានអនុវត្តដោយ សចស ក្នុងការកំណត់ជាទូទៅលើបញ្ហាយុត្តាធិការបុគ្គល ឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលដែលបានចោទប្រកាន់ថាបានកើតមាននៅក្នុងមន្ទីរសន្តិសុខភ្នំត្រយោង នឹងមិនលាតសន្ធឹងវិសាលភាពភូមិសាស្ត្រនៃការចោទប្រកាន់ប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម ឡើយ[179] និងមិនអាចធ្វើការលើកតម្កើងឋានៈផ្លូវការរបស់អ្នកស្រីនៅក្នុងឋានានុក្រមខ្មែរក្រហមបានដែរ[180] ព្រមទាំងមិនអាចកែប្រែនូវការពិតដែលថា មានកម្មាភិបាលច្រើនជាងមួយរយនាក់ផ្សេងទៀត ដែលមានឋានៈស្មើនឹងអ្នកស្រីនៅក្នុងអំឡុងពេលវេលាពាក់ព័ន្ធ

[176] ដីកាដំណោះស្រាយ, ឯកសារ D308/3 ត្រង់កថាខណ្ឌ ៣១៩ ដល់៣២០ ។

[177] ដីកាដំណោះស្រាយ, ឯកសារ D308/3 ត្រង់កថាខណ្ឌ ១៨៩ ។

[178] ដីកាដំណោះស្រាយ, ឯកសារ D308/3 ត្រង់កថាខណ្ឌ ៣១៧ ។

[179] ដីកាដំណោះស្រាយ, ឯកសារ D308/3 ត្រង់កថាខណ្ឌ ៣១៣ ។

[180] ដីកាដំណោះស្រាយ, ឯកសារ D308/3 ត្រង់កថាខណ្ឌ ៣១៥ ។

នោះ[181] ។

៩០. សរុបសេចក្តីទៅ សពអ បានបរាជ័យក្នុងការដោះស្រាយបញ្ហាដ៏សំខាន់ទាំងនេះ ប្រកបដោយភាពយុត្តិធម៌ ឬឱ្យមានលក្ខណៈសមហេតុផល ។ មិនត្រឹមតែប៉ុណ្ណោះ សពអ បានខកខានមិនបានធ្វើការតវ៉ា កុំថាដល់ទៅធ្វើការបង្ហាញឱ្យឃើញនូវកំហុសឆ្គងណាមួយដែលនាំឱ្យមានការរំលោភឆន្ទានុសិទ្ធិ ។ អាស្រ័យហេតុនេះហើយ ទឡ្ហីករណ៍នេះគួរតែត្រូវបានច្រានចោល ។

**ឃ. ទឡ្ហីករណ៍ទី៤÷ សចស គ្មានកំហុសអង្គច្បាប់នៅពេលធ្វើការកំណត់និយមន័យឧក្រិដ្ឋកម្មនៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ និងការអនុវត្តនិយមន័យនេះលើការឃើញនេះ នៅក្នុងដីកាដំណោះស្រាយ**

៩១. សពអ បានលើកឡើងថា សចស មានកំហុស ដោយការមិនដាក់ឱ្យអ្នកស្រី អ៊ឹម ចែម ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការបាត់ខ្លួនដោយបង្ខំ ថាជាអំពើអមនុស្សធម៌មួយផ្សេងទៀតដែលបានប្រព្រឹត្តទៅនៅការដ្ឋានស្ពានស្រែង[182] ។ ជាពិសេស សពអ បានអះអាងថា សចស មានកំហុសដោយអនុវត្តនិយមន័យទំនើបនៃការបាត់ខ្លួនដោយបង្ខំ និងមិនមែនធាតុផ្សំនានានៃអំពើអមនុស្សធម៌ផ្សេងទៀត[183] ហើយដោយតម្រូវឱ្យមានធាតុបន្ថែមមួយទៀត ពោលគឺភស្តុតាងដែលមានជនមួយចំនួន គួរតែត្រូវបានស្វែងរកព័ត៌មានអំពីកន្លែងលាក់ខ្លួនរបស់បុគ្គលដែលត្រូវបានឃុំខ្លួន[184] ។

៩២. ដូចដែលបានរៀបរាប់លម្អិតខាងលើនៅកថាខណ្ឌ១៧ ដល់កថាខណ្ឌ១៩ ក្រុមការពារក្តីយល់ឃើញថា ទឡ្ហីករណ៍ទី៤ មិនគួរនឹងទទួលយក ហើយគួរត្រូវច្រានចោល ។ ជាលទ្ធផល ដីការសម្រេចរបស់ សចស ដែលថា អ.វ.ត.ក ខ្វះយុត្តាធិការបុគ្គល គឺជាសំណួរចោទគឺនៅត្រង់ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អ្នកស្រី អ៊ឹម ចែម ចំពោះការបាត់ខ្លួនដោយបង្ខំ មិនបានស្តែងឱ្យឃើញឡើង

---

[181] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ៣១៦ ។

[182] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៤៧ ។

[183] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៤៧-៥១ ។

[184] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៤៧ និងត្រង់កថាខណ្ឌ ៥២ ដល់ ៥៧ ។

សម្រាប់ត្រូវធ្វើការពិចារណាទៅវិញទេ ។ លើសពីនេះ ដូចដែលបានលើកឡើងខាងលើនៅក្នុងកថាខណ្ឌ២០ ដល់កថាខណ្ឌ២៣ ទឡ្ហីករណ៍ទី៤ គឺជាសំណើមិនអាចអនុញ្ញាតបានមួយ ចំពោះករណីស្នើសុំឱ្យមានការពិនិត្យមើលឡើងវិញនូវវិធីសាស្ត្ររបស់ សចស លើការកំណត់ខ្សែបន្ទាត់ជាក់លាក់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការបាត់ខ្លួនដោយបង្ខំ ថាជាអំពើអមនុស្សធម៌ផ្សេងទៀតឡើយ ហេតុដូច្នេះ សំណើនេះ វាស្ថិតនៅក្រៅវិសាលភាពនៃអំណាចរបស់ អបជ ក្នុងការពិនិត្យឡើងវិញ ។

៩៣. បើសិនជាទឡ្ហីករណ៍ទី៤អាចត្រូវបានទទួលយកក៏ដោយ ក៏គុណតម្លៃរបស់វាគួរត្រូវបានច្រានចោលដែរ ។ ក្រុមការពារក្តីសន្មតថា i) សពអ បានបកស្រាយខុសវិធីសាស្ត្ររបស់ សចស ចំពោះនិយមន័យនៃបទឧក្រិដ្ឋនៃការបាត់ខ្លួនដោយបង្ខំ និង ii) បើទោះបីជាមានកំហុសអង្គច្បាប់ និង/ឬអង្គហេតុត្រូវបានបង្ហាញក៏ដោយ ក៏ សពអ ខកខានមិនធ្វើការតវ៉ា ឬបង្ហាញឱ្យឃើញថាមានការរំលោភឆន្ទានុសិទ្ធិ ដែលទាក់ទងទៅនឹងដីកាសម្រេចដែលរងការជំទាស់ ។

***i. សពអ បានបកស្រាយខុសនូវវិធីសាស្ត្ររបស់ សចស ចំពោះនិយមន័យបទឧក្រិដ្ឋនៃការបាត់ខ្លួនដោយបង្ខំ***

៩៤. មានការគាំទ្រតិចតួចសម្រាប់សេចក្តីអះអាងរបស់ សពអ ដែលថា សចស បានអនុវត្តប្រាសចាកពីនិយមន័យនៃការបាត់ខ្លួនដោយបង្ខំថាជាអំពើអមនុស្សធម៌ផ្សេងទៀត ដែលស្ថិតនៅក្រោមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[185] ។ សចស បានថ្លែងបញ្ជាក់នូវអង្គច្បាប់យ៉ាងត្រឹមត្រូវ និងបានអនុវត្តតាមនិយមន័យរបស់អង្គជំនុំជម្រះតុលាការកំពូល ចំពោះនិយមន័យនៃអំពើអមនុស្សធម៌ដទៃផ្សេងទៀតដែលស្ថិតក្រោមឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[186] ហើយបានរកឃើញថា ការបាត់ខ្លួនដោយបង្ខំ "អាចមានលក្ខណៈគ្រប់គ្រាន់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត"[187] ។

---

[185] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៤៨ ។ *សូមមើលផងដែរ*, បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៤៨ ដល់ ៥១ ។

[186] ដីកាដំណោះស្រាយ ឯកសារ **D308/3** ត្រង់កថាខណ្ឌ ៧៤ *យោងលើ* សាលដីកានៃសំណុំរឿង០០២/១, ឯកសារ **F36** កថាខណ្ឌ ៥៨០ ។

[187] ដីកាដំណោះស្រាយ ឯកសារ **D308/3** ត្រង់កថាខណ្ឌ ៧៥ ។

### *ii. សពអ ខកខានមិនបានធ្វើការតវ៉ា ឬបង្ហាញឱ្យឃើញថាមានការរំលោភបំពានឆន្ទានុសិទ្ធិ ដែលទាក់ទងនឹងការបាត់ខ្លួនដោយបង្ខំនៅការដ្ឋានស្ពានស្រែង*

៩៥. សពអ បានថ្លែងការពារថា បើសិនជា សចស បានអនុវត្តនិយមន័យច្បាប់ត្រឹមត្រូវលើបញ្ហាអង្គហេតុវិញនោះ ម្ល៉េះសមអ្នកស្រី អ៊ឹម ចែម នឹងត្រូវបានរកឃើញថាបានទទួលខុសត្រូវចំពោះការបាត់ខ្លួនដោយបង្ខំនៅការដ្ឋានស្ពានស្រែង[188] ។ ជាងនេះទៅទៀត សពអ បានលើកហេតុផលថា សចស មានកំហុសអង្គច្បាប់ និងអង្គហេតុដោយការតម្រូវថាឱ្យមានភស្តុតាងបញ្ជាក់ថាគ្រួសារ ឬ មិត្តភក្តិបានធ្វើការស្វែងរកព័ត៌មានអំពីជោគវាសនា ឬ ទីកន្លែងរបស់ជនដែលបានបាត់ខ្លួន[189] ។ សពអ បានទាមទារថា នៅក្នុងបរិបទទូទៅនៃរបបខ្មែរក្រហមដែលតម្រូវឱ្យបុគ្គលម្នាក់គប្បីស្វែងរកព័ត៌មាន[ទាក់ទងនឹងការបាត់ខ្លួន]ពីអង្គការនេះគឺ "មិនមានភាពប្រាកដនិយមទាល់តែសោះ"[190] ។ ទោះជាយ៉ាងណា ដូចដែលបានលើកឡើងខាងក្រោម វិធីសាស្ត្ររបស់ សពអ ចំពោះដីកាសម្រេចដែលរងការជំទាស់ គឺជាការយល់ខុស ។

៩៦. យ៉ាងហោចណាស់ សពអ ត្រូវតែបង្ហាញថាផលវិបាកនៃការខកខានមិនបានធ្វើការពិចារណាពីការបាត់ខ្លួនដោយបង្ខំ គឺជាហេតុផលនៃការធ្វើមោឃភាពលើដីកាសម្រេចដែលរងការជំទាស់ ។ ដូច្នេះ ទោះបីជា សពអ បានចង្អុលភស្តុតាងយ៉ាងត្រឹមត្រូវថាវិធីសាស្ត្ររបស់ សចស មានកំហុសក៏ដោយ ក៏ សពអ បានបរាជ័យក្នុងការចាត់វិធានការបន្តបន្ទាប់ទៀត៖ ធ្វើការបង្ហាញឱ្យជឿបានថាមានការបាត់ខ្លួនដោយបង្ខំមួយចំនួនត្រូវបានកើតឡើង ដើម្បីបង្កើតឱ្យមាននូវទំនាក់ទំនងគ្រប់គ្រាន់រវាងអ្នកស្រី អ៊ឹម ចែម និងការបាត់ខ្លួនដោយបង្ខំនានា ដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តទៅនៅការដ្ឋានស្ពានស្រែង និងធ្វើការចង្អុលបង្ហាញឱ្យឃើញថាឧក្រិដ្ឋកម្មទាំងនេះ បានពង្រីកនូវទំហំនៃការទទួលខុសត្រូវរបស់អ្នកស្រីចំពោះឧក្រិដ្ឋកម្មពាក់ព័ន្ធនានា ដោយសារតែ ផលវិបាកនៃការរកឃើញណាមួយស្តីពីបញ្ហាកង្វះយុត្តាធិកាបុគ្គល បង្កឱ្យមានការការរំលោភបំពានឆន្ទានុសិទ្ធិ ។ ដូច

188 បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៥១ ។

189 បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៥២ ។

190 បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៥៣ ។

ដែលបណ្តឹងឧទ្ធរណ៍របស់ សពអ បង្ហាញក្នុងកថាខណ្ឌ ៥២ ដល់ ៥៧ សពអ មិនខ្វល់នឹងអនុវត្តនូវជំហានដ៏សំខាន់ទាំងនេះទេ ។ ទឡ្ហីករណ៍ទី៤ គួរត្រូវបានច្រានចោល ដោយសារមានវិការៈ ។

៩៧. លើសពីនេះទៀត សេចក្តីសំអាងហេតុរបស់ សពអ ទៅលើករណីយុត្តិសាស្ត្រនៃតុលាការសិទ្ធិមនុស្សអន្តរអាមេរិកាំង ("IACHR") មិនបានផ្តល់ការគាំទ្របន្ថែមអ្វីចំពោះការអះអាងថា អ្នកវិនិច្ឆ័យអង្គហេតុដែលមានហេតុផល អាចនឹងត្រូវបានរកឃើញពីទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់អ្នកស្រី អ៊ឹម ចែម លើការបាត់ខ្លួនដោយបង្ខំ[191] ។ IACHR គឺជាតុលាការសិទ្ធិមនុស្សដែលមានវិធីសាស្ត្រផ្សេងគ្នាចំពោះបទដ្ឋាន និងបន្ទុកនៃការបង្ហាញភស្តុតាងមិនអាចបង្រួមចូលគ្នាបានជាមួយនឹងវិធីសាស្ត្រតុលាការទាំងឡាយណា ដែលមានដំណើរការនីតិវិធីព្រហ្មទណ្ឌ ឬបទដ្ឋាននីតិវិធីត្រឹមត្រូវដែលកំពុងត្រូវបានពិចារណានៅក្នុងករណីជាក់លាក់នេះទេ[192]

៩៨. ទីមួយ ការរកឃើញថា "ការចាប់ខ្លួន និងការបាត់ខ្លួនកម្មករ ឃើញកើតមានជាទូទៅនៅការដ្ឋានប្រឡាយស្ពានស្រែង"[193] គឺមិនគ្រប់គ្រាន់ឡើយ ក្នុងការបង្ហាញឱ្យឃើញពី*ធាតុផ្សំសត្យានុម័ត* និង *ធាតុផ្សំអត្តនោម័ត* នៃឧក្រិដ្ឋកម្មនៃការបាត់ខ្លួនដោយបង្ខំ ។ វាមិនអាចសន្មតបានថាការចាប់ខ្លួន និងការបាត់ខ្លួនដោយបង្ខំ បំពេញដោយស្វ័យប្រវត្តិចំពោះធាតុផ្សំទាំងនេះនៃឧក្រិដ្ឋកម្ម ពោលគឺ ការប្រព្រឹត្តដោយសកម្ម និងអកម្មណាមួយដោយមានចេតនាបង្កការឈឺចាប់យ៉ាងធ្ងន់ធ្ងរលើរូបរាងកាយ ឬផ្លូវចិត្ត[194] ។ ការអះអាងរបស់ សពអ ដែលថា "ការប៉ះទង្គិចផ្លូវចិត្ត និងការឈឺចាប់ចំពោះអ្នកនៅស្ពានស្រែងក៏មិនខុសគ្នាដែរ" ពីការរកឃើញនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/១[195]

---

[191] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៥៣ ដល់ ៥៥ ។

[192] *សូមមើលឧទាហរណ៍*, សំណុំរឿងរបស់ *Godinez Cruz ទល់នឹង Honduras* ឆ្នាំ ១៩៨៩, IACHR (ser. C), សេចក្តីសម្រេច ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៨៩, ត្រង់កថាខណ្ឌ ១៤០ និង ១៤១ ["ផ្ទុយទៅនឹងច្បាប់ព្រហ្មទណ្ឌជាតិ នៅក្នុងកិច្ចដំណើរការនីតិវិធីកំណត់ពីការរំលោភសិទ្ធិមនុស្សនានា រដ្ឋមិនអាចពឹងផ្អែកលើការការពារថាម្ចាស់បណ្តឹងបានបរាជ័យក្នុងការបង្ហាញភស្តុតាង នៅពេលដែលភស្តុតាងនោះ មិនអាចរកបានដោយគ្មានកិច្ចសហប្រតិបត្តិការរបស់រដ្ឋ"] [**ភ្ជាប់ជាឯកសារសម្អាង៖ ៣០**]។

[193] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៥១ *យោងលើ* ដីកាដំណោះស្រាយ ត្រង់កថាខណ្ឌ ២៣៨ ។

[194] ដីកាដំណោះស្រាយ ឯកសារ **D308/3** ត្រង់កថាខណ្ឌ ៧៤ ។

[195] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៥១ ។

គឺជាការលើកឡើងដែលគ្មានមូលដ្ឋានគ្រប់គ្រាន់ ដើម្បីចង្អុលបង្ហាញឱ្យឃើញពីការប្រព្រឹត្តទៅនៃឧក្រិដ្ឋកម្មទាំងនេះ ។

៩៩. លើសពីនេះ វាជាមូលដ្ឋានមិនពេញលេញមួយក្នុងការសន្និដ្ឋានពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អ្នកស្រី អ៊ឹម ចែម ។ ទោះបីជា សចស មានកំហុសក្នុងការតម្រូវឱ្យមានធាតុផ្សំបន្ថែមមួយទៀតក៏ដោយ[196] ក៏ការខកខានមិនបានតវ៉ារបស់ សពអ ទៅលើចំណងទាក់ទងពេញលេញមួយរវាងអ្នកស្រី អ៊ឹមចែម និងការបាត់ខ្លួនដោយបង្ខំដែលត្រូវបានចោទប្រកាន់នៅក្នុងការដ្ឋានស្ពានស្រែងព្រមទាំងរបៀបដែលការសំអាងលើឧក្រិដ្ឋកម្មទាំងមូល (រួមទាំងភាពសរុបរួមនូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់ និងការដាក់ឃុំឃាំង ដែលត្រូវបានកំណត់ និងថ្លឹងថ្លែងត្រឹមត្រូវ[197]) ការកំណត់លក្ខណៈផ្លូវច្បាប់ចំពោះបទល្មើសនៃការបាត់ខ្លួនដោយបង្ខំ អាចនឹងត្រូវបានកែប្រែការវាយតម្លៃជាទូទៅនៃយុត្តាធិការបុគ្គល[198] គឺសំខាន់ណាស់ ។ សរុបមក សពអ ខកខានមិនបានធ្វើការតវ៉ា កុំថាឡើយថាគាត់បានបង្កើតឱ្យឃើញនូវរបៀបដែលកំហុសណាមួយបានបណ្តាលឱ្យមានការរំលោភឆន្ទានុសិទ្ធិ ។ ហេតុដូច្នេះហើយ ទឡ្ហីករណ៍ទី៤ គួរតែត្រូវបានច្រានចោល ។

**ខ. ទឡ្ហីករណ៍ទី៥ និងទឡ្ហីករណ៍ទី៦៖ សពអ បានបកស្រាយខុស អំពីមុខតំណែងដែលថាការរកឃើញជាក់ស្តែងទាក់ទងនឹងតួនាទីរបស់ អ៊ឹម ចែម នៅក្នុងភូមិភាគនិរតី ប្រើសម្រាប់វាយតម្លៃលើយុត្តាធិការបុគ្គល**

១០០. សពអ បានលើកជាហេតុផលថា "មិនមាន[អ្នក]វិនិច្ឆ័យអង្គហេតុដ៏សមហេតុផលណាអាចរកឃើញថា [អ្នកស្រី] អ៊ឹម ចែម មិនមែនជាលេខាស្រុកកោះអណ្តែត[នោះទេ]" ចំណែកតួនាទីអ្នកស្រី "ជាសមាជិកគណៈតំបន់១៣" ផ្អែកតាមការពិនិត្យដ៏ត្រឹមត្រូវលើភស្តុតាង[199] ។ ទាក់ទិននឹង

---

[196] ដីកាដំណោះស្រាយ ឯកសារ **D308/3** ត្រង់កថាខណ្ឌ ៣០២ ។

[197] ដីកាដំណោះស្រាយ ឯកសារ **D308/3** ត្រង់កថាខណ្ឌ ៦៧ (ការសម្លាប់), កថាខណ្ឌ ៧០ (ការដាក់ឃុំឃាំង) ។

[198] *សូមមើល*, ដីកាដំណោះស្រាយ ឯកសារ **D308/3** ត្រង់កថាខណ្ឌ ៣២៣ ។ *សូមមើលផងដែរ*, ដីកាដំណោះស្រាយ ឯកសារ **D308/3** ត្រង់កថាខណ្ឌ ៣១៣, ៣១៥, ៣១៦ និងកថាខណ្ឌ ៣១៩ ដល់ ៣២០ ។

[199] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៥៨ (ទឡ្ហីករណ៍ទី៥) និង កថាខណ្ឌ ៧០ (ទឡ្ហីករណ៍ទី៦) ។

ទឡ្ហីករណ៍ទី៥ និងទឡ្ហីករណ៍ទី៦ សពអ បានអះអាងថា សចស ខកខានក្នុងការរកឃើញថា អ្នកស្រី អ៊ឹម ចែម បានកាន់តំណែងទាំងពីរនេះ "បង្ហាញឱ្យឃើញថាវាជាមូលហេតុដែលដីកាដំណោះស្រាយមិនលើកយកការចោទប្រកាន់ទាំងឡាយរបស់សហព្រះរាជអាជ្ញាដែលថា [អ្នកស្រី] អ៊ឹម ចែម បានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម (JCE) នៅភូមិភាគនិរតី"[200] ។

១០១. ទឡ្ហីករណ៍ទី៥ និងទឡ្ហីករណ៍ទី៦ គួរតែត្រូវច្រានចោលដោយមិនបង្អង់ ។ អបជ ធ្លាប់បានសម្រេចថា រាល់អំណះអំណាងនានារបស់ភាគីដែលមិនមានសក្តានុពលបង្កឱ្យមានសេចក្តីសម្រេចរងការជំទាស់ក្នុងការបដិសេធចោល ឬកែសម្រួលឡើងវិញអាចនឹងត្រូវច្រានចោលភ្លាមៗដោយ អបជ ហើយក៏មិនចាំបាច់ត្រូវធ្វើការពិចារណាលើអង្គសេចក្តីដែរ[201] ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTY បានសន្និដ្ឋានថានៅពេលអំណះអំណាងទាំងឡាយណាដែលគ្មានភាពពាក់ព័ន្ធ[202] មិនបានបរិយាយឱ្យបានល្អិតល្អន់ ថាតើកំហុសនៃអង្គហេតុដែលបានចោទប្រកាន់នោះបានបង្កផលប៉ះពាល់ដូចម្តេចខ្លះទៅលើអំណះអំណាងដែលបានធ្វើការជំទាស់តវ៉ា[203] ឬក៏គ្រាន់តែធ្វើការអះអាងថាភស្តុតាងពាក់ព័ន្ធមិនត្រូវបានវាយតម្លៃឱ្យបានត្រឹមត្រូវ[204] ភស្តុតាងមិនត្រូវបានផ្តល់ទម្ងន់គ្រប់គ្រាន់ ឬមិនត្រូវបានបកស្រាយនៅក្នុងលក្ខណៈជាក់លាក់ណាមួយ[205] ។

---

[200] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៨១ ។

[201] *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿង លេខ ០០២/១៩-០៩-២០០៧/អវកត/កសចស (អ.ប.ជ. ៤៧ និង ៤៨)*, សាលដីកាលើបណ្តឹងឧទ្ធរណ៍លើដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតលេខ D250/3/3 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០ និងដីកាសម្រេចលេខ D250/3/2 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ២០១០ លើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១០, ឯកសារ **D250/3/2/1/5** នៅកថាខណ្ឌ ២២ ។

[202] *សូមមើល, រឿងក្តីរបស់ Prosecutor ទល់នឹង Momčilo Krajišnik*, រឿងក្តីលេខ (IT-00-39-A), អង្គជំនុំជម្រះសាលាឧទ្ធរណ៍, សាលដីកា ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩, ត្រង់កថាខណ្ឌ ២០ [**ភ្ជាប់ជាឯកសារសម្អាង៖ ១១**]។

[203] *សូមមើល, រឿងក្តីរបស់ Prosecutor ទល់នឹង Momčilo Krajišnik*, រឿងក្តីលេខ (IT-00-39-A), អង្គជំនុំជម្រះសាលាឧទ្ធរណ៍, សាលដីកា ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩, ត្រង់កថាខណ្ឌ ២៣ [**ភ្ជាប់ជាឯកសារសម្អាង៖ ១១**] ។

[204] *រឿងក្តីរបស់ Prosecutor ទល់នឹង Momčilo Krajišnik*, រឿងក្តីលេខ (IT-00-39-A), អង្គជំនុំជម្រះសាលាឧទ្ធរណ៍, សាលដីកា ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩, ត្រង់កថាខណ្ឌ ១៩ [**ភ្ជាប់ជាឯកសារសម្អាង៖ ១១**] ។

[205] *សូមមើល, រឿងក្តីរបស់ Prosecutor ទល់នឹង Momčilo Krajišnik*, រឿងក្តីលេខ (IT-00-39-A), អង្គជំនុំជម្រះសាលាឧទ្ធរណ៍, សាលដីកា ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩, ត្រង់កថាខណ្ឌ ២៧ [**ភ្ជាប់ជាឯកសារសម្អាង៖ ១១**] ។

១០២. លើសពីនេះ ដើម្បីលើកឡើងនូវមូលដ្ឋានដែលអាចតវ៉ាបាននៃបណ្តឹងឧទ្ធរណ៍នៅក្នុងទឡ្ហីករណ៍ទី៥ ឬទឡ្ហីករណ៍ទី៦ សពអ ត្រូវបានតម្រូវឱ្យសំដៅទៅលើដីកាដំណោះស្រាយទាំងស្រុង និងធ្វើការបង្ហាញឱ្យឃើញថា៖ i) ដីកាដំណោះស្រាយមិនបានដោះស្រាយនូវការចោទប្រកាន់នានារបស់សពអ ដែលថា អ្នកស្រី អ៊ឹម ចែម បានចូលរួមពាក់ព័ន្ធនៅក្នុងភូមិភាគនិរតី និង ii) សេចក្តីសន្និដ្ឋានទាំងឡាយណាដែលអ្នកស្រី អ៊ឹម ចែម មិនមែនជាលេខាស្រុក និងជាសមាជិកគណៈតំបន់នៅក្នុងភូមិភាគនិរតីត្រូវបានបង្កើតឡើងដោយការមានកំហុស ហើយបាននាំឱ្យមានការរំលោភបំពានលើឆន្ទានុសិទ្ធិដើម្បីឈានដល់ការសន្និដ្ឋានដែលថា អ.វ.ត.ក ខ្វះយុត្តាធិការលើ រូបអ្នកស្រី ។

១០៣. ផ្ទុយទៅវិញ វិធីសាស្ត្ររបស់ សពអ ក្នុងការប្តឹងឧទ្ធរណ៍ គឺប៉ុនប៉ងបញ្ចុះបញ្ចូលឱ្យ អបជ សើរើអង្គហេតុសារជាថ្មី និងដាក់ជំនួសទស្សនទានរបស់ សចស ជារបស់ខ្លួនវិញ[206] ។ មិនត្រឹមតែប៉ុណ្ណោះទៀតសោត ការប៉ុនប៉ងនេះថែមទាំងមិនយកចិត្តទុកដាក់នឹងបទដ្ឋានវាយតម្លៃដ៏សំខាន់បំផុត ហើយជំរុញឱ្យការអានមិនពេញលេញ និងការអានជាបំណែកៗនៃហេតុផលជាមូលដ្ឋាន និងដីកាដំណោះស្រាយ ។ ជារួម បណ្តឹងឧទ្ធរណ៍ខកខានមិនបានធ្វើការកំណត់អត្តសញ្ញាណនៃកំហុសអង្គហេតុពាក់ព័ន្ធនានា និងបោះបង់ចោលនូវចេតនាទាំងឡាយ ដើម្បីធ្វើការដោះស្រាយលើបញ្ហាបទដ្ឋានពិនិត្យឡើងវិញនៃបណ្តឹងឧទ្ធរណ៍ ។

១០៤. ជារួមទៅ ទឡ្ហីករណ៍ទី៥ និងទឡ្ហីករណ៍ទី៦ គឺមិនមានគុណវុឌ្ឍិទេ ។ អ្នកស្រី អ៊ឹម ចែម មិនបានរងការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងភូមិភាគនិរតីឡើយ[207] ។ សចស មិនមានសិទ្ធិបញ្ជូនទៅធ្វើការជំនុំជម្រះចំពោះបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ថាបានកើតឡើងនៅក្នុងទីតាំងនោះទេ[208] ។ ទោះបីជាយ៉ាងណាក្តី សចស បានពិចារណាលើការចោទប្រកាន់នានារបស់ សពអ ដែលមាននៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់គាត់ (ទាក់ទិននឹងសិទ្ធិអំណាចរបស់អ្នកស្រី

[206] *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿង លេខ ០០២/១៩-០៩-២០០៧/អវតក/កសចស (អ.ប.ជ. ២៥),* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុក នៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៩, ឯកសារ **D164/3/6** នៅកថាខណ្ឌ ២៦ ។

[207] សេចក្តីជូនដំណឹងពីបទចោទប្រកាន់, ឯកសារ **D239.1** ។

[208] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ២៤៥ ។

អ៊ឹម ចែម នៅក្នុងភូមិភាគនិរតី) ហើយបានសន្និដ្ឋានថា ការដាក់បញ្ចូលបទចោទប្រកាន់ទាំងនោះ នឹងមិនប៉ះពាល់ដល់ការសន្និដ្ឋានថាអ្នកស្រីស្ថិតនៅក្រៅដែនយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែរ[209] ។ ហេតុដូច្នេះ សពអ មិនបានបង្ហាញថាតើសេចក្ដីសន្និដ្ឋានរបស់ សចស មានកំហុសយ៉ាងដូចម្ដេច ក្នុងការរកឃើញថាអ្នកស្រី អ៊ឹម ចែម មិនមែនជាលេខាស្រុក និងជាសមាជិកគណៈតំបន់នៅក្នុងភូមិភាគនិរតី និងថាតើការរកឃើញបែបនេះអាចនឹងមានការជាប់ទាក់ទង ឬភាពជឿជាក់បាននៃការវាយតម្លៃណាមួយលើបញ្ហាយុត្តាធិការបុគ្គល ហើយដែលដីកាដំណោះស្រាយ គឺដោយសារការរំលោភបំពានលើឆន្ទានុសិទ្ធិ ។ ដូច្នេះហើយ ទឡ្ហីករណ៍ទី៥ និងទឡ្ហីករណ៍ទី៦ គួរត្រូវច្រានចោល ។

១០៥. ដូចដែលបានលើកហេតុផលបន្ថែមខាងក្រោម ការអះអាងទាមទាររបស់ សពអ មិនអាចបង្កើតបានជាកំហុសពាក់ព័ន្ធណាមួយ ឬការបញ្ជាក់ឱ្យឃើញនូវការរំលោភបំពានឆន្ទានុសិទ្ធិណាមួយឡើយ ។

### *i. ទឡ្ហីករណ៍ទី៥៖ សចស បានសន្និដ្ឋានដោយសមហេតុផលថាអ្នកស្រី អ៊ឹម ចែម មិនមែនជាលេខាស្រុកកោះអណ្ដែតឡើយ*

១០៦. សពអ បានទាមទារថា "ពុំមានអ្នកវិនិច្ឆ័យអង្គហេតុដ៏មានហេតុផលណាអាចរកឃើញថា [អ្នកស្រី] អ៊ឹម ចែមមិនមែនជាលេខាស្រុកកោះអណ្ដែតទេ ដោយផ្អែកទៅលើការពិនិត្យឡើងវិញនូវភស្តុតាង"[210] ។ សពអ បានអះអាងថា សចស មិនធ្វើការវាយតម្លៃឱ្យបានត្រឹមត្រូវលើកិច្ចសម្ភាសន៍របស់អ្នកស្រី អ៊ឹម ចែម[211] ដោយចោទប្រកាន់ថាវាជាភស្តុតាងដែលត្រូវបានបញ្ជាក់គាំទ្រដោយសាក្សីផ្សេងទៀត[212] ក្នុងការបង្ហាញ "ពីមុខនាទីរបស់គាត់ ជាលេខាស្រុកកោះអណ្ដែត"[213] ។

---

209 ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ២៤៦ ។

210 បណ្ដឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៥៨ ។

211 បណ្ដឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៥៩ ដល់ ៦២ *យោងលើ* កិច្ចសម្ភាសន៍របស់ DC-Cam ជាមួយ អ៊ឹម ចែម ធ្វើនៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨, ឯកសារ **D123/1/5.1b** ។ កិច្ចសម្ភាសន៍របស់ DC-Cam ជាមួយ អ៊ឹម ចែម ធ្វើនៅថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០១២, ឯកសារ **D123/1/5.1c** ។

212 បណ្ដឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៦៣ ។

ដោយការពិនិត្យឡើងវិញយ៉ាងហ្មត់ចត់នៃដីកាដំណោះស្រាយ និងភស្តុតាងដែលបានកំណត់យក បង្ហាញឱ្យឃើញថា វិធីសាស្ត្ររបស់ សចស ចំពោះភស្តុតាងគឺសមហេតុផល[214] ។ លើសពីនេះ ទៅទៀត ដូចដែលបានរៀបរាប់ខាងក្រោមគ្មានអង្គជំនុំជម្រះមានហេតុផលណាមួយ អាចអនុម័ត វិធីសាស្ត្របច្ចុប្បន្ន ដែលបង្ខំឱ្យប្រើដោយ សពអ នោះទេ ។

១០៧. វិធីសាស្ត្ររបស់ សចស ចំពោះកិច្ច សម្ភាសន៍របស់អ្នកស្រី អ៊ឹម ចែម ជាមួយ DC-Cam គឺជា ការយល់ឃើញប្រដំប្រសងគ្នាជាមួយគោលការណ៍ជាមូលដ្ឋាននានា ដែលគ្រប់គ្រងនូវកិច្ចដំណើរ ការនីតិវិធីនៃរបស់ អ.វ.ត.ក ទាំងមូល បូករួមទាំងអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះ តុលាការកំពូល[215] ។ សចស បានសុខចិត្តទទួលយកដោយសមរម្យថា "ការស្តាប់ចម្លើយរបស់ មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានបង្កើតឡើងដោយមិនមានការធានាតាមផ្លូវ និងទម្រង់ដែល កំណត់លក្ខណៈនៃកំណត់ហេតុស្តាប់ចម្លើយនោះឡើយ"[216] ហើយត្រូវតែ "ផ្តល់ទម្ងន់តិចតួចជាង ការស្តាប់ចម្លើយដែលបានធ្វើឡើងដោយ ក.សចស"[217] ។ សចស បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា ពួកគាត់អាចត្រូវបាន "ពឹងផ្អែកតែក្នុងករណីដែលទទួលបានការគាំទ្រដោយប្រភពផ្សេងទៀត ប៉ុណ្ណោះ"[218] ។

---

213 បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៥៩ ។

214 ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១៤៣ ដល់ ១៥០ ។

215 សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១, ឯកសារ **E313** ត្រង់កថាខណ្ឌ ៥០១ ដល់ ៥០៣ ។ សាលដីកាអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១, ឯកសារ **F36** ត្រង់កថាខណ្ឌ ៣៥៨ ដល់ ៣៥៩ ។

216 ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១០៤ ។

217 ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១៣៩ ["សេចក្តីថ្លែងការណ៍ចំនួនពីរដែល អ៊ឹម ចែម បានផ្តល់ជូន មជ្ឈមណ្ឌលឯកសារកម្ពុជា សេចក្តីថ្លែងការណ៍មួយផ្តល់ជូនអង្គការយុវសន្តិភាព និងមួយទៀតផលិតកម្មស្នាលយលឹងចូត ត្រូវបានយកមកពិចារណានៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) ។ ស្របជាមួយនឹងវិធីសាស្ត្រដែលបានអនុវត្តនៅ ក្នុងសំណុំរឿង០០២ និងវិធានទូទៅនៃការវាយតម្លៃលើភ័ស្តុតាងដែលបានពន្យល់នៅក្នុងផ្នែកនេះ សេចក្តីថ្លែងការណ៍ ទាំងនេះត្រូវបានផ្តល់ទម្ងន់តិចតួចជាងការស្តាប់ចម្លើយដែលបានធ្វើឡើងដោយ ក.ស.ច.ស ។ ភាពអាចជឿជាក់បាន និង តម្លៃជាភស្តុតាងរបស់សេចក្តីថ្លែងការណ៍ទាំងនេះ ត្រូវបានវាយតម្លៃដោយពិនិត្យពិចារណាលើភស្តុតាងទាំងអស់ផ្សេងទៀត ដែលមាននៅក្នុងសំណុំរឿង" ។ (ដកចេញសេចក្តីយោងជើងទំព័រ និងគំនូសលើអក្សរនៃការសង្កត់ន័យ)] ។

218 ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១០៨ ។

១០៨. ផ្អែកតាមគោលការណ៍ដែលបានបង្កើតឡើងយ៉ាងល្អទាំងនេះ គ្មានអង្គជំនុំជម្រះមានហេតុផលណាអាចរកឃើញថា កិច្ចសម្ភាសន៍របស់អ្នកស្រី អ៊ឹម ចែម មានភាពច្បាស់លាស់គ្រប់គ្រាន់ក្នុងការបង្កើតនូវសិទ្ធិអំណាចរបស់អ្នកស្រីនៅស្រុកកោះអណ្តែតនោះទេ ។ ការអះអាងរបស់ សពអ ដែលថា សេចក្តីថ្លែងការណ៍របស់អ្នកស្រី អ៊ឹម ចែម "បញ្ជាក់យ៉ាងច្បាស់"[219] គឺជាការអះអាងដែលមិនយកចិត្តទុកដាក់លើគោលការណ៍ច្បាប់ស្នូល ដែលផ្តល់មូលដ្ឋានសម្រាប់ការវាយតម្លៃភស្តុតាងដោយយុត្តិធម៌ និងការប្រកាន់ខ្ជាប់ទៅនឹងតម្រូវការដែលភស្តុតាងត្រូវតែបំពេញតាមលក្ខខណ្ឌនៃបន្ទុក ក៏ដូចជាបទដ្ឋាននៃការបង្ហាញភស្តុតាងដែរ ។ ការប៉ុនប៉ងរបស់ សពអ ក្នុងការជ្រើសយកទិដ្ឋភាពភស្តុតាងនៃសេចក្តីថ្លែងការណ៍របស់អ្នកស្រី អ៊ឹម ចែម តែផ្នែកណាដែលខ្លួនចង់បាន (ភស្តុតាងដែលថាអ្នកស្រីត្រូវបានផ្ទេរទៅស្រុកកោះអណ្តែត ពីព្រោះ "[អ្នកស្រី] ធ្វើអីក៏សម្រេចតាមផែនការ"[220] ភស្តុតាងដែលថាអ្នកស្រីត្រូវបានចាត់តាំងដោយ "ខាងខេត្ត...គាត់ផ្លាស់ឱ្យ [អ្នកស្រី] ទៅរៀបចំប្រជាជន" នៅកោះអណ្តែត[221] ហើយនិងត្រង់ចំណុចដែលអ្នកស្រីបានលើកឡើងថា "ទូទៅហ្នឹង កន្លែងដែល[អ្នកស្រី]គ្រប់គ្រងដឹកនាំ"[222]) ហើយចាត់ទុកការកត់សម្គាល់ទាំងនោះថាជាភស្តុតាងផ្នែកសេចក្តីសម្រេចលើមុខងារ*តាមច្បាប់* និងមុខងារ*ជាក់ស្តែង* របស់អ្នកស្រី គឺវាផ្ទុយពីគោលបំណងនៃគោលការណ៍ដែលទើបតែបានលើកឡើង និងជាហានិភ័យមួយដែលធ្វើឱ្យប៉ះពាល់ដល់ដំណើរការនីតិវិធីត្រឹមត្រូវ ។

១០៩. លើសពីនេះ បើទោះបីជាសេចក្តីថ្លែងការណ៍របស់ DC-Cam មិនត្រូវបានទទួលយកដោយសារវារំលោភទៅលើការការពារប្រឆាំងនឹងការដាក់ពិរុទ្ធឱ្យខ្លួនឯង ឬអាចបង្ហាញពីហេតុផលសមរម្យ

---

[219] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៦១ ។

[220] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៦០ *យោងលើ* កិច្ចសម្ភាសន៍របស់ DC-Cam ជាមួយ អ៊ឹម ចែម ធ្វើនៅថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០១២, ឯកសារ **D123/1/5.1c** ត្រង់លេខសម្គាល់ទំព័រជាភាសាអង់គ្លេស EN ERN 00951845 ។

[221] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៥៩ *យោងលើ* កិច្ចសម្ភាសន៍របស់ DC-Cam ជាមួយ អ៊ឹម ចែម ធ្វើនៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨, ឯកសារ **D123/1/5.1b** ត្រង់លេខសម្គាល់ទំព័រជាភាសាអង់គ្លេស EN ERN 00951795 ។

[222] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៥៩ *យោងលើ* កិច្ចសម្ភាសន៍របស់ DC-Cam ជាមួយ អ៊ឹម ចែម ធ្វើនៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨, ឯកសារ **D123/1/5.1b** ត្រង់លេខសម្គាល់ទំព័រជាភាសាអង់គ្លេស EN ERN 00951819 ។

នៃអង្គហេតុណាមួយដូចការដែល សចស បានពិពណ៌នាដ៏ត្រឹមត្រូវក៏ដោយ គ្មានការថ្លែងរបស់អ្នកស្រី អ៊ឹម ចែម មួយណា មានលក្ខណៈប្រាកដប្រជាថាអ្នកស្រីបានកាន់តំណែងជាលេខាស្រុកកោះអណ្ដែតនោះទេ[223] ។ វិធីសាស្ត្ររបស់ សពអ មិនអើពើលើអង្គហេតុដែលអ្នកស្រី អ៊ឹម ចែម ក៏បានថ្លែងផងដែរថា អ្នកស្រី "មិនមែនជាលេខស្រុកអីទេ" ហើយជំនួសមកវិញ អ្នកស្រីមានបន្ទុក "ទទួលមើលការងារជាមួយស្រីៗ"[224] ។ ដូចដែល សចស បានសន្និដ្ឋានយ៉ាងសមរម្យបំផុត ថា សេចក្តីថ្លែងការណ៍សរុបរបស់អ្នកស្រី អ៊ឹម ចែម បានផ្តល់ត្រឹមតែភស្តុតាងមិនច្បាស់លាស់ ហើយដោយគិតតាមបទដ្ឋាន និងបន្ទុកនៃការភស្តុតាង សេចក្តីថ្លែងការណ៍របស់អ្នកស្រីទាំងអម្បាលម៉ាន គឺមិនអាចបង្កើតបាននូវទម្ងន់ភស្តុតាងដូចដែលទាមទារដោយ សពអ នោះទេ ។ វាជាការត្រឹមត្រូវណាស់ ក្នុងការដែល សចស បានរកឃើញថា សេចក្តីថ្លែងការណ៍នានារបស់អ្នកស្រី អ៊ឹម ចែម ត្រូវតែបានយកមកធ្វើការ "វាយតម្លៃដោយពិនិត្យពិចារណាលើភស្តុតាងផ្សេងទៀតដែលមាននៅក្នុងសំណុំរឿង"[225] ។

១១០. ការអះអាងរបស់ សពអ ដែលថា សចស គួរតែបានរកឃើញថា "ការសារភាពរបស់[អ្នកស្រី] អ៊ឹម ចែម ទាក់ទងនឹងមុខងារ របស់គាត់ ត្រូវបានបញ្ជាក់អះអាងតាមរយៈ ភស្តុតាងរបស់សាក្សីនានា"[226] គឺពុំមានគុណវុឌ្ឍិដូចគ្នានោះទេ ។ ដោយដាក់ដោយឡែកនូវការប៉ុនប៉ងដើម្បីលើកការតវ៉ាជាថ្មីលើបញ្ហាអង្គហេតុ ដោយគ្មានការយោងទៅលើលក្ខខណ្ឌតម្រូវនានាសម្រាប់ធ្វើការពិនិត្យឡើងវិញនៃបណ្តឹងឧទ្ធរណ៍ ការលើកអំណះអំណាងនេះ សពអ បដិសេធមិនធ្វើ សូម្បីតែចេតនាក្នុងការចង្អុលបង្ហាញឱ្យឃើញពីរបៀបដែល សចស មានកំហុសដូចម្តេចខ្លះ នៅពេលថ្លឹងថ្លែងលើភស្តុតាង*សរុប* ដែលឈានដល់ការសន្និដ្ឋានថាអ្នកស្រីមិនមែនជាលេខាស្រុកកោះអណ្តែត ។ ជាពិសេស សពអ បានព្យាយាមចៀសវាងវែកញែកតតាំងទៅនឹងការយោងរបស់

---

223 ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១៤៥ ដល់ ១៤៦ ។

224 កិច្ចសម្ភាសន៍របស់ DC-Cam ជាមួយ អ៊ឹម ចែម ធ្វើនៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨, ឯកសារ **D123/1/5.1b** ត្រង់លេខសម្គាល់ទំព័រជាភាសាអង់គ្លេស EN ERN 00951795 ។

225 ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១៣៩ ។

226 បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៦៣ ។

សចស ទៅលើភស្តុតាងរបស់លោក ពេជ្រ ជឹម (ដែលបានថ្លែងថាអ្នកស្រី អ៊ឹម ចែម *មិនបាន*កាន់មុខតំណែងជាគណៈស្រុកនោះទេ[227]) ហើយនិងភស្តុតាងបានពីលោក ប៊ុន ធឿន (ដែលថ្លែងថាអ្នកស្រី អ៊ឹម ចែម មិនបានចូលរួមប្រជុំនៅអង្គរជ័យក្នុងនាមជាលេខាស្រុកនោះទេ[228]) ។ សេចក្តីសេចក្តីថ្លែងការណ៍ទាំងនេះ ដែល សចស បានពឹងផ្អែកនៅក្នុងបទបង្ហាញរបស់ខ្លួនយ៉ាងសមហេតុផល និងការមិនយកចិត្តទុកដាក់បច្ចុប្បន្នរបស់ សពអ គឺជាការផ្តល់ដំបូន្មាន ។

១១១. ច្បាស់ណាស់ថា អវត្តមាននៃការប៉ុនប៉ងណាមួយដើម្បីដោះស្រាយលើភាពសមហេតុផលនៃការរកឃើញសរុបរបស់ សចស ទាក់ទងនឹងមុខងាររបស់អ្នកស្រី អ៊ឹម ចែម នៅក្នុងភូមិភាគនិរតី ដោយឡែកការដែលអះអាងថា សចស មិនបានពិចារណាឱ្យបានត្រឹមត្រូវចំពោះភស្តុតាង នឹងមិនអាចក្លាយជាមូលដ្ឋានបំពេញឱ្យលក្ខខណ្ឌច្បាប់ សម្រាប់ធ្វើការពិនិត្យលើដីកាដំណោះស្រាយសារឡើងវិញនោះទេ[229] ។ ការលើកយកមូលដ្ឋានសំអាងហេតុទាំងនេះជាអំណះអំណាង សពអ គ្រាន់តែធ្វើការកែសម្រួលសារជាថ្មីនូវទស្សនទាននៃភស្តុតាងដែលមានលក្ខណៈចំណុះឱ្យគ្នា ដោយការជ្រើសសេចក្តីយោងរបស់ខ្លួនតែពី សេចក្តីថ្លែងការណ៍របស់សាក្សីចំនួន ៥នាក់ប៉ុណ្ណោះ (អ៊ុល

[227] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១៤៦ *យោងលើ* កំណត់ហេតុស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ធ្វើថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤, ឯកសារ **D118/259** ត្រង់ចម្លើយ A41-43 ។

[228] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១៤៩ *យោងលើ* កំណត់ហេតុស្តាប់ចម្លើយសាក្សី ប៊ុន ធឿន ធ្វើថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤, ឯកសារ **D118/259** ត្រង់ចម្លើយ A32-34។

[229] រឿងក្តី *The Prosecutor ទល់នឹង Ramush Haradinaj និងអ្នកផ្សេងទៀត*, សំណុំរឿងលេខ (IT-04-84-A), សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១០ ត្រង់កថាខណ្ឌ ១៣ [**ភ្ជាប់ជាឯកសារសម្អាង៖ ១៥**]។ រឿងក្តី *The Prosecutor ទល់នឹង Ljube Boškoski ទល់នឹង Johnan Tarčulovski*, សំណុំរឿងលេខ (IT-04-82-A), សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១០ ត្រង់កថាខណ្ឌ ១៨ [**ភ្ជាប់ជាឯកសារសម្អាង៖ ១៣**]។ រឿងក្តី *The Prosecutor ទល់នឹង Dragomir Milošević*, សំណុំរឿងលេខ (IT-98-29/1-A), សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ត្រង់កថាខណ្ឌ ១៧ [**ភ្ជាប់ជាឯកសារសម្អាង៖ ១២**]។ រឿងក្តី *The Prosecutor ទល់នឹង Pavle Strugar*, សំណុំរឿងលេខ (IT-01-42-A), សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៨ ត្រង់កថាខណ្ឌ ២៣ [**ភ្ជាប់ជាឯកសារសម្អាង៖ ១០**]។ រឿងក្តី *The Prosecutor ទល់នឹង Radoslav Brđanin*, សំណុំរឿងលេខ (IT-99-36-A), សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៧ ត្រង់កថាខណ្ឌ ២៧-២៨ [**ភ្ជាប់ជាឯកសារសម្អាង៖ ៩**]។

ហឿន,[230] នាង អ៊ូច,[231] កៅ ឆេង,[232] សុខ រុំ,[233] និង រៀល សន[234]) ។

១១២. ក្នុងករណីនេះ សចអ បានយកលំនាំតាមវិធីសាស្ត្ររបស់ សចស ចំពោះចម្លើយរបស់ អ៊ុល ហឿន,[235] នាង អ៊ូច,[236] និង កៅ ឆេង[237] ប៉ុន្តែគ្រាន់តែអះអាងថា ភស្តុតាងពាក់ព័ន្ធគឺមិនត្រូវបានវាយតម្លៃត្រឹមត្រូវ ។ ទាក់ទងនឹងចម្លើយរបស់ អ៊ុល ហឿន សចស បានវាយតម្លៃដោយសមរម្យថា វាជាភស្តុតាងដាច់តែឯង ពុំមានមូលដ្ឋានច្បាស់លាស់ និងផ្ទុយគ្នាពីការលើកឡើងរបស់សាក្សីផ្សេងទៀត[238] ។ សចអ ខកខានមិនលើកបង្ហាញនូវភស្តុតាងរបស់ខ្លួន ផ្ទុយទៅវិញបែជាស្មានអំពីភាពខុសគ្នានៅក្នុងចម្លើយរបស់សាក្សីថា "អាចត្រូវបានពន្យល់តាមរយៈការច្រឡំរបស់គាត់អំពីបរិវេណព្រំដែននៃស្រុកនេះ ឬការជាប់ពាក់ព័ន្ធរបស់វាទៅនឹង[អ្នកស្រី] អ៊ឹម ចែម តាមរយៈមុខងាររបស់ប្តីគាត់"[239] ។ បញ្ហានេះ គួរតែទៅមុខដោយមិនចាំបាច់និយាយថាមុខងាររបស់ អបជ គឺមិនត្រូវយកការយល់ឃើញរបស់ខ្លួនចំពោះភស្តុតាងទៅជំនួសលើការយល់ឃើញរបស់ សចស នោះទេ[240] ហើយ អបជ ដែលមានមានសិទ្ធិក្នុងការចាត់ទុកការភាន់ច្រឡំនៃសាក្សី ថាជាភស្តុតាង

[230] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៦៤ ។

[231] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៦៥ ។

[232] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៦៦ ។

[233] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៦៧ ។

[234] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៦៨ ។

[235] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១៤៩ *យោងលើ* កំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ុល ហឿន ធ្វើថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៤, ឯកសារ **D118/208** ត្រង់ចម្លើយ A62-64។ ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១៤៩ *យោងលើ* កំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ុល ហឿន ធ្វើថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤, ឯកសារ **D118/209** ត្រង់ចម្លើយ A128-29 ។

[236] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៦៥ ។

[237] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៦៦ ។

[238] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១៤៩ ។

[239] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៦៤ ។

[240] *សូមមើល, សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿង លេខ ០០២/១៩-០៩-២០០៧/អវតក/កសចស (អ.ប.ជ. ២៥),* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុក នៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៩, ឯកសារ **D164/3/6** នៅកថាខណ្ឌ ២៦ ។

ដែលមិនអាចជឿទុកចិត្តបានសោះឡើយចំពោះសក្ខីកម្មទាំងស្រុង ឬក៏រួមទាំងភស្តុតាងដែលបានយោងជាសំអាងដើម្បីគាំទ្រដល់សំណុំរឿងរបស់ សពអ ។

១១៣. ទាក់ទងនឹងរបស់សាក្សី នាង អ៊ុច សពអ ខកខានមិនបានកំណត់ថារបកគំហើញដែលបានលើកឡើងដោយ សចស គឺមិនត្រូវបានធ្វើដោយអ្នកវិនិច្ឆ័យអង្គហេតុដ៏មានហេតុផលនោះទេ ។ សពអ បានអះអាងថា “មានភស្តុតាងលើសលុបបញ្ជាក់ថា ការបដិសេធរបស់ [នាង អ៊ុច] ទាំងអស់ [ថាគាត់ជាសមាជិកនៃគណៈស្រុកកោះអណ្ដែត] គឺគ្រាន់តែជាការកុហក ក្នុងគោលបំណងមួយដាក់ខ្លួនគាត់ឱ្យឆ្ងាយពីឧក្រិដ្ឋកម្មនានា ដែលបានប្រព្រឹត្តឡើងនៅក្នុងតំបន់ទាំងអស់នេះតែប៉ុណ្ណោះ”[241] ។ ទោះជាយ៉ាងក៏ដោយ តាមពិតទៅអំណះអំណាងទាំងនេះ ទាំងមិនត្រឹមត្រូវ និងគ្មានភាពពាក់ព័ន្ធ ។

១១៤. ទីមួយ សពអ គ្រាន់តែពឹងផ្អែកពីប្រតិចារឹកនៃសក្ខីកម្មរបស់សាក្សីនៅក្នុងសវនាការលើសំណុំរឿង០០២/០២ ដែលពាក់ព័ន្ធនឹងការសួរដេញដោលអំពីមុខងាររបស់សាក្សី នាង អ៊ុច នៅក្នុងស្រុកត្រាំកក់ (មិនមែនស្រុកកោះអណ្ដែតទេ)[242] ។ ទីពីរ ទោះជា នាង អ៊ុច បាន ឬមិនបានព្យាយាមដាក់ខ្លួនគាត់នៅឱ្យឆ្ងាយពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅក្នុងស្រុកកោះអណ្ដែតក៏ដោយ[243] ក៏វាមិនពាក់ព័ន្ធនឹងបញ្ហាណាមួយ ដែលមានសមត្ថភាពផ្ដល់ភស្តុតាងនៃតួនាទីរបស់អ្នកស្រី អ៊ឹម ចែម ដែលត្រូវបានចោទប្រកាន់នៅក្នុងទីតាំងនោះដែរ ។ ភស្តុតាងតែមួយគត់ពីសាក្សីរូបនេះ ដែលភ្ជាប់ទៅអ្នកស្រី អ៊ឹម ចែម គឺជាកិច្ចសម្ភាសន៍ជាមួយ DC-Cam[244] ដែលទាមទារឱ្យមានការបញ្ជាក់បន្ថែម ដូចដែលបានរៀបរាប់ខាងលើនៅកថាខណ្ឌ១០៧ ដើម្បីទទួលបាននូវតម្លៃជាភស្តុតាងប្រហាក់ប្រហែល

---

[241] បណ្ដឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៦៥ ។

[242] បណ្ដឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៦៥ *ដកស្រង់ សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿង លេខ ០០២/១៩-០៩-២០០៧/អវតក/អ.ជ.ស.ដ* ប្រតិចារឹកសវនាការលើអង្គសេចក្ដីនៃសំណុំរឿង ០០២ (សាក្សី នាង អ៊ុច) ធ្វើនៅថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៥, ឯកសារ **E1/273.1** ត្រង់ទំព័រ ៨១-៨៥ ។

[243] បណ្ដឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៦៥ ។

[244] បណ្ដឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៦៥ *យោងលើ* កិច្ចសម្ភាសន៍របស់ DC-Cam ជាមួយ អ៊ឹម ចែម ធ្វើនៅថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០១២, ឯកសារ **D123/1/5.1c** ត្រង់លេខសម្គាល់ទំព័រជាភាសាអង់គ្លេស EN ERN 00951847 ។

សម្រាប់ធ្វើការផ្ទៀងផ្ទាត់លើអង្គហេតុ ។

១១៥. អំណះអំណាងរបស់ សពអ ទាក់ទងនឹងភស្តុតាងរបស់ កៅ ឆេង[245] គឺជាភស្តុតាងដែលមិនសម ហេតុផល និងគ្មានភាពពាក់ព័ន្ធទាល់តែសោះ ។ សពអ បានអះអាងថាវាជាការពិត ដែលថា សេចក្ដីថ្លែងការណ៍របស់សាក្សីពាក់ព័ន្ធនឹងការចោទប្រកាន់លើអ្នកស្រី អ៊ឹម ចែម ពីការគ្រប់គ្រង លើ "មេឃុំស្រុក ... កោះអណ្ដែត ... [នៅពេល]យើងមើលសម្រាប់បរិបទនេះ និងបន្ថែមលើ ភស្តុតាងដទៃទៀត [វាបាន] បញ្ជាក់អះអាងអំពីមុខតំណែងរបស់ [អ្នកស្រី] អ៊ឹម ចែម ជាលេខា ស្រុកកោះអណ្ដែតពិតប្រាកដមែន"[246] ។ ទោះជាយ៉ាងណាក្ដី វាជាភស្តុតាងអសមត្ថភាព ដែលមិន អាចបញ្ជាក់ភស្តុតាងអ្វីដល់អំណះអំណាងរបស់ សពអ ឡើយ ពោលគឺ មុខងារជា*មេឃុំ*ស្រុក និង*លេខា*ស្រុក គឺជាអង្គភាពដាច់ដោយឡែកពីគ្នា[247] ។ ការប៉ុនប៉ងរបស់ សពអ ក្នុងការបង្រួម អង្គភាពទាំងពីរនេះចូលគ្នា គឺឥតប្រយោជន៍ ។ មិនត្រឹមតែប៉ុណ្ណោះ សពអ មិនបានបង្ហាញឱ្យ ឃើញថា សចស គ្មានហេតុផលសមរម្យក្នុងការច្រានចោលភស្តុតាងនេះ ដោយផ្អែកលើមូលដ្ឋាន ដែលថាវាជាភស្តុតាងចចាមអារ៉ាមដាច់ឆ្ងាយពីគេ[248] ។ តាមការពិនិត្យជាក់ស្ដែង ការរួមបញ្ចូលគ្នា រវាងភស្តុតាងដែលមានភាពឆ្ងាយដាច់ពីគេ និងភស្តុតាងចចាមអារ៉ាម ផ្ដល់បានជាមូលដ្ឋានដ៏រឹងមាំ ដើម្បីធ្វើការរកឃើញថាភស្តុតាងទាំងមូលមានតម្លៃតិចតួច ឬគ្មានតម្លៃជាភស្តុតាងសោះ[249] ។

---

[245] បណ្ដឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៦៦ ។

[246] បណ្ដឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៦៦ *យោងលើ* កំណត់ហេតុស្ដាប់ចម្លើយសាក្សី កៅ ឆេង ធ្វើថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៣, ឯកសារ **D119/16** ត្រង់ចម្លើយ A24 ។

[247] *សូមមើល*, កំណត់ហេតុស្ដាប់ចម្លើយសាក្សី ជុំ កាន់ ធ្វើថ្ងៃទី ២៦-២៧ ខែ មីនា ឆ្នាំ ២០១៤, ឯកសារ **D119/110** ត្រង់ចម្លើយ A23 ។

[248] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១៤៨, លេខយោងជើងទំព័រ ២៧៥ ។

[249] សាលដីកាអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង០០២/០១, ឯកសារ **F36** ត្រង់កថាខណ្ឌ ៣០២ ។ រឿងក្ដី *The Prosecutor ទល់នឹង Alex Tamba Brima* និងអ្នកផ្សេងទៀត, សំណុំរឿងលេខ (SCSL-04-16-T), សាលក្រមអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៧ ត្រង់កថាខណ្ឌ ១០៩ [**ភ្ជាប់ជាឯកសារសម្អាង៖ ២១**] ។ រឿងក្ដី *The Prosecutor ទល់នឹង Fatmir Limaj* និងអ្នកផ្សេងទៀត, សំណុំរឿងលេខ (IT-03-66-T), សាលក្រមអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ត្រង់កថាខណ្ឌ ២១ [**ភ្ជាប់ជាឯកសារសម្អាង៖ ៦**]។ រឿងក្ដី *The*

១១៦. ទទ្បីករណ៍ដែលនៅសេសសល់ គឺជាការចោះសម្រាំងស្មើគ្នាដោយការស្មាន និងមិនមានភាពជាប់ពាក់ព័ន្ធ ។ ការអះអាងរបស់ សពអ ដែលថា សចស បានខកខានមិនបានធ្វើការពឹងផ្អែកលើភស្តុតាងទទួលបានពី រៀល សន (លើកឡើងថា អ្នកស្រី អ៊ឹម ចែម "ធ្វើជាមេឃុំ បន្ទាប់មកទៅធ្វើជាគណៈស្រុក"[250]) គឺមិនយកចិត្តទុកដាក់នឹងចំណុចជាក់ស្តែង ថាវាជាភស្តុតាងមានកំហុសឆ្គងដូច្នេះគ្មាន អង្គជំនុំជម្រះមានហេតុផលណាអាចនឹងមិនអើពើចំពោះភាពទន់ខ្សោយទាំងនោះ និងផ្តល់ទម្ងន់ឱ្យភស្តុតាងដូច្នេះនោះទេ ។ ទីមួយ សម្រង់ដែលពឹងផ្អែកដោយ សពអ ផ្តល់តែការគាំទ្រចំពោះសំណើដែលស្មើថាអ្នកស្រី អ៊ឹម ចែម គឺជាសមាជិក "គណៈស្រុក" និងមិនមែនជា*លេខា*ស្រុកទេ[251] ។ ទីពីរ សពអ អះអាងថាភស្តុតាងរបស់ រៀល សន (ជាអ្នកបានធ្វើប្រតិបត្តិការផ្ទាល់នៅថ្នាក់ស្រុកនៅតំបន់១៣[252]) បានបញ្ជាក់បន្ថែមលើអំណះអំណាងរបស់គាត់ដោយមិនយកចិត្តទុកដាក់លើការសារភាពរបស់សាក្សីថាគាត់មិនបានដឹងពីស្រុកដែលអ្នកស្រី អ៊ឹម ចែម ធ្វើការនោះទេ[253] ។ ផ្ទុយទៅនឹងតក្កវិជ្ជារបស់ សពអ បុគ្គលដែលមានចំណេះដឹងនូវរឿងរ៉ាវផ្ទៃក្នុងរចនាសម្ព័ន្ធនៃតំបន់១៣ នឹងត្រូវបានគេរំពឹងថាជាអ្នកដែលអាចធ្វើការរម្លឹកឡើងវិញនូវព័ត៌មានលម្អិតសំខាន់ៗ និងបានច្បាស់លាស់ ។ ក្នុងករណីណាក៏ដោយ ដោយសារតែកម្សោយនៃភស្តុតាងឱកាសនេះបើកចំហរសម្រាប់អង្គជំនុំជម្រះដែលមានហេតុផល ក្នុងការសម្រេចផ្តល់តម្លៃលើភាពជឿជាក់បាននៃភស្តុតាង ត្រឹមកម្រិតតិចតួច ឬគ្មានសោះតែម្តង ។

១១៧. ចុងក្រោយ ការចោទប្រកាន់របស់ សពអ ដែលថា សចស បានខកខានមិនបាន "យោងទៅរក

---

*Prosecutor ទល់នឹង Radoslav Brdanin*, សំណុំរឿងលេខ (IT-99-36-T), សាលក្រមអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៤ ត្រង់កថាខណ្ឌ ២៧ [**ភ្ជាប់ជាឯកសារសម្អាង៖ ៤**]។

[250] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៦៨ *យោងលើ* កំណត់ហេតុស្តាប់ចម្លើយសាក្សី រៀល សន ធ្វើថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤, ឯកសារ **D118/181**ត្រង់ចម្លើយ A224 ។

[251] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៦៨ *យោងលើ* កំណត់ហេតុស្តាប់ចម្លើយសាក្សី រៀល សន ធ្វើថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤, ឯកសារ **D118/181** ត្រង់ចម្លើយ A224 ។

[252] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៦៨ ។

[253] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៦៨ ។

ភស្តុតាងរបស់ សុខ រុំ"[254] គឺជាការចោទប្រកាន់ដែលខ្វះនូវគុណវុឌ្ឍិខ្លាំងបំផុត ។ គ្មានភាពចាំបាច់អ្វីសម្រាប់ សចស "ដើម្បីសំដៅទៅលើរាល់សក្ខីកម្មរបស់សាក្សី និងគ្រប់បំណែកនៃកំណត់ត្រាភស្តុតាង ហើយការខកខានមិនបានធ្វើដូច្នេះមិនមានភាពចាំបាច់អ្វីក្នុងការបង្ហាញពីការខ្វះការត្រិះរិះពិចារណានោះទេ"[255] ។ នេះក៏ដោយសារតែ សចស បានដឹងថាភស្តុតាងបានពីអ្នកស្រី សុខ រុំ[256] មិនមានភាពសំខាន់ដើម្បីគាំទ្រចំពោះការចោទប្រកាន់អ្នកស្រី អ៊ឹម ចែម ជាលេខាស្រុកកោះអណ្តែត ។ សពអ មិនបានពន្យល់ថាតើហេតុអ្វីបានជាភស្តុតាងរបស់សាក្សីរូបនេះ (ដែលថាអ្នកស្រី អ៊ឹម ចែម បានធ្វើមេទ្ធិញធំៗ[257]) មានសារៈសំខាន់ខ្លាំងចំពោះការរកឃើញពីការមានមុខតំណែង*តាមច្បាប់*របស់អ្នកស្រី ដែល សចស មានកាតព្វកិច្ចត្រូវបដិសេធចោលនូវភាពពាក់ព័ន្ធ និងភាពគួរជឿជាក់បាននៃភស្តុតាងដូច្នេះ ។

១១៨. ចំពោះហេតុផលទាំងនេះ ការអះអាងរបស់ សពអ ដែលថាមិនមានអ្នកវិនិច្ឆ័យសមហេតុផលអាចរកឃើញថាអ្នកស្រី អ៊ឹម ចែម ជាលេខាស្រុកកោះអណ្តែត តែមិនបង្ហាញភស្តុតាងបែបនេះ វាគឺការយល់ខុសទាំងស្រុង[258] ។ ខណៈដែលវិធីសាស្ត្រចោះសម្រាំង និងមានតែមួយចំណែកៗរបស់ សពអ ចំពោះភស្តុតាងដែលបានបង្ហាញ វាឆ្ងាយពីការសន្និដ្ឋានមួយដែលថាពុំមានអ្នកវិនិច្ឆ័យអង្គហេតុមានហេតុផលណាមួយបដិសេធមិនពិចារណាលើអំណះអំណាងរបស់គាត់ វិធីសាស្ត្ររបស់ សចស ទៅវិញទេ គឺសមហេតុផលបំផុតនៅក្នុងកាលៈទេសៈទាំងនេះ ។ ទឡ្ហីករណ៍ទី៥ គួរតែត្រូវច្រានចោល ។

---

254 បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៦៧ ។

255 រឿងក្តី *The Prosecutor ទល់នឹង* *Momčilo Krajišnik*, សំណុំរឿងលេខ (IT-00-39-A), សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០០៩ ត្រង់កថាខណ្ឌ ១៩ [**ភ្ជាប់ជាឯកសារសម្អាង៖ ១១**]។

256 បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៦៧ *យោងលើ* កំណត់ហេតុស្តាប់ចម្លើយសាក្សី សុខ រុំ ធ្វើថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤, ឯកសារ **D119/108** ត្រង់ចម្លើយ A48 និងចម្លើយ A105 ។ ។

257 បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៦៧ *យោងលើ* កំណត់ហេតុស្តាប់ចម្លើយសាក្សី សុខ រុំ ធ្វើថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤, ឯកសារ **D119/108** ត្រង់ចម្លើយ A48 ។

258 បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៥៨ ។

### ii. *ទឡ្ហីករណ៍ទី៦៖ សចស បានសន្និដ្ឋានយ៉ាងសមហេតុផលថា អ្នកស្រី អ៊ឹម ចែម មិនមែនជាសមាជិកគណៈតំបន់១៣*

១១៩. សពអ បានអះអាងថា "មិនមានអ្នកវិនិច្ឆ័យលើអង្គហេតុដ៏សមហេតុផលណាអាចខកខានរកមិនឃើញថា [អ្នកស្រី] ជាសមាជិកគណៈតំបន់១៣ នោះទេ ផ្អែកតាមការពិនិត្យដ៏ត្រឹមត្រូវលើភស្តុតាង"[259] ហើយថាការសន្និដ្ឋានខុសរបស់ សចស ត្រង់ចំណុចនេះ "បង្ហាញឱ្យឃើញថា វាជាមូលហេតុដែលដីកា ដំណោះស្រាយមិនលើកយកការចោទប្រកាន់ទាំងឡាយរបស់[គាត់] ដែលថា [អ្នកស្រី] អ៊ឹម ចែម បានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម (JCE) នៅភូមិភាគនិរតី"[260] ។ ដូចគ្នានឹងទឡ្ហីករណ៍ទី៥ ដែរ សពអ អះអាងថា សចស មិនយកចិត្តទុកដាក់លើកិច្ចសម្ភាសន៍របស់អ្នកស្រី អ៊ឹម ចែម ជាមួយ DC-Cam ដោយចោទថាអ្នកស្រីត្រូវបានសារភាពពីការដែលគាត់ត្រូវបានដំឡើងឋានៈឱ្យក្លាយជាសមាជិកនៃគណៈតំបន់១៣[261] និងខកខានមិនបានធ្វើការវាយតម្លៃលើភស្តុតាងបញ្ជាក់បន្ថែមឱ្យបានត្រឹមត្រូវ[262] ។ ផ្ទុយទៅវិញ ដូចដែលបានគូសបញ្ជាក់ខាងក្រោម វិធីសាស្ត្ររបស់ សចស ចំពោះភស្តុតាង គឺសមហេតុផលជាទីបំផុត[263] ។ គ្មានអង្គជំនុំជម្រះមានហេតុផលណា អាចនឹងយកវិធីសាស្ត្ររបស់ សពអ ចំពោះភស្តុតាងបានទេ ។

១២០. សារណារបស់ក្រុមការពារក្តីនៅកថាខណ្ឌ១០៧ ខាងលើ ទាក់ទងនឹងវិធីសាស្ត្រសមហេតុផលចំពោះតម្លៃនៃភស្តុតាងដែលបានពីសេចក្តីថ្លែងការណ៍របស់អ្នកស្រី អ៊ឹម ចែម ផ្តល់ឱ្យ DC-Cam ពាក់ព័ន្ធនឹងទឡ្ហីករណ៍ទី៥ គឺអនុវត្តដូចគ្នាដែរនឹងទឡ្ហីករណ៍ទី៦ ។ ចំណាត់ការរបស់ សចស អនុវត្តន៍ចំពោះសេចក្តីថ្លែងការណ៍ដែលធ្វើឡើងដោយ DC-Cam អាចនឹង "ត្រូវបានពឹងផ្អែកតែក្នុង

---

[259] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៧០ ។

[260] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៨១ ។

[261] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៧១-៧៣ *យោងលើ* កិច្ចសម្ភាសន៍របស់ DC-Cam ជាមួយ អ៊ឹម ចែម ធ្វើនៅថ្ងៃទី ៦ ខែមេសា ឆ្នាំ ២០១២, ឯកសារ **D123/1/5.1c** ។

[262] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៧៤-៨០ ។

[263] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១៤៣-១៥០ ។

ករណីដែលទទួលបានការគាំទ្រដោយប្រភពផ្សេងទៀតប៉ុណ្ណោះ"[264] ។

១២១. នៅក្នុងទឡ្ហីករណ៍ទី៦ សពអ បានអះអាងថា សាក្សីចំនួន ១៥នាក់ និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន មានភស្តុតាងបញ្ជាក់បន្ថែមជាមួយនឹងសេចក្តីថ្លែងការណ៍របស់អ្នកស្រី អ៊ឹម ចែម ដែលផ្តល់ឱ្យ DC-Cam និងការចោទប្រកាន់ដែលថាអ្នកស្រីកាន់មុខតំណែងនៅក្នុង គណៈតំបន់១៣[265] ។ ជាជាងធ្វើការពិគ្រោះវែកញែកលើដីកាដំណោះស្រាយឱ្យបានស៊ីជម្រៅ និងឱ្យបានទូលំទូលាយ ការទាមទាររបស់ សពអ ផ្អែកយ៉ាងច្រើនលើវិធីសាស្ត្របែបចោះសម្រាំងចំពោះការវាយតម្លៃរបស់ សចស ។ សពអ ខកខានមិនបានត្រិះរិះពិចារណា ឬតាំងជាមួយភស្តុតាងដ៏ច្រើនលើសលុបវាយតម្លៃដោយ សចស ដែលជាឫសគល់យ៉ាងសំខាន់ដល់ការរកឃើញថា ភស្តុតាងមិនបានបង្កើតបានថាអ្នកស្រី អ៊ឹម ចែម ជាសមាជិកនៃគណៈតំបន់១៣ឡើយ[266] ។ ដូចបានឃើញស្រាប់នូវការវិភាគរបស់ សពអ ចំពោះដីកាដំណោះស្រាយ និងដោយ

---

[264] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១០៨ ។

[265] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៧០-៨១ *យោងលើ* កំណត់ហេតុស្តាប់ចម្លើយសាក្សី ស្នួន មុត, អ៊ុល ហឿន, អន សុភាព, មូល អេង, ម៉ឹង វេត, ពេជ្រ ជឹម, ប៊ុន ធឿន, អ៊ឹង ជឿន, ខឹម ហឿន, ខឹម វ៉ៃ, សុខ រុំ, តែម ជ្រន, គង់ សាមី, ភ្លី លី, ធង ភូន ។

[266] *សូមមើល*, ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១៤៨ ["ទោះជាយ៉ាងណាក្តី សាក្សីជាច្រើននាក់បានផ្តល់ភស្តុតាងជាក់លាក់ជាងបញ្ហានេះ ដោយលើកឡើងថា តួនាទីរបស់[អ្នកស្រី] អ៊ឹម ចែម នៅតំបន់១៣ គឺជាប្រធានសមាគមនារី *ដោយយោងទៅ* កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ឹង វេត ធ្វើនៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៤, ឯកសារ **D119/83** ត្រង់ចម្លើយ A18-19 ។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ឹង វេត ធ្វើនៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤, ឯកសារ **D119/84** ត្រង់ចម្លើយ A19-20 និងត្រង់ចម្លើយ A29-31 ។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ធ្វើនៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣, ឯកសារ **D118/79** ត្រង់ចម្លើយ A6 ។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ប៊ុន ធៀន ធ្វើនៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៩, ឯកសារ **D6.1.688** ត្រង់ ERN 00384405 (ជាភាសាអង់គ្លេស)។ កំណត់ហេតុស្តាប់ចម្លើយសាក្សី សៅ វ៉ន ធ្វើនៅថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៣, ឯកសារ **D119/15** ត្រង់ចម្លើយ A12 ។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ប៊ុន ធៀន ធ្វើនៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៤, ឯកសារ **D118/274** ត្រង់ចម្លើយ A28 ។ កំណត់ហេតុស្តាប់ចម្លើយសាក្សី តឹប ភី ធ្វើនៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៥, ឯកសារ **D219/521** ត្រង់ចម្លើយ A63 ។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ធ្វើនៅថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤, ឯកសារ **D118/259** ត្រង់ចម្លើយ A40-41 និងត្រង់ចម្លើយ A40-45 ។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ប៊ុន ធឿន ធ្វើនៅថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៤, ឯកសារ **D119/149** ត្រង់ចម្លើយ A32-34] ។

ផ្អែកលើភស្តុតាងសរុបនៅក្នុងសំណុំរឿង វិធីសាស្ត្ររបស់ សចស ចំពោះសេចក្តីថ្លែងការណ៍របស់អ្នកស្រី អ៊ឹម ចែម ព្រមទាំងភស្តុតាងដែលត្រូវបានលើកឡើងថាជាភស្តុតាងស៊ីសង្វាក់ពាក់ព័ន្ធនឹងតួនាទីរបស់អ្នកស្រី អ៊ឹម ចែម នៅក្នុងតំបន់១៣ គឺសមហេតុផល[267] ។

១២២. ទីមួយ សពអ លើកឡើងពុំត្រឹមត្រូវនូវភាពគួរជឿជាក់បាននៃភស្តុតាង ដែលថាវាអាចត្រូវបានភ្ជាប់ទៅនឹងភស្តុតាងដែលបានពីអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។ ស្របតាមយុត្តិសាស្ត្រនៃ អ.វ.ត.ក សចស បានកត់សម្គាល់ដូច្នេះថា សេចក្តីថ្លែងការណ៍របស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីគឺ "វាជា '*ការរៀបរាប់ទូទៅ* ដែលខុសពីបទពិសោធន៍ផ្ទាល់ខ្លួន ហើយជាលទ្ធផលត្រូវចាត់ទុកថាមិនគ្រប់គ្រាន់សម្រាប់កំណត់ពីអង្គហេតុពាក់ព័ន្ធ"[268] ។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចំនួនបីក្នុងចំណោមអ្នកដាក់ពាក្យសុំទាំង៤នាក់ ដែលដកស្រង់ដោយ សពអ សុទ្ធតែស្ថិតនៅក្នុងប្រភេទដែលទើបតែបានលើកឡើងនេះ[269] ។ វាជាការអនុវត្តឆន្ទានុសិទ្ធិធម្មតាដ៏សមហេតុផលក្នុងការដែល សចស ផ្តល់ទម្ងន់តិចតួចឱ្យភស្តុតាងប្រភេទនេះ ឬមិនផ្តល់ទាល់តែសោះចំពោះការឆ្លើយតបទៅនឹងសំណួរដែលសួរថា "តើអ្នកណាដែលអ្នកជឿជាក់ថាត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះ? ហើយមូលហេតុអ្វីដែលអ្នកជឿជាក់បែបនេះ?" ជាពិសេស នៅពេលចម្លើយតបទាំងនោះ ជាសេចក្តីថ្លែងការណ៍មួយបន្ទាត់ដោយចោទប្រកាន់ថាអ្នកស្រី អ៊ឹម ចែម ជាអ្នកកាន់តំណែងនៅក្នុងគណៈតំបន់១៣[270] ។ លើសពីនេះ ខណៈដែលការរៀបរាប់លម្អិតអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជា

---

[267] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១៣៦-១៣៩ ។

[268] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១០៧ *ដកស្រង់ចេញ* សាលដីកាអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង00២/0១, ឯកសារ **F36** ត្រង់កថាខណ្ឌ ៤៥៧ ។

[269] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៧៩, លេខយោងដើងទំព័រ ១៩៦ ។

[270] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តែម ជ្រន ធ្វើនៅថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១២, ឯកសារ **D5/1133** ត្រង់លេខសម្គាល់ទំព័រជាភាសាអង់គ្លេស EN ERN 01144435 ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គង់ សាមី ធ្វើនៅថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣, ឯកសារ **D5/1303** ត្រង់លេខសម្គាល់ទំព័រជាភាសាអង់គ្លេស EN ERN 01191036។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ភ្លី លី ធ្វើនៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៣, ឯកសារ **D5/1615** ត្រង់លេខសម្គាល់ទំព័រជាភាសាអង់គ្លេស EN ERN 01168228 ។

ដើមបណ្តឹងរដ្ឋប្បវេណី មានតម្លៃខ្ពស់ជាងការបង្ហាញត្រឹមតែសេចក្តីសន្និដ្ឋានទូទៅ ការនេះវាមិនអាចធ្វើឱ្យខិនថយដល់ទូន្មានរបស់អង្គជំនុំជម្រះតុលាការកំពូលដែលបានក្រើនរម្លឹកថា សម្រាប់អ្នកដែលបានបង្ហាញព័ត៌មានលម្អិតនូវអ្វីដែលទំនងជាបទពិសោធន៍ផ្ទាល់ខ្លួន សេចក្តីថ្លែងការណ៍របស់ពួកគេ គប្បីមានការបញ្ជាក់បន្ថែមដោយភស្តុតាងផ្សេងទៀត[271] ។ ដូចដែលបានរកឃើញដោយ សចស ហើយមិនត្រូវបានយកចិត្តទុកដាក់ដោយ សពរអ ភស្តុតាងដែលមានភាពជាប់ពាក់ព័ន្ធ និងភាពអាចជឿជាក់បាននៃភស្តុតាងពីអ្នកដាក់ពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណី គឺត្រូវតែអាស្រ័យលើភស្តុតាងដែលគួរឱ្យទុកចិត្តផ្សេងទៀត[272] ។

១២៣. ដូចដែលនឹងត្រូវបានបង្ហាញខាងក្រោម ការពិនិត្យដោយប្រញាប់ប្រញាល់លើភស្តុតាងសរុបបង្ហាញបានថា ពាក្យសុំទាំងនោះមិនមានមូលដ្ឋានអ្វីរឹងមាំនោះទេ ។ សចស មានឆន្ទានុសិទ្ធិសុច្ឆន្ទៈក្នុងការសន្និដ្ឋានថាអ្នកស្រី អ៊ឹម ចែម មិនមែនជាសមាជិកនៃគណៈតំបន់១៣ ។ ដោយដាក់ឡែកនូវបំណងរបស់ សពរអ ក្នុងការតវ៉ាលើសំណុំរឿងអយ្យការសារជាថ្មីជាជាងធ្វើការឆ្លើយតបទៅនឹងលក្ខខណ្ឌកម្រិតនៃបណ្តឹងឧទ្ធរណ៍ ចំនួនសាក្សីដែលបានសំអាងលើក្នុងទឡ្ហីករណ៍ទី៦ ផ្តល់ទម្ងន់តិចតួច ឬគ្មានទម្ងន់គាំទ្រពិតប្រាកដអ្វីចំពោះការអះអាងផ្ទុយរបស់ សពរអ ។ ចំណុចជាក់លាក់នៅក្នុងចំណោមសាក្សីទាំង១១នាក់ដែលត្រូវបានលើកឡើងដើម្បីគាំទ្រទឡ្ហីករណ៍ទី៦ មានសាក្សីចំនួនប្រាំពីរ (៧) នាក់បានផ្តល់ភស្តុតាងដោយប្រយោល ដែលនេះជាសភាពនៃការស្មាន គ្មានភាពស៊ីសង្វាក់ និងកម្រិតតិចតួចពេកសម្រាប់អាចជឿជាក់បាន ដែលភស្តុតាងដូច្នេះមានតម្លៃតិចជាងភស្តុតាងចចាមអារ៉ាមដែលរកជឿមិនបានសោះ ។ ដូចដែលបានពិភាក្សាជាសង្ខេបខាងក្រោម ការអះអាងរបស់ សពរអ ថាសាក្សីទាំងនេះ "មានភាពជាក់លាក់ និងច្បាស់លាស់" លើការដឹងឮពីតួនាទីអ្នកស្រី អ៊ឹម ចែម នៅភូមិភាគនិរតី គឺគ្មានភស្តុតាងគាំទ្រ និងគ្មានភាពត្រឹមត្រូវ ។

១២៤. ឧទាហរណ៍ សពរអ លើកយកការវាយតម្លៃរបស់ សចស ស្តីពីសេចក្តីថ្លែងការណ៍របស់សាក្សី

[271] សាលដីកាអង្គជំនុំជម្រះតុលាការកំពូលក្នុង សំណុំរឿង០០២/០១, ឯកសារ **F36** ត្រង់កថាខណ្ឌ ៤៥៧ ។

[272] *ប្រៀបធៀបគ្នា*, ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១០៨ និងសាលដីកាអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង០០២/០១, ឯកសារ **F36** ត្រង់កថាខណ្ឌ ៤៥៧ ។

អ៊ុល ហឿន, អន សុភាព និង សួន មុត ដែល "មិនត្រូវបានរាប់បញ្ចូល...ចម្លើយទាំងអស់នេះដោយផ្អែកលើមូលដ្ឋានដែលថាសាក្សីទាំងអស់នេះផ្តល់ភស្តុតាង 'មានភាពច្បាស់លាស់ និងជឿជាក់មានកម្រិត'"[273] ។ សពអ បានអះអាងថា ផ្ទុយពីការវាយតម្លៃរបស់ សចស សាក្សីទាំងនេះ "មានភាពជាក់លាក់ និងច្បាស់លាស់ថា [អ្នកស្រី] អ៊ឹម ចែម មានតួនាទីនៅក្នុងគណៈតំបន់១៣"[274] ។ គ្មានអង្គជំនុំជម្រះមានហេតុផលណាអាចយល់ស្របតាមទស្សនទានលើភស្តុតាងដូច្នេះបានទេ ។ សាក្សី អ៊ុល ហឿន មិនបានផ្តល់មូលដ្ឋានអ្វីមួយសម្រាប់ការអះអាងរបស់គាត់ចំពោះតួនាទីរបស់អ្នកស្រី អ៊ឹម ចែម នៅថ្នាក់តំបន់ឡើយ ហើយលោកបានទទួលស្គាល់ថា "ខ្ញុំមិនច្បាស់ទេ" សូម្បីតែការកាន់តំណែងរបស់អ្នកស្រី អ៊ឹម ចែម នៅថ្នាក់ស្រុក[275] ។ លើសពីនេះទៀត សចស បានច្រានចោលភស្តុតាងផ្សេងទៀតដែលផ្តល់ដោយសាក្សី អ៊ុល ហឿន ទាក់ទងនឹងតួនាទីរបស់អ្នកស្រី អ៊ឹម ចែម នៅភូមិភាគនិរតី ដោយសារ "ពុំមានមូលដ្ឋានច្បាស់លាស់"[276] ដែលការរកឃើញមួយនេះ មិនត្រូវបានជំទាស់ឡើយដោយ សពអ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់គាត់ ។

១២៥. ស្រដៀងគ្នានេះដែរ សាក្សី អន សុភាព បានបញ្ជាក់ថាគាត់ "មិនដែលបានជួប [អ្នកស្រី] អ៊ឹម ចែម នៅក្នុងរបបខ្មែរក្រហមទេ"[277] ហើយក៏ "មិនដឹង" ពីរចនាសម្ព័ន្ធគ្រប់គ្រងនៅតំបន់១៣ដែរ[278] ។ ចុងក្រោយ ភស្តុតាងរបស់សាក្សី សួន មុត[279] គឺផ្អែកលើការសង្កេតផ្ទាល់ខ្លួនចំពោះអ្នកស្រី អ៊ឹម

---

[273] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៧៤ *ដកស្រង់* ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១៤៨ ។

[274] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៧៤ ។

[275] កំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ុល ហឿន ធ្វើថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៤, ឯកសារ **D193/8.2** ត្រង់ចម្លើយ A13 ។

[276] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១៤៩ *ដកស្រង់* កំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ុល ហឿន ធ្វើថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៤, ឯកសារ **D118/208** ត្រង់ចម្លើយ A62-64 ។ កំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ុល ហឿន ធ្វើថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤, ឯកសារ **D118/209** ត្រង់ចម្លើយ A128-29 ។

[277] កំណត់ហេតុស្តាប់ចម្លើយសាក្សី អន សុភាព ធ្វើថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣, ឯកសារ **D118/78** ត្រង់ចម្លើយ A8 ។

[278] កំណត់ហេតុស្តាប់ចម្លើយសាក្សី អន សុភាព ធ្វើថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣, ឯកសារ **D118/78** ត្រង់សំណួរ និងចម្លើយ Q-A10 ។

[279] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៧៤ *ដកស្រង់* កំណត់ហេតុស្តាប់ចម្លើយសាក្សី សួន មុត ធ្វើថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤, ឯកសារ **D219/37** ត្រង់ចម្លើយ A17-18 និង A25 ។

ចែម "ដោយសារគាត់បានមកដឹកនាំអង្គប្រជុំ និងមកធ្វើការនៅកន្លែងដែលខ្ញុំរស់នៅ"[280] ។ ជាក់ស្តែង ភស្តុតាងនេះមានភាពគួរឱ្យជឿជាក់បានស្តួចស្តើងបំផុតទាក់ទងទៅនឹងការអះអាងថា អ្នកស្រី អ៊ឹម ចែម គឺជាសមាជិកនៃគណៈតំបន់១៣ ។ សរុបទៅ គ្មានអង្គជំនុំជម្រះមានហេតុផលណានឹងសន្និដ្ឋានថា សចស មានកំហុស ឬរំលោភលើឆន្ទានុសិទ្ធិរបស់ខ្លួននៅពេលបដិសេធមិនពឹងផ្អែកលើអង្គភស្តុតាងដូច្នេះនោះទេ ។

១២៦. សពអ ក៏តវ៉ាផងដែរថា ភស្តុតាងគាំទ្រការអះអាងដែលថាអ្នកស្រី អ៊ឹម ចែម ជាសមាជិកលេខាតំបន់១៣នោះ គឺមិនត្រូវបានវាយតម្លៃត្រឹមត្រូវដោយ សចស ឡើយ[281] ។ ជាពិសេស សពអ ព្យាយាមពឹងផ្អែកលើសេចក្តីថ្លែងការណ៍របស់សាក្សី សុខ រ៉ុំ,[282] មូល អេង,[283] ពេជ្រ ជឹម,[284] ប៊ុន ធឿន[285] និង ឆឹង ជឿន[286] ។ ទោះបីជាយ៉ាងណាក្តី ឆ្ងាយពីការគាំទ្រដល់ការចោទប្រកាន់របស់ សពអ ការដឹងឮរបស់សាក្សីលើមុខតំណែងរបស់អ្នកស្រី អ៊ឹម ចែម មានសភាពផុយស្រួយច្បាស់ចែស ព្រោះវាបានមកពីការបរិយាយដែលគ្មានប្រភព និងជាភស្តុតាងចចាមអារ៉ាមដែលគ្មានការបញ្ជាក់បន្ថែម ។ តួយ៉ាងនៅក្នុងសេចក្តីថ្លែងការណ៍របស់អ្នកស្រី សុខ រ៉ុំ ។ ថ្វីបើភស្តុតាងពីសាក្សីរូបនេះត្រូវបានពិចារណាដោយ សពអ ថាវា "ពិតជាគាំទ្រ" លើសំណុំរឿងរបស់អយ្យការក្តី[287] ការពិតសាក្សីរូបនេះ គ្រាន់តែបានថ្លែងថាគាត់ "ធ្លាប់ឮ" ឈ្មោះអ្នកស្រី អ៊ឹម ចែម ប៉ុណ្ណោះ[288]

---

[280] កំណត់ហេតុស្តាប់ចម្លើយសាក្សី សួន មុត ធ្វើថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤, ឯកសារ **D219/37** ត្រង់ចម្លើយ A18 ។

[281] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៧៥-៧៨ ។

[282] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៧៨ ។

[283] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៧៥ និងកថាខណ្ឌ ៧៨ ។

[284] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៧៥ ។

[285] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៧៦ ។

[286] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៧៧ ។

[287] Appeal, para, 78.

[288] កំណត់ហេតុស្តាប់ចម្លើយសាក្សី សុខ រ៉ុំ ធ្វើថ្ងៃទី ១៩-២០ ខែ មីនា ឆ្នាំ ២០១៤, ឯកសារ **D119/108** ត្រង់សំណួរ និងចម្លើយ Q-A45។

ហើយថាអ្នកស្រី "មិនចាំឈ្មោះគណៈតំបន់១៣ ទេ"[289] ។

១២៧. ភស្តុតាងដែលនៅសេសសល់ទាំងអម្បាលម៉ាន មិនបានគាំទ្រអ្វីបន្ថែមពីនេះទេ ។ សាក្សី មូល អេង បានថ្លែងថា "ខ្ញុំមិនដឹងពិតខ្លួនឯងទេ" ថាអ្នកស្រី អ៊ឹម ចែម ជាសមាជិកគណៈតំបន់១៣ ហើយគាត់គ្រាន់តែបាន "ឮទូទៅ"[290] ប៉ុណ្ណោះ ។ សាក្សី ពេជ្រ ជឹម បានផ្តល់ភស្តុតាងចចាមអារ៉ាម ដោយការផ្អែកលើពាក្យ "អ្នកខ្លះគេនិយាយ"[291] ថាអ្នកស្រី អ៊ឹម ចែម "ជាគណៈតំបន់ទទួលខុសត្រូវខាងនារី"[292] ។ សពអ មិនបានយកចិត្តទុកដាក់លើការពិតដែលមាននៅក្នុងបទសម្ភាសន៍ជាបន្តបន្ទាប់មកទៀតរបស់សាក្សី ពេជ្រ ជឹម ដែលបានបញ្ជាក់ផងដែរថាអ្នកស្រី អ៊ឹម ចែម "មិនមែនជាគណៈតំបន់ទេ"[293] ។ សាក្សី ប៊ុន ធឿន បានសារភាពថាគាត់ "ចាំមិនសូវច្បាស់ទេ" ចំពោះព័ត៌មានទាក់ទងនឹងតួនាទីផ្លូវការរបស់អ្នកស្រី អ៊ឹម ចែម និង "គ្រាន់តែឮ" ថាអ្នកស្រី អ៊ឹម ចែម "*ប្រហែលជា*ក្លាយជាសមាជិកគណៈតំបន់១៣ទៀតផងក៏មិនដឹង"[294] ។ សាក្សី អ៊ឹង ជឿន បានប្រកាសពីរដងថាគាត់ "មិនដឹង" ថាអ្នកស្រី អ៊ឹម ចែម មានតួនាទីអ្វីច្បាស់ នោះទេ[295] ។

១២៨. ជាចុងក្រោយ ក្នុងចំណោមសាក្សីចំនួន១១នាក់ ដែលចម្លើយរបស់ពួកគាត់ត្រូវបានអះអាងថាជាភស្តុតាងមានការបញ្ជាក់បន្ថែម (ដូចគ្នានឹងអ្នកដាក់ពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណីចំនួនបួន

---

289 កំណត់ហេតុស្តាប់ចម្លើយសាក្សី សុខ រុំ ធ្វើថ្ងៃទី ១៩-២០ ខែ មីនា ឆ្នាំ ២០១៤, ឯកសារ **D119/108** ត្រង់សំណួរ និងចម្លើយ Q-A12 ។

290 កំណត់ហេតុស្តាប់ចម្លើយសាក្សី មូល អេង ធ្វើថ្ងៃទី ០៤-០៥ ខែ មីនា ឧសភា ២០១៥, ឯកសារ **D219/294** ត្រង់ចម្លើយ A140 ។

291 កំណត់ហេតុស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ធ្វើថ្ងៃទី ១៩ ខែ មិថុនា ២០១៤, ឯកសារ **D118/259** ត្រង់ចម្លើយ A40 ។

292 បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៧៥ *ដកស្រង់* កំណត់ហេតុស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ធ្វើថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤, ឯកសារ **D118/259** ត្រង់ចម្លើយ A40 ។

293 កំណត់ហេតុស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ធ្វើថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣, ឯកសារ **D118/79** ត្រង់សំណួរ និងចម្លើយ Q-A6 ។

294 កំណត់ហេតុស្តាប់ចម្លើយសាក្សី ប៊ុន ធឿន ធ្វើថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៤, ឯកសារ **D118/274** ត្រង់សំណួរ និងចម្លើយ Q-A28-29 ។

295 កំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ឹង ជឿន ធ្វើថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៤, ឯកសារ **D119/156** ត្រង់ចម្លើយ A15 និងត្រង់សំណួរ និងចម្លើយ Q-A16 ។

រូប ដែលបានលើកឡើងខាងលើត្រង់កថាខណ្ឌ១២២) ត្រូវបាន សពអ ផ្អែកលើដើម្បីគាំទ្រក្នុងទឡ្ហីករណ៍ទី៦ នៃបណ្តឹងឧទ្ធរណ៍របស់គាត់ គឺមានតែសាក្សីបីនាក់ប៉ុណ្ណោះដែលបានផ្តល់ភស្តុតាងដោយផ្ទាល់ទាក់ទងនឹងតួនាទីរបស់អ្នកស្រី អ៊ឹម ចែម នៅភូមិភាគនិរតី ។ ទោះបីជាយ៉ាងណាក្តី មានតែអ្នកស្រី ខឹម វៃ[296] ប៉ុណ្ណោះ ដែលស័ក្តិសមជាភស្តុតាងគាំទ្រដែលមានអត្ថន័យសម្រាប់ការចោទប្រកាន់ទាក់ទងនឹងមុខតំណែងរបស់អ្នកស្រី អ៊ឹម ចែម នៅក្នុងតំបន់១៣ ។ ពាក្យទិតៀនរបស់ សពអ ចំពោះវិធីសាស្ត្ររបស់ សចស លើសាក្សីដែលនៅសល់ពីរនាក់ (ខឹម បឿន និង ម៉ឺង វេត) គឺជាការមិនត្រឹមត្រូវ និងជាការអភ័ត ។ សចស ពិតជាបានប្រតិបត្តិយ៉ាងត្រឹមត្រូវដោយឥតសង្ស័យ ក្នុងការច្រានចោលនូវភស្តុតាងរបស់ពួកគេ ដោយសារមិនអាចផ្តល់ការគាំទ្រអ្វីកើតដល់សំណុំរឿងរបស់ សពអ ។

១២៩. ទាក់ទងនឹងភស្តុតាងរបស់ ខឹម បឿន សពអ បានលើកឡើងពុំត្រឹមត្រូវ ដោយការអះអាងថា សុន្ទរកថារបស់អ្នកស្រី អ៊ឹម ចែម បាននិយាយអំពី "បញ្ហាសន្តិសុខ ឬការចាប់ខ្លួនមនុស្សឬ ខ្មាំង ឬជនក្បត់ ឬការបោសសម្អាត ... ចម្លើយទាំងអស់នេះ គឺពិតជាខុសគ្នាខ្លាំងពីការសន្និដ្ឋានរបស់ សចស ថា [អ្នកស្រី] អ៊ឹម ចែម បានចូលរួមការប្រជុំនានា ដោយសំអាងលើមូលដ្ឋានថាជាប្រធានសមាគមនារីតំបន់"[297] ។ តាមពិត សាក្សីបានថ្លែងថា អ្នកដែលចូលរួមប្រជុំជាមួយថ្នាក់តំបន់រួមមានដូចជាអ្នកស្រី អ៊ឹម ចែម ឬសាក្សីខ្លួនឯងផ្ទាល់ (ដែលមានឋានៈជាមេឃុំ[298]) សុទ្ធតែត្រូវបានអនុញ្ញាតឱ្យផ្តល់នូវចំណាប់អារម្មណ៍របស់ខ្លួននៅចុងបញ្ចប់នៃកិច្ចប្រជុំ[299] អាស្រ័យទៅលើ

---

[296] *សូមមើល*, បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៧៨ *ដកស្រង់* កំណត់ហេតុស្តាប់ចម្លើយសាក្សី ខឹម វៃ ធ្វើថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៥, ឯកសារ **D219/636** ត្រង់ចម្លើយ A38 ។

[297] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៧៧ ["ខឹម បឿន ... បានឆ្លើយប្រាប់ សចស ថា អ៊ឹម ចែម បាននិយាយអំពី "បញ្ហាសន្តិសុខ ឬការចាប់ខ្លួនមនុស្សឬ ខ្មាំង ឬជនក្បត់ [និង] ការបោសសម្អាតក្នុងពេលប្រជុំនៅតំបន់១៣"] កំណត់ហេតុស្តាប់ចម្លើយសាក្សី ខឹម បឿន ធ្វើថ្ងៃទី ២១-២៣ ខែ ឧសភា ឆ្នាំ ២០១៤, ឯកសារ **D118/242** ត្រង់ចម្លើយ A99 ។

[298] *សូមមើល*, កំណត់ហេតុស្តាប់ចម្លើយសាក្សី ខឹម បឿន ធ្វើថ្ងៃទី ២១-២៣ ខែ ឧសភា ឆ្នាំ ២០១៤, ឯកសារ **D118/242** ត្រង់ចម្លើយ A17 ។

[299] កំណត់ហេតុស្តាប់ចម្លើយសាក្សី ខឹម បឿន ធ្វើថ្ងៃទី ២១-២៣ ខែ ឧសភា ឆ្នាំ ២០១៤, ឯកសារ **D118/242** ត្រង់ចម្លើយ A91 និង A98 ។

ប្រធានបទដែលបានលើកឡើងដោយប្រធានតំបន់[300] ។ ក្នុងបរិបទនេះ ខឹម ហឿន មិនបានស្នើឱ្យគេយល់ថាអ្នកស្រី អ៊ឹម ចែម មានសិទ្ធិអំណាចខ្ពង់ខ្ពស់ណាមួយដើម្បីធ្វើការដឹកនាំកិច្ចប្រជុំនានានៅតំបន់១៣ ក្នុងលក្ខណៈបង្ហាញថាអ្នកស្រីជាសមាជិកគណៈតំបន់ឡើយ ។ ដូចគ្នានេះដែរ ភស្តុតាងដែលត្រូវបានផ្តល់ដោយសាក្សី ម៉ឹង វេត ដែលថាអ្នកស្រី អ៊ឹម ចែម ជា "ជាអនុម្នាក់នៅក្នុងគណៈតំបន់១៣ ទទួលខុសត្រូវនារីនៅក្នុងតំបន់"[301] មិនមានខ្លឹមសារគាំទ្របានច្បាស់លាស់ចំពោះការស្នើឡើងថាអ្នកស្រី អ៊ឹម ចែម ជាសមាជិកនៃគណៈតំបន់១៣នោះទេ តែការពិតទៅសេចក្តីថ្លែងការណ៍របស់លោក ម៉ឹង វេត ស្នើឡើងថាអ្នកស្រី អ៊ឹម ចែម ស្ថិតក្នុងឋានៈទីពីរនៃការគ្រប់គ្រងនៅតំបន់១៣ ជាជាងការមានមុខងារជាសមាជិកគណៈតំបន់ពេញសិទ្ធិ ហើយនេះគឺសំដៅទៅលើតួនាទីរបស់អ្នកស្រីនៅក្នុងសមាគមនារី[302] ។

១៣០. នៅក្នុងសេចក្តីសន្និដ្ឋានចុងក្រោយ សចស បានផ្តល់សាក្សីម្នាក់គឺ ខឹម វ៉ៃ ជាសាក្សីដែលបានផ្តល់ភស្តុតាងផ្ទាល់ និងដែលអាចមានភាពគួរជឿជាក់បានពិតប្រាកដ[303] ។ ផ្ទុយទៅនឹងការទាមទាររបស់ សពអ ដោយយោងទៅលើបន្ទុក និងបទដ្ឋាននៃភស្តុតាង គឺមានមូលដ្ឋានមិនពេញលេញសម្រាប់អាចទាញការសន្និដ្ឋានណាមួយទាក់ទងនឹងមុខតំណែង ឬតួនាទី *ជាក់ស្តែង* ឬ *តាមច្បាប់* របស់អ្នកស្រី អ៊ឹម ចែម ជាពិសេសនៅពេលដែលវាត្រូវបានចោទប្រកាន់ថាបានរកឃើញពីមូលដ្ឋាននៃសិទ្ធិអំណាច លើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញ ការសម្លាប់ ការសម្លាប់រង្គាល ការធ្វើទារុណកម្ម ការឃុំឃាំង និងអំពើអមនុស្សធម៌ដទៃទៀតនៅភូមិភាគ

[300] កំណត់ហេតុស្តាប់ចម្លើយសាក្សី ខឹម ហឿន ធ្វើថ្ងៃទី ២១-២៣ ខែ ឧសភា ឆ្នាំ ២០១៤, ឯកសារ **D118/242** ត្រង់សំណួរ និងចម្លើយ Q-A98 និងចម្លើយ A99 ។

[301] *សូមមើល*, បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៧៥ *ដកស្រង់* កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ឹង វេត ធ្វើថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៤, ឯកសារ **D119/83** ត្រង់ចម្លើយ A18 ។

[302] កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ឹង វេត ធ្វើថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៤, ឯកសារ **D119/83** ត្រង់សំណួរ និងចម្លើយ Q-A18-19 ។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ឹង វេត ធ្វើថ្ងៃទី ០១ ខែ កុម្ភៈ កញ្ញា ២០១៥, ឯកសារ **D219/488** ត្រង់ចម្លើយ A36 និង A109 ។

[303] កំណត់ហេតុស្តាប់ចម្លើយសាក្សី ខឹម វ៉ៃ ធ្វើថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៥, ឯកសារ **D219/636** ត្រង់ចម្លើយ A38 ។

និវតី[304] ។ ដោយពិចារណាក្នុងបរិបទនៃភស្តុតាងទាំងស្រុង[305] វាច្បាស់ណាស់ សន្និដ្ឋានរបស់ សចស ភស្តុតាងមិនបានបង្កើតឱ្យអ្នកស្រី អ៊ឹម ចែម ជាសមាជិកគណៈតំបន់១៣ គឺជាការសន្និដ្ឋាន សមហេតុផល ។ គ្មានការសន្និដ្ឋានណាផ្សេងទៀតបើកចំហរទៅកាន់អង្គជំនុំជម្រះមាន ហេតុផលឡើយ ។ ជាការពិតណាស់ ជាជាងការវាយតម្លៃដែលគ្មានអង្គជំនុំជម្រះមានហេតុផល ណាអាចធ្វើបាននោះ សចស មានភារកិច្ចក្នុងការត្រិះរិះពិចារណាលើបំណងនៃការអះអាងរបស់ សពអ ។ ភស្តុតាងដែលបានដាក់បង្ហាញ គឺជាភស្តុតាងមានកំហុសយ៉ាងធ្ងន់ធ្ងរ និងមិនអាច ចង្អុលបង្ហាញឱ្យឃើញថាអ្នកស្រី អ៊ឹម ចែម ជាសមាជិកនៃគណៈតបន់១៣ ហើយនៅទីបំផុត ក៏ ចោទពីរបៀបដែល សចស រកមិនឃើញថាអ្នកស្រី អ៊ឹម ចែម មិនមែនជាអ្នកទទួលខុសត្រូវ ខ្ពស់បំផុត ។ ទឡ្ហីករណ៍ទី៦ គួរតែត្រូវច្រានចោល ។

## V. សំណើ

ចំពោះហេតុផលដែលបានលើកឡើងខាងលើ ក្រុមការពារក្ដីសូមដោយគោរពដល់ អបជ មេត្តា សម្រេចច្រានចោលបណ្ដឹងឧទ្ធរណ៍នេះ និងមេត្តាតម្កល់សេចក្ដីសម្រេចនៃដីកាដំណោះស្រាយថា អ្នកស្រី អ៊ឹម ចែម ស្ថិតក្រៅដែនយុត្តាធិការរបស់ អ.វ.ត.ក ៕

សូមមេត្តាទទួលយកសារណានេះដោយគោរព ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជាថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៧

សហមេធាវីការពារក្ដីអ្នកស្រី អ៊ឹម ចែម

| | |
|---|---|
| [ហត្ថលេខា] | [ហត្ថលេខា] |
| ប៊ិត ស៊ាងលឹម | Wayne JORDASH, QC |

---

[304] ដីកាសន្និដ្ឋានស្ថាពររបស់ សពអ ឯកសារ **D304/2** ត្រង់កថាខណ្ឌ ១៥៧-១៧២ ។

[305] ដីកាដំណោះស្រាយ, ឯកសារ **D308/3** ត្រង់កថាខណ្ឌ ១៤៨ លេខយោងជើងទំព័រ ២៧១ (ដកស្រង់សេចក្ដីថ្លែងការណ៍ ចំនួន ១០ ដើម្បីគាំទ្រដល់ការរកឃើញរបស់ពួកគាត់ដូច្នេះថា តួនាទីរបស់អ្នកស្រី អ៊ឹម ចែម នៅតំបន់១៣ គឺជាប្រធាន សមាគមនារី) ។